# ពិភពលោកអេភេសូ




**Recommend, White Young Jeon**

**Translator, Sreyleak Kohn**

**CRFI**

## ខគម្ពីរចងចាំប្រវត្តិសាស្ត្រនៃសេចក្តីប្រោសលោះរបស់ក្រុមជំនុំអេភេសូ (20 ខ)

(អេភេសូ 1:3) សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទានពរមកយើងក្នុងព្រះគ្រីស្ទ ដោយគ្រប់ទាំងព្រះពរខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់។
(អេភេសូ 1:17) ដើម្បីនឹងសូមឲ្យព្រះនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង គឺជាព្រះវរបិតាដ៏មានសិរីល្អបានប្រទានឲ្យអ្នករាល់គ្នាបានព្រះវិញ្ញាណ ដែលប្រោសឲ្យមានប្រាជ្ញា ហើយក៏បើកសំដែងឲ្យដឹងពីដំណើរស្គាល់ទ្រង់។
(អេភេសូ 2:8-9) ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ។ ក៏មិនមែនជាការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន។
(អេភេសូ 2:19) ដូច្នេះអ្នករាល់គ្នាមិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ គឺជាជាតិតែមួយនឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ។
(អេភេសូ 3:12) ហើយក្នុងទ្រង់យើងរាល់គ្នាមានសេចក្តីក្លាហាន និងច្បាប់ចូលដោយទុកចិត្តដោយសារសេចក្តីជំនឿដែលជឿដល់ទ្រង់ដែរ។
(អេភេសូ 3:16) ដើម្បីឲ្យទ្រង់បានប្រោសប្រទាន ឲ្យអ្នករាល់គ្នាបានព្រះចេស្តាចំរើនកំឡាំងនៃមនុស្សខាងក្នុង ដោយសារព្រះវិញ្ញាណទ្រង់ តាមសិរីល្អនៃទ្រង់ដ៏ប្រសើរក្រៃលែង។
(អេភេសូ 4:1-3) ដូច្នេះខ្ញុំជាអ្នកជាប់គុកក្នុងព្រះអម្ចាស់ ខ្ញុំទូន្មានអ្នករាល់គ្នាថា ចូរឲ្យអ្នករាល់គ្នាដើរបែបគួរនឹងការងារ ដែលទ្រង់បានហៅធ្វើចុះ។ ព្រមទាំងមានចិត្តសុភាព ហើយស្លូតបូតគ្រប់ជំពូកទាំងអត់ធ្មត់ ហើយទ្រាំទ្រគ្នាទៅវិញទៅមក ដោយស្រឡាញ់។ ហើយខំប្រឹងរក្សាសេចក្តីរួបរួមគ្នារបស់ព្រះវិញ្ញាណ ដោយសេចក្តីមេត្រីទុកជាចំណងផង។

(អេភេសូ 4:13)  ទាល់តែយើងរាល់គ្នាបានរួបរួម ខាងឯសេចក្ដីជំនឿចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ ដូចគ្នាទាំងអស់គឺដល់បានពេញជាមនុស្ស ហើយដល់ខ្នាតកំពស់នៃសេចក្ដីពោរពេញផងព្រះគ្រីស្ទ។
(អេភេសូ 4:22-24) ថាខាងកិរិយាប្រព្រឹត្តកាលពីដើម នោះត្រូវឲ្យអ្នករាល់គ្នាបាន ដោះមនុស្សចាស់ ដែលតែងតែខូចទៅ តាមសេចក្ដីប៉ងប្រាថ្នារបស់សេចក្ដីឆបោក ចោលចេញ។  ហើយឲ្យគំនិតក្នុងចិត្តបានកែប្រែជាថ្មីឡើង។ ព្រមទាំងប្រដាប់ខ្លួន ដោយមនុស្សថ្មីវិញ ដែលកើតមកក្នុងសេចក្ដីសុចរិត ហើយក្នុងសេចក្ដីបរិសុទ្ធរបស់ ផងសេចក្ដីពិត តាមភាពព្រះ។
(អេភេសូ 4:30) កុំធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធនៃព្រះបានព្រួយព្រះហឫទ័យ ដែលទ្រង់ ដៅចំណាំអ្នករាល់គ្នា ទុកសំរាប់ដល់ថ្ងៃប្រោសលោះនោះឡើយ។
(អេភេសូ 5:8-9) ដ្បិតកាលពីដើមអ្នករាល់គ្នាក៏ងងឹតដែរ តែឥឡូវនេះវិញ បានភ្លឺក្នុង ព្រះអម្ចាស់ ដូច្នេះចូរដើរដូចជាមនុស្សភ្លឺចុះ។ ដ្បិតផលផ្លែនៃពន្លឺ នោះមាននៅក្នុង គ្រប់ទាំងកិរិយាល្អ សេចក្ដីសុចរិត និងសេចក្ដីពិត។
(អេភេសូ 5:16) ទាំងលៃយកឱកាសឲ្យទាន់ពេលផង ពីព្រោះសម័យនេះអាក្រក់ ណាស់។
(អេភេសូ 5:18) កុំឲ្យស្រវឹងស្រាដែលនាំឲ្យព្រើលចិត្តឡើយ តែចូរឲ្យមានពេញជា ព្រះវិញ្ញាណវិញ។
(អេភេសូ 5:22) ស្ត្រីរាល់គ្នាអើយចូរឲ្យចុះចូលចំពោះប្ដីខ្លួន ដូចជាចុះចូលនឹងព្រះ អម្ចាស់ដែរ។
(អេភេសូ 5:25) បុរសរាល់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធខ្លួនដូចជាព្រះគ្រីស្ទបាន ស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះអង្គទ្រង់ជំនួសផង។
(អេភេសូ 6:1-3) ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ដ្បិត ធ្វើដូច្នោះទើបបានត្រូវ។ ចូរគោរពប្រតិបត្តិដល់មាតាបិតាខ្លួន នេះជាបញ្ញាត្តដំបូង

ដែលជាប់មានទាំងសេចក្ដីសន្យាផង។ ដើម្បីឲ្យអ្នករាល់គ្នាបានសេចក្ដីសុខហើយរស់នៅផែនដីជាយូរអង្វែងទៅ។
(អេភេសូ 6:7) ទាំងបំរើដោយអំណរ ដូចជាបំរើដល់ព្រះអម្ចាស់ផង មិនមែនដូចជាបំរើមនុស្សឡើយ។
(អេភេសូ 6:10-11) ឯសេចក្ដីឯទៀត បងប្អូនអើយ ចូរឲ្យមានកំលាំងឡើងក្នុងព្រះអម្ចាស់ ដោយឫទ្ធិបារមីរបស់ព្រះចេស្ដាទ្រង់។ ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអាចនឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអំបាលម៉ានរបស់អារក្ស។
(អេភេសូ 6:18) ព្រមទាំងប្រើសេចក្ដីអធិស្ឋាននិងសេចក្ដីទូលអង្វរគ្រប់យ៉ាង ដើម្បីអធិស្ឋានដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា ហើយចាំយាមក្នុងសេចក្ដីខ្ជាប់ខ្ជួននិងសេចក្ដីទូលអង្វរឲ្យពួកបរិសុទ្ធទាំងអស់។
(អេភេសូ 6:24) សូមឲ្យព្រះគុណ បានសណ្ឋិតនៅជាមួយនឹងអស់អ្នកណា ដែលស្រឡាញ់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នាដោយស្មោះត្រង់។

# អារម្ភកថានៃការសិក្សាសំបុត្រទៅកានក្រុមជំនុំអេភេសូ

1. នៅក្នុងសម័យបច្ចុប្បន្ននេះ ក្នុងពេលដែលយើងកំពុងជួបប្រទះនឹងបញ្ហាពីគោលលទ្ធិនៃក្រុមជំនុំ វាជារឿងមួយដែលធ្វើឲ្យយើងគិតពិចារណាសិក្សាទៅលើសំបុត្រទៅកាន់ក្រុមជំនុំអេភេសូ ពីព្រោះយើងអាចមើលឃើញពីក្រុមជំនុំដែលមានពេលដោយសិរីរុងរឿងនៃក្រុមជំនុំរបស់ព្រះនៅក្នុងនោះ។ វាជាការអស្ចារ្យណាស់នៅក្នុងចិត្តរបស់យើង ដែលផ្សាភ្ជាប់ទៅនឹងកណ្ឌគម្ពីរដែលត្រូវ បានហៅថាអេភេសូ ដែលជាប្រភពនៃដំណោះស្រាយនូវគ្រប់បញ្ហាដែលបានកើតមានឡើងនៅ ក្នុងក្រុមជំនុំនៃប្រវត្តិរបស់ក្រុមជំនុំ។ "តើខ្ញុំដែលជាអ្នកស្វែងគួររកដេញតាមអ្វី?" "តើអ្វីទៅ ជាអាថ៌កំបាំងនៃក្រុមជំនុំមានសិរីរុងរឿង?" "តើក្រុមជំនុំគួរច្រៀងចម្រៀងអ្វី?" "តើក្រុមជំនុំគួរតែរស់ នៅក្នុងលោកិយបែបណា?" ហើយ "តើក្រុមជំនុំអាចយកឈ្នះក្រុមជំនុំអាចយកឈ្នះលើខ្មាំងសត្រូវរបស់ខ្លួនដែលវាយប្រហារមកលើខ្លួនដោយរបៀបណា?" យើងអាចស្តាប់ចម្លើយនៃសំណួរខាងលើទាំងនេះ។ មេរៀនទាំងប្រាំបីដែលយើងនឹងស្តាប់នៅក្នុងសៀវភៅនេះ ស្ទើរតែទាំងអស់មានផ្ទុកនូវបរិមាណនៃអេភេសូគ្រប់ជំពូកទាំងអស់។ សៀវភៅនេះត្រូវបានកែសម្រួលដោយបែប cinemascope (ការអធិប្បាយ សំណួរ និង គោលគំនិតនៃរូបភាព)

2. យើងអាចទទួលបាននូវជំនួយនៅពេលដែលយើងធ្វើតាមនូវការចង្អុលបង្ហាញមួយចំនួន

(1) យើងសិក្សាអត្ថបទព្រះគម្ពីរដោយស្មោះត្រង់។ នៅពេលដែលយើងធ្វើការពិនិត្យពិច្ច័យទៅលើការសិក្សាខ្លឹមសារខគម្ពីរដែលត្រូវបានបញ្ជាក់អះអាងរួចដោយលម្អិត យើងអាចបើកចំហរដោយការបើកសំដែងនៃព្រះវិញ្ញាណបរិសុទ្ធ។

(2) ប្រសិនបើយើងអាចទន្ទិញចងចាំខគម្ពីរខុសៗគ្នានៅក្នុងអេភេសូ ឬគិតពីខគម្ពីរទាំងនោះម្តងហើយម្តងទៀតនៅក្នុងគំនិត។ ការទន្ទិញខគម្ពីរពិបាកណាស់ ដោយសារការប្រើប្រាស់នូវតួនាទីរបស់គំនិត ប៉ុន្តែព្រះគុណអស្ចារ្យនឹងត្រូវបានផ្តល់មកពីព្រះបន្ទូលរបស់ព្រះ។ នៅក្នុងដំណើរការនៃការរំលឹកម្តងហើយម្តងទៀត នោះយើងនឹងអាចរកឃើញសេចក្តីពិតនៅក្នុងនោះ។

(3) ដោយសារការរំលឹកនូវគោលគំនិតនៃរូបភាព យើងនឹងគិតពីអត្ថបទ។ រូបភាពនឹងជួយដល់គោលបំណងដែលយើងនឹងទទួលបានសេចក្តីពិតនៅក្នុងចិត្តរបស់យើង។ វិធីសាស្ត្រដើម្បីចងចាំសេចក្តីពិតនៅក្នុងទំនាក់ទំនងទៅនឹងរូបភាព។

(4) ការសិក្សានឹងធ្វើឲ្យមេរៀនដំណើរការ ការពិភាក្សា កិច្ចការ ការប្រលង ។ល។ បើទោះជាយើងស្តាប់ទៅកាន់មេរៀនបង្រៀនដោយមនុស្សម្នាក់ បន្ទាប់ពីស្តាប់រួច ប្រសិនបើយើងចែករំលែកការយល់ដឹងផ្ទាល់ខ្លួនទៅគ្នាទៅវិញទៅមក យើងនឹងទទួលបាននូវពិភពលោកមួយដ៏អស្ចារ្យនៅក្នុងជីវិតខាងវិញ្ញាណរបស់យើង។ ហើយនៅពេលដែលយើងព្យាយាមស្វែងរកចម្លើយទៅនឹងសំណួរមួយចំនួន នោះយើងនឹងទទួលបាននូវសេចក្តីជំនឿដោយខ្លួនឯងនៅក្នុងជីវិតរបស់យើង។

(5) ហើយយើងត្រូវការរៀបចំអត្ថបទនីមួយៗដោយយកចេញមកដោយយកចិត្តទុកដាក់ដោយស្មោះត្រង់ដើម្បីទទួលបាននូវការសិក្សាបន្តទៅទៀត។.

(6) យើងត្រូវការទំនោរទៅកាន់ការទទួលនូវគោលដៅរបស់ហើង។

3. នៅពេលដែលយើងដើរតាមនូវបំណងចិត្តរបស់ព្រះអម្ចាស់របស់យើងដែលបើកសំដែងនៅក្នុង ម៉ាថាយ 7:7-8 យើងនឹងទទួលបាននូវពិភពលោកមួយដែលគួរឲ្យចង់ដឹងនូវសេចក្តីពិត ពីព្រោះព្រះអម្ចាស់ទ្រង់ផ្តល់ដល់អ្នកដែលសូម ស្វែងរក និងគោះទ្វារ ដែលនឹងទទួលបាននូវរបស់ដែលប្រសើរជាប្រាកដ។

ទីមួយ វាជាចិត្តចង់បានរបស់ aite. "Aiteo" មានន័យថាសូមនៅក្នុងភាសាក្រិក (សំណូម និង ផ្តល់សំណួរណាមួយ) នៅពេលដែលយើងសិក្សានូវសេចក្តីពិត ប្រសិនបើយើងមានសំណួរមួយចំនួននោះជាជាការធម្មតាទេ ពីព្រោះពិភពនៃសេចក្តីពិតជារបស់ពិភពខាងវិញ្ញាណ។ ដោយសារតែយើងកាន់កាប់ខាងលោកិយដោយអំណាចដែលមានកំណត់របស់យើង វាជាការធម្មតាទេដែលយើងជួបនូវបញ្ហាមួយចំនួន។ ដូច្នេះយើងគួរតែសូមដល់ព្រះអម្ចាស់ដោយស្ងៀមស្ងាត់ "សូមទ្រង់បើកភ្នែករបស់ពួកយើងឲ្យឃើញពិភពលោក"។ បន្ទាប់មកព្រះអម្ចាស់នឹងឆ្លើយពីបំណងព្រះហឬទ័យទ្រង់មកកាន់យើង។

ទីពីរ វាជាបំណងចិត្តរបស់ jete។ វាមានន័យថាស្វែងរក ស្រាវជ្រាវរក។ ពេលដែលយើងស្វែងរកនោះយើងនឹងទទួលបានពីព្រះ។ បន្ទាប់ពពីយើងជឿព្រះយេស៊ូវ យើងបាត់បង់របស់ជាច្រើន។ ជាដំបូងសេចក្តីស្រឡាញ់ ផលដំបូង ការត្រាស់ហៅដំបូង បំណងចិត្តដំបូង ។ល។ យើងដឹងថាគ្រប់របស់ដែលបាត់បង់ទាំងអស់ នោះបានដាក់នៅក្នុងព្រះយេស៊ូវគ្រីស្ទ។ នៅពេលដែលយើងស្វែងរកព្រះយេស៊ូវហើយនឹងព្រះបន្ទូលរបស់ទ្រង់ នោះយើងនឹងរកឃើញ។ នៅពេលដែលយើងស្វែងរកដោយអស់ពីចិត្ត ព្រះយេស៊ូវគ្រីស្ទនឹងធ្វើឲ្យមានព្រឹត្តិការណ៍មួយដ៏អស្ចារ្យនៅក្នុងជីវិតរបស់យើង។ គ្រប់ការទាំងនេះត្រូវបានលាក់នៅក្នុងព្រះគ្រីស្ទ និង ព្រះបន្ទូលរបស់ទ្រង់។ នៅពេលដែលយើងរកឃើញការទាំងនេះ នោះព្រះអម្ចាស់នឹងធ្វើការដ៏អស្ចារ្យនៅក្នុងយើង។ ដូចជាពួកអ៊ីស្រាអែលនៅបាប៊ីឡូនបានទទួលដោយការបង្គាប់របស់ស៊ីប្រាស់ នូវសេចក្តីសន្យារបស់ព្រះជាម្ចាស់ដែលនឹងត្រូវសំរេចបំពេញដោយស្មោះត្រង់មកកាន់យើង។

ទីបី ជាជាបំណងចិត្តរបស់ kuluo។ វាមានន័យថាអ្នកដែលគោះទ្វារដោយម្រាមដៃនៅក្នុងការបន្ទាបខ្លួននិងភាពស្មោះត្រង់។ នៅពេលដែលយើងគោរពតាមបំណង

ព្រះហឫទ័យរបស់ទ្រង់ ហើយដាក់បញ្ហារបស់យើងនៅលើតុដោយស្មោះត្រង់ ព្រះអម្ចាស់នឹងប្រកាសថា "សេចក្តីជំនឿរបស់អ្នកធំណាស់ បំណងប្រាថ្នារបស់អ្នកនឹងត្រូវបានសំរេចជាបរិបូរហូរហៀរ"។ តាមប្រវត្តិសាស្ត្រតាមរយៈការគោះទ្វារដោយស្មោះត្រង់ដូច្នេះ ជាប្រភពនៃសេចក្តីពិតដែលផុសចេញមក។

សូមឲ្យព្រះគុណរបស់ព្រះអម្ចាស់នៅជាប់នឹងក្រុមជំនុំប្រើសប៊ីធារៀន ឲ្យស្វែងរកឃើញនូវកំរិតបីពាន់ និង រស់នៅដោយព្រះគុណនៅក្នុងការនោះ។

White Young Jeon

# មេរៀនទី 1

# សេចក្តីណែនាំលើអេភេសូ

"ចូរសូមនោះតែងនឹងឲ្យមកអ្នក ចូររកនោះតែងនឹងឃើញ ចូរគោះនោះតែងនឹងបើកឲ្យអ្នក។ ដ្បិតអស់អ្នកណាដែលសូម នោះរមែងបាន អ្នកណាដែលរក នោះរមែងឃើញ ហើយនឹងបើកឲ្យអ្នកណាដែលគោះដែរ។" (ម៉ាថាយ 7:7-8)

## មេរៀនទី1 ការណែនាំនៃអេភេសូ

## គោលគំនិត៖

1. រូបភាពទាំមូល- ចំណងជើងនៃអេភេសូគឺជាសិរីរុងរឿងនៃក្រុមជំនុំនៅក្នុងព្រះគ្រីស្ទ។
2. សៀវភៅដ៏ធំ និង សញ្ញាសៀវភៅនៅក្នុងនោះ– ប៉ូលបានសរសេរឆ្នាំ 61-63។
3. ការលំអរដែលភ្ជាប់ទៅនឹងសៀវភៅធំ – រូបភាពនៃអេភេសូ
4. ច្រវាក់ - សំបុត្រអេភេសូត្រូវថបានសរសេរនៅក្នុងគុកក្រុងរ៉ូមដោយប៉ូល។
5. ពន្លឺនៃរស្មីចែងចាំង - អេភេសូត្រូវបានសរសេរជាមួយនឹងបែបបទស្រួលៗ ប៉ុន្តែអត្ថន័យមាននូវទំហំដ៏ធំអស្ចារ្យ ជម្រៅដ៏ជ្រៅ និង កំពស់ដ៏ខ្ពស់។
6. រូបភាពនៅផ្នែកខាងស្តាំ – អេភេសូ1:-3 មានបន្ទូលថាគោលលិទ្ធិនៃសេចក្តីសង្គ្រោះ។
7. រូបភាពដែលនៅខាងឆ្វេង - អេភេសូ4:-6 បើកសំដែងពីការអនុវត្តដែលក្រុមជំនុំត្រូវធ្វើ។
8. សៀវភៅដែលមានពណ៌ខ្មៅ – ក្រុមជំនុំអេភេសូបានផ្តោតលើការថ្វាយបង្គំ ដែលក្រុមជំនុំត្រូវថ្វាយដល់ព្រះអម្ចាស់។
9. សៀវភៅតូចដែលបិទ - អេភេសូស្រដៀងទៅនឹងកូឡុស។

## មេរៀនទី 1
## ជីវប្រវត្តិរបស់អេភេសូនិងការណែនាំ

I. ជីវប្រវត្តិះ

(1) ក្រុងអេភេសូ

អេភេសូគឺជាចំណុចកណ្តាលនៃ clonical areas នៃទីក្រុងរ៉ូម ដែលមានទីតាំងនៅឆ្នេរភាគខាងលិចនាប្រទេសតួគីពេលបច្ចុប្បន្ន នៅតំបន់អាស៊ីមីណានាសម័យរបស់សាវ័កប៉ូល។ ទីក្រុងមានទីតាំងនៅច្រកចូលទន្លេ Cyster ចន្លោះភ្នំ coresus និង សមុទ្រ។ ហើយជាកន្លែងដែលជាក្រុងមជ្ឈមណ្ឌលនៃជំនួញ និង សកម្មភាពពាណិជ្ជកម្ម ជាផ្លូវដែលសំខាន់នៃជំនួញអាស៊ី ដែលត្រូវបានបង្កើត 70 ហ្វីត។ ហើយវាមានភាពល្បីល្បាញដោយសារការអប់រំនិងវិហាររបស់ព្រះនាងឌីអាណានៅទីនោះ។ ប៉ុន្តែពេលនេះកន្លែងនោះត្រូវបានក្លាយជាដីដែលត្រូវបំផ្លាញដែលមនុស្សមិនអាចរស់នៅបាន។

(2) ក្រុមជំនុំអេភេសូ

ក្រុមជំនុំអេភេសូមានទំនាក់ទំនងទៅនឹងសាវ័កប៉ូល នៅក្នុងដំណើរផ្សាយដំណឹងល្អរបស់គាត់ជាលើកទីពីរ។ នៅពេលដែលប៉ូលមិនបាននៅជាមួយពួកគេ ព្រីស្គីឡា និង អាហ្គុឡា បានធ្វើការជំនួសគាត់នៅទីនោះ។ (កិច្ចការ 18:20-19:1) បន្ទាប់មកនៅក្នុងដំណើរលើកផ្សាយដំណឹងល្អលើកទីបីរបស់ប៉ូល នៅពេលដែលគាត់បង្រៀនព្រះបន្ទូលរបស់ព្រះអស់រយៈពេលពីរឆ្នាំនឹងបីខែ នាងបានទទួលនូវបទពិសោធន៍នៃការលូតលាស់យ៉ាងអស្ចារ្យ។(កិច្ចការ 19:1-20:1)។ បន្ទាប់ពីពេលនោះមកធីម៉ូថេបានស្នាក់នៅអស់រយៈពេលយ៉ាងយូរ។ (I ធីម៉ូថេ 1:3) ហើយវាជាក្រុមជំនុំដែលអូនី

ស៊ីម៉ូបានបំរើនៅទីនោះ( II ធីម៉ូថេ 1:8) ហើយវាជាកន្លែងដែលសំខាន់នៃពន្ធ័កិច្ចរបស់សាវ័កប៉ូល។ (វិវរណ:2:1-10) សំបុត្រអេភេសូជាសំបុត្រនៃដំណើរវិលជុំវិញដែលប៉ូលបានផ្ញើទៅកាន់ក្រុមជំនុំនៅអាស៊ី ( AD 61-63)

2. ការណែនាំ

(1) ចំណាងជើងនៃអេភេសូ

មានទស្សនៈខុសៗគ្នាជាច្រើនទៅលើចំណាងជើងមានឡើងដោយសារ អត្ថន័យរបស់វាយ៉ាងហូរហៀរ។ ការដែលច្បាស់លាស់មួយត្រូវបានពិចារណា "ព្រះគុណរបស់ព្រះ" នៅក្នុងអេភេសូ 2:8-10 និង មួយផ្សេងទៀត "ការត្រាស់ហៅនៃអ្នកដែលជឿ" ឬ ការរួបរួមនៃក្រុមជំនុំ រូបកាយរបស់ព្រះគ្រីស្ទ។ បើទោះជាចំណាងជើងនេះត្រូវបានបើកសំដែងជាផ្នែកមួយចំនួននៃសំបុត្រ ប៉ុន្តែមិនអាចរាប់បញ្ចូលនូវអត្ថន័យទាំងមូលនោះឡើយ។ ដូច្នេះយើងអាចនិយាយបានថាចំណាងជើងទាំងមូលនៃអេភេសូគឺ "គោលបំណងដ៏នៅអស់កល្បរបស់ព្រះនិងឋានៈរបស់រាស្រ្តទ្រង់នៅក្នុងព្រះគ្រីស្ទ"។ អាចនិយាយក្នុងពាក្យមួយទៀតថា វាមានន័យថាក្រុមជំនុំដែលមានសិរីរុងរឿងនៅក្នុងព្រះគ្រីស្ទ។ សំបុត្រអេភេសូបង្ហាញពីសិរីរុងរឿងរបស់ក្រុមជំនុំយ៉ាងល្អ។ អត្ថបទបង្ហាញរូបភាពប្រាំពីរនៃក្រុមជំនុំ ហើយទាំងនោះជា រាស្រ្តរបស់ព្រះ (1:2) មរតករបស់ព្រះ ( 1:11), ដំណាក់របស់ព្រះ (2:19-22) , រូបកាយរបស់ព្រះគ្រីស្ទ (1:22-23) កូនក្រមុំរបស់ព្រះគ្រីស្ទ ( 5:22-31) ក្រុមជំនុំ ( 1:22 3:10,21) មនុស្សថ្មី ( 2:1-15)។

អ្នកវិទូសិក្សាខាងព្រះគម្ពីរបានបង្ហាញពីអេភេសូដូចតទៅនេះ

- F. W. Farrar - "វាត្រូវបានបង្ហាញដោយភាសាដែលមានភាពប្រសើរថ្លៃថ្លា យ៉ាងជ្រៅបំផុត ហើយល្អឥតខ្ចោះបំផុតនៅក្នុងសំបុត្ររបស់ប៉ូលទៅកាន់ពួកសាសន៍ដទៃ"
- W. O. Carver - "វាជាកិច្ចការដ៏អស្ចារ្យបំផុតនៅក្នុងប្រវត្តិសាស្រ្តរបស់មនុស្ស"។

- S.T. Coleridge - "វាជាកិច្ចការដែលមានពេញដោយការកោតខ្លាចដល់ព្រះបំផុតដែលមនុស្សបង្កើត"។

កណ្ឌគម្ពីរដែលអ្នកខាងកំណែទម្រង់ស្រឡាញ់ជាងគេនោះគឺកណ្ឌគម្ពីរនេះឯង។ អ្នកខាងកំណែទ្រង់របស់ស្កុត លោក ចន ណក្ស John Knox បានអានហើយសញ្ជឹងគិតលើសំបុត្រអេភេសូនៅពេលចុងក្រោយរបស់គាត់ ហើយលោក ចន ប៊ីយុនយ៉ាន់ John Byunyan ក៏មានការកោតសរសើរលើកណ្ឌគម្ពីរនេះ គឺដើម្បីនឹងទទួលបាននូចការអធិប្បាយដោយប្រៀបធៀបនៃដំណើរការទៅកាន់ស្ថានសួគ៌។

(2) រូបភាពនៃអេភេសូ

1) សំបុត្រក្នុងគុក- វាជាសំបុត្រមួយនៅក្នុងគុកនៅក្នុងដំណើរបេសកម្មផ្សាយដំណឹងល្អលើកទីមួយរបស់ប៉ូល។ បន្ទាប់ពីគាត់បានសរសេរអេភេសូ បន្តិចក្រោយមកគាត់ក៏បានសរសេរកូឡុស និង ភីលេម៉ូន ហើយនៅពេលចុងក្រោយគាត់អាចនឹងសរសេរភីលីព។ ការបញ្ជាក់ដែលគាត់ត្រូវបានជាប់គុកត្រូវបានបង្ហាញបីដងនៅក្នុង 3:1, 4:1 និង 6:20។

2) សំបុត្រជាទូទៅ- បើទោះជាសំបុត្រនេះត្រូវបានសរសេរដោយបែបបទនៃអក្ខរៈក្រមដោយងាយៗ ប៉ុន្តែប្រភេទយ៉ាងធំទូលាយនៃគំនិតរាប់បញ្ចូលទាំងពួកយូដា និងពួកសាសន៍ដទៃ ស្ថានសួគ៌ និង ផែនដី អតីតកាលនិងបច្ចុប្បន្នកាលនិងអនាគតផងដែរ។ ពាក្យ "ទាំងអស់" ត្រូវបានបង្ហាញលើសពី50ដង។

3) សំបុត្រខាងគោលលិទ្ធិ - អេភេសូជំពូក1ដល់ជំពូក3 បង្ហាញពីគោលលិទ្ធិនៃការប្រោសលោះ។ សេចក្តីប្រោសលោះនេះត្រូវបានរៀបគម្រោងដោយព្រះ ហើយត្រូវបានសំរេចបំពេញតាមរយៈសកម្មភាពរបស់ព្រះគ្រីស្ទ ហើយត្រូវបានអនុវត្ត

ដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះយើងយល់ថាក្រុមជំនុំដែលត្រូវបានសង្គ្រោះនោះជាសហគមន៍ដែលនៅអស់កល្ប ដែលត្រូវបានចាក់ឫសសេដ្ឋកិច្ចដ៏អស់កល្ប។

4) សំបុត្រដែលមានការអនុវត្ត - ហើយអេភេសូ4:-6 បើកសំដែងពីកំរិតក្រមនៃសកម្មភាពរបស់ក្រុមជំនុំ។ សកម្មភាពនេះមិនបាននិយាយត្រឹមតែសីលធម៌របស់មនុស្សនោះឡើយ ប៉ុន្តែក៏និយាយពីលទ្ធផលធម្មជាតិ ដែលសកម្មភាពនៃសេចក្តីប្រោសលោះនាំមកនូវអ្វីខ្លះ។ អ្នកបរិសុទ្ធដែលឈរនៅលើការប្រោសលោះដ៏ពិតទទួលបាននូវបទពិសោធលើការផ្លាស់ប្រែយ៉ាងពិតប្រាកដនៃទង្វើរបស់ពួកគេ ដែលចាប់ផ្តើមចេញពីអំណាចនៃសេចក្តីសង្គ្រោះ។ ដូច្នេះទំនាក់ទំនងនេះមិនអាចបំបែកចេញពីគ្នាទេ ដោយសារវាដូចជាទំនាក់ទំនងតែមួយរវាងដើមឈើនិងផ្លែវាដែរ។ ក្រុមជំនុំគួរតែបង្ហាញពីសិរីរុងរឿងនៃសេចក្តីសង្គ្រោះដោយការបើកសំដែងនូវសិរីល្អនៃសេចក្តីសង្គ្រោះ។

5) សំបុត្រនៃការថ្វាយបង្គំ - ដូច្នេះប៉ូលបានសង្កត់ធ្ងន់លើក្រុមជំនុំគួរតែថ្វាយខ្លួនរបស់គេទៅកាន់ព្រះគ្រីស្ទ ដែលជាសិរសានៃក្រុមជំនុំ។ ការថ្វាយបង្គំជារបៀបដែលយើងអាចប្រើអំណាចរបស់ព្រះគ្រីស្ទ ដែលទ្រង់ត្រូវបានលើកឡើងដល់ទីដែលខ្ពស់បំផុត។ ពីព្រោះក្រុមជំនុំត្រូវបានហៅមកសំរាប់ជាមរតករបស់ព្រះគ្រីស្ទចេញពីលោកិយងងឹត ក្រុមជំនុំជាទ្រព្យសម្បត្តិរបស់ព្រះគ្រីស្ទ។ ដូច្នេះក្រុមជំនុំគួរតែរស់នៅដូចជាអ្នកដែលបានថ្វាយខ្លួនដល់ព្រះគ្រីស្ទ។ (រ៉ូម 12:1-3)

6) សំបុត្រភ្លោះ- អេភេសូត្រូវបានហៅថាជាសំបុត្រភ្លោះ ពីព្រោះអត្ថន័យនៃអេភេសូរាប់បញ្ចូលអត្ថន័យដែលស្រដៀងជាច្រើនទៅនឹងកូឡូស។ អេភេសូមានប្រតិកម្មទៅលើក្រុមជំនុំជាពិសេស ប៉ុន្តែកូឡូសជាផ្នែកយ៉ាងសំខាន់របស់ព្រះគ្រីស្ទ ជាសិរសា

របស់ក្រុមជំនុំ។ ដោយសារជាសំបុត្រដែលសរសេរនៅក្នុងគុកដូចគ្នា ហើយអត្ថន័យក៏មានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំង។

(3) សេចក្តីពន្យល់នៃពាក្យនៅក្នុងអេភេសូ

1) នៅក្នុង – 90 ដង វាមានន័យថាជាការរួបរួមរវាងព្រះគ្រីស្ទនិងគ្រីស្ទាន។ "នៅក្នុងព្រះគ្រីស្ទ" បើកសំដែងពីសេចក្តីពិតជាក់ស្តែង។

2) ព្រះគុណ - 13ដង វាត្រូវបានសង្កត់ធ្ងន់លើព្រះគុណរបស់ព្រះនិងដំណឹងល្អ (កិច្ចការ20:2) ។

3) វិញ្ញាណ - 13 ដង វាចង្អុលទៅកាន់សេចក្តីពិតនិងជីវិតរបស់គ្រីស្ទាននៅក្នុងអេភេសូ។

4) បរិសុទ្ធ – 8 ដង វាបង្ហាញពីការប្រៀបប្រដូចដែលក្រុមជំនុំត្រូវបានរួបរួមនឹងព្រះគ្រីស្ទ។

5) ដើម្បីធ្វើ- 8 ដង វាចង្អុលទៅកាន់ការបង្រៀនជាក់ស្តែងនៅក្នុងអេភេសូ។ សីលធម៌របស់គ្រីស្ទានចង្អុលទៅកាន់គ្រប់សកម្មភាពទាំងអស់នៅក្នុងព្រះគ្រីស្ទ។

6) ជារបស់ស្ថានសួគ៌- 5 ដង ជាសភាពរបស់គ្រីស្ទានដែលត្រូវបានលើកទៅកាន់។

7) អាថ៌កំបាំង - 5 ដង វាជាសេចក្តីពិតដែលលាក់នៅក្នុងព្រះ (គម្រោងការនៃសេចក្តីប្រោសលោះ)

(4) ការណែនាំនៃអេភេសូ

រូបភាព

# មេរៀនទី 2

# ការកោតសរសើរនៃក្រុមជំនុំ

អេភេសូ 1:1-23

"សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទានពរខាងព្រលឹងវិញ្ញាណ នៅស្ថានដ៏ខ្ពស់" (អេភេសូ 1:3)

## មេរៀនទី 2 ការសរសើរនៃក្រុមជំនុំ

## គោលគំនិត៖

1. មនុស្សដែលមើលទៅកាន់សញ្ញាភ្លេង– ជាអត្ថន័យដែលសំខាន់នៃការសរសើរដែលក្រុមជំនុំគួរច្រៀង ដែលជាព្រះពរខាងវិញ្ញាណនៅក្នុងព្រះគ្រីស្ទ។
2. រូបតន្ទ្រ - ដំណឹងល្អដែលបានដាក់នៅក្នុងព្រះគ្រីស្ទ។

(1) សញ្ញាភ្លេងពីរគ្រាប់ដំបូង - ព្រះវរបិតា-ព្រះរៀបចំសេចក្ដីសង្គ្រោះរបស់ក្រុមជំនុំ។

1) សញ្ញាភ្លេងគ្រាប់ទីមួយ – ព្រះវរបិតា - ព្រះទ្រង់ជ្រើសរើសក្រុមជំនុំ

2) សញ្ញាភ្លេងគ្រាប់ទីពីរ – ព្រះវរបិតា - ព្រះរើសយកក្រុមជំនុំមកជាកូនរបស់ទ្រង់។

(2) សញ្ញាគ្រាប់ភ្លេងនៅក្នុងរូបភាព - ព្រះរាជបុត្រា - ព្រះបង្កើតសេចក្ដីសង្គ្រោះរបស់ក្រុមជំនុំ។

1) សញ្ញាភ្លេងគ្រាប់ទីមួយ - ព្រះរាជបុត្រា-ព្រះប្រោសលោះក្រុមជំនុំដោយលោហិតរបស់ទ្រង់។

2) សញ្ញាភ្លេងគ្រាប់ទីពីរ- ព្រះជាមរតករបស់ក្រុមជំនុំហើយក្រុមជំនុំជាមរតករបស់ព្រះ។

(3) សញ្ញាគ្រាប់ភ្លេងពីរនៅក្នុងផ្នែកចុងក្រោយ - ព្រះវិញ្ញាណបរិសុទ្ធ អនុវត្តសេចក្ដីសង្គ្រោះទៅកាន់ក្រុមជំនុំ។

1) សញ្ញាគ្រាប់ភ្លេងទីមួយ - ព្រះវិញ្ញាណធ្វើឲ្យមានសុវត្ថិភាពនៃសេចក្ដីសង្គ្រោះរបស់ក្រុមជំនុំ។

2) សញ្ញាគ្រាប់ភ្លេងទីពីរ - ព្រះវិញ្ញាណបើកសំដែងសេចក្ដីសង្គ្រោះដល់ក្រុមជំនុំ។

3. មនុស្សដែលលុតជង្គង់ចុះហើយកាន់នូចភាជនៈ - ប៉ូលបានថ្វាយការអធិស្ឋានទីមួយសំរាប់ក្រុមជំនុំអេភេសូ។

1) ក្លិនឈ្មុយដែលហោះឡើង - ផ្តល់នូវវិញ្ញាណនៃប្រាជ្ញានិងការបើកសំដែង ហើយធ្វើឲ្យយើងដឹងនូវសេចក្តីសង្ឃឹមនៅក្នុងព្រះគ្រីស្ទ។

រូបភាព

## មេរៀនទី 2
## ការកោតសរសើរនៃក្រុមជំនុំ

I. អត្ថបទ: អេភេសូ 1:1-23

II. ខគម្ពីរសំខាន់ៗ: អេភេសូ 1:3

III. ការណែនាំ:

ដោយសារគ្រប់ទាំងបទព្រះគម្ពីរជាព្រះបន្ទូលដែលគ្មានកំហុសដ៏មានជីវិតរបស់ព្រះ ដែលត្រូវបានសរសេរដោយការបើកសំដែងដោយព្រះវិញ្ញាណបរិសុទ្ធ (២ ធីម៉ូថេ 3:16) យើងគួរតែក្រោកឈរនៅចំពោះព្រះដូចជាចាស់ទុំទាំង៧០នាក់ នៅពីមុខភ្នំស៊ីណាយដោយការបន្ទាបខ្លួននិងភាពស្មោះត្រង់។ ការបើកសំដែងមិនបានផ្ទុកនូវទម្រង់និងអត្ថន័យដែលមិនស្គាល់នោះឡើយ ប៉ុន្តែមានលក្ខណៈដែលយើងអាចយល់បាន ហើយមានការឆ្លើយតបដោយស្មោះត្រង់ទៅកាន់ព្រះ។ ដូច្នេះបទគម្ពីរគួរតែបានបកប្រែហើយត្រូវឆ្លើយតបថាអាម៉ែនទៅកាន់ព្រះបន្ទូលដែលត្រូវបានបកប្រែ។

ប៉ូលត្រូវបានជាប់គុកនៅរ៉ូមពេលនេះ។ គាត់បានសរសេរអេភេសូដើម្បីនឹងប្រាប់ដំណឹងពីសេចក្តីពិតនៃក្រុមជំនុំពេញដោយសិរីរុងរឿងរបស់ព្រះ ដែលត្រូវបានគ្រោងនៅក្នុងព្រះទ័យរបស់ព្រះ ពីព្រោះគាត់បានស្តាប់ឮថាក្រុមជំនុំដែលត្រូវបានបង្កើតឡើងនៅអាស៊ីមីណាត្រូវបានបាត់បង់លក្ខណៈនៃក្រុមជំនុំបន្តិចម្តងៗជារឿយៗដោយឥទ្ធិពលនៃការបង្រៀនខុសឆ្គង។ ពីព្រោះការលើកទឹកចិត្តរបស់គាត់មានភាពស្មោះត្រង់ខ្លាំងទៅកាន់ពួកគេ ពួកគេបានចាប់ផ្តើមដោយមេរៀនមួយដែលរឹងមាំ។ គាត់បានអះអាងពីភាពជាសាវ័ករបស់គាត់ ហើយរាក់ទាក់ទៅកាន់ពួកគេ (1-2) បន្តិចក្រោយមកកាត់បានចងចាំអ្វីដែលព្រះបានធ្វើយ៉ាងអស្ចារ្យសំរាប់ក្រុមជំនុំ

ហើយបានសរសើរខ្លាំងៗដល់ព្រះជាម្ចាស់(3-14)។ ការនេះគួរតែជាការសរសើររបស់ពួកសាវ័កនិងការសរសើរដ៏អស់កល្បនៃក្រុមជំនុំដែលត្រូវបានប្រោសលោះ។ ដូច្នេះប៉ូលបានរៀបរាប់ពីហេតុផលដែលបាត់បង់នូវការសរសើរដោយលំអិត ហើយបានសូមដោយបំណាងយ៉ាងខ្លាំងដល់ក្រុមជំនុំនៅអាស៊ីមីណា (15-23)។ គាត់បានសូមថាឲ្យពួកគេបានរកឃើញការដូចគ្នា ការពិត និង សរសើរព្រះរហូត។ តើខ្ញុំមានចម្រៀងដូចគ្នានៅក្នុងចិត្តដូចប៉ូលមានបទពិសោធដែលឬទេ? ចូរយើងគិតពីការនោះនៅក្នុងអត្ថបទ។

IV. ការពន្យល់៖

1. ការស្វាគមន៍ (1-2)

(1) អ្នកស្វាគម – សាវ័កប៉ូល។ ប៉ូលបានសង្កត់ធ្ងន់ថាគាត់ផ្ទាល់បានទទួលភាពជាសាវ័កពីព្រះគ្រីស្ទ ចេញពីបំណងព្រះហឫទ័យរបស់ព្រះ ពីព្រោះគាត់បានអះអាងថាសារមិនមែនជារបស់គាត់ទេប៉ុន្តែជារបស់ព្រះគ្រីស្ទនិងព្រះបន្ទូលរបស់ព្រះផ្ទាល់។

(2) មនុស្សដែលត្រូវបានទទួលការស្វាគមន៍ - អ្នកបរិសុទ្ធនៅអេភេសូ និង អ្នកដែលស្មោះត្រង់នៅក្នុងព្រះគ្រីស្ទ។ ការចម្លងដែលមានអំណាចមិនបានសរសេរនៅក្នុងអេភេសូ ពីព្រោះវាជាសំបុត្រវិលជុំដែលក្រុមជំនុំអាចអានបាន ដែលមិនមានការកំណត់នៅក្នុងក្រុមជំនុំអេភេសូ។ យ៉ាងណាក៏ដោយ កម្មវត្ថុនៃអ្នកអានដែលអាចអានអេភេសូត្រូវបានកំណត់ត្រឹមតែអ្នកបរិសុទ្ធនៅក្នុងព្រះគ្រីស្ទ។

(3) អត្ថន័យនៃការស្វាគមន៍ – ការប្រសិទ្ធិពររបស់គាត់ព្រះគុណនិងសេចក្ដីសុខសាន្ត។ វាជាការសំខាន់នៅក្នុងការចេញពីទីណាមួយ។ វាជាព្រះពរចេញពីព្រះត្រៃ

ឯក។ ព្រះគុណដែលនៅទីនេះជាសេចក្ដីមេត្តារបស់ព្រះដែលបានផ្ដល់មកគ្រីស្ទាន ដោយគ្មានលក្ខខណ្ឌ។ វាមិនមែនជាអត្ថប្រយោជន៍ខាងរបស់របរនិងរូបសាច់ឡើយ ប៉ុន្តែជាព្រះគុណខាងវិញ្ញាណ។ នេះជាព្រះពរដែលចេញមកពីតែព្រះត្រៃឯក ប៉ុណ្ណោះ។ ហើយសេចក្ដីសុខសាន្តមានន័យថាជាសុវត្ថិភាពនិងការប្រកបគ្នាដែល អ្នកដែលទទួលបានព្រះគុណពេញចិត្ត។ ដើម្បីទទួលបានសេចក្ដីសុខសាន្តជាដំបូង ព្រះគុណគួរតែចាក់បង្ហូរចេញមកពីព្រះ។ នេះជាលំដាប់លំដោយដែលតាំងនៅរបស់ ព្រះ។ តើអ្នកចង់មានសេចក្ដីសុខសាន្តនៅក្នុងជីវិតរបស់អ្នកដែរឬទេ? ដំបូងនោះត្រូវ តែទទួលព្រះគុណរបស់ព្រះជាមុខសិន។

2. ការសរសើរ (3-14)

(1) ចំណាងជើងដ៏ធំនៃការសរសើរដំកើង - "ព្រះពរដែលក្រុមជំនុំទទួលបាននៅ ក្នុងព្រះគ្រីស្ទ" (3) ហេតុអ្វីបានជាគេត្រូវសរសើរដំកើង? ដោយសារគេសរសើរដំ កើងសម្រាប់ព្រះពរខាងព្រលឹងវិញ្ញាណនិងទីវាលរបស់វា (Tertullian)។ អ្នកដែល ស្គាល់នូវសេចក្ដីប្រោសលោះអាចមានអារម្មណ៍ពីព្រះគុណនៃសេចក្ដីប្រោសលោះ យ៉ាងក្រៃលែង។

(2) អត្ថន័យព្រះពរខាងវិញ្ញាណ - ប៉ូលបានបង្ហាញព្រះពរដោយលំអិត។ តើអ្វីទៅ ដែលជាងព្រះពរដែលប៉ូលមានការកោតសរសើរនៅក្នុងព្រលឹងរបស់គាត់? និយាយ ដោយខ្លី វាជាសេចក្ដីស្រឡាញ់របស់ព្រះ ដែលគាត់បានថ្វាយខ្លួនដាច់ដល់ទ្រង់។ នៅរំពេចដែលសាវ័កយល់នូវសេចក្ដីស្រឡាញ់ដ៏ហូរហៀរនៅក្នុងការដើរចូរទៅក្នុង ស្ថានសួគ៌កំរិតទីបីបានស្វាគមន៍នៅក្នុងបរិស្ថានមួយនៃសេចក្ដីទុក្ខលំបាក ទៅតាម លំហូរនៃសេចក្ដីកោតសរសើររបស់គាត់ គាត់សរសើរដំកើងព្រះពីព្រោះដោយសារ តែព្រះពរ។ គាត់ត្រូវបានបើកសំដែងនូវព្រះគុណដ៏អស្ចារ្យ ដូចជាការបញ្ជាក់នៃ ប្រយោគមួយនៅក្នុងខ 1-13។

A. សេចក្តីសង្គ្រោះដែលព្រះវរបិតាបានគ្រោងទុក (4-6) - គាត់បានមើលឃើញអត្ថន័យអាថ៌កំបាំងនៃសេចក្តីប្រោសលោះ ដែលព្រះវរបិតាមានកាលពីដើមដំបូងមកនៅក្នុងព្រះគុណនិងសេចក្តីពិត គាត់បានសរសើរដំកើងព្រះដោយសារសេចក្តីប្រោសលោះដ៏បរិបូររបស់ទ្រង់ ដែលគ្រប់ការទាំងអស់ត្រូវបានត្រូវធ្វើឲ្យមានការចុះសម្រុងគ្នានៅក្នុងចំណុចកណ្តាលនៃអត្ថន័យនៃសេចក្តីប្រោសលោះ។ (រ៉ូម 8:37-39, 11:33-36 ១ ធីម៉ូថេ 3:16) នៅក្នុងចំណោមការទាំងនោះមានការពីរដែលខុសប្លែកពីគេត្រូវបានបើកសំដែងមក។

1) ទ្រង់បិទការទាំងនោះ។ ព្រះទ្រង់បានបញ្ញាត្តហើយមិនបានជ្រើសរើសដើម្បីសង្គ្រោះគ្រប់មនុស្សមានបាបចេញពីអំពើរបាបដ៏អាក្រក់របស់ពួកគេឡើយ ប៉ុន្តែសង្គ្រោះមនុស្សមួយចំនួនប៉ុណ្ណោះ។ គោលបំណងដែលព្រះយេស៊ូវបានយាងមកនៅក្នុងលោកិយនេះ នោះមិនមែនដើម្បីសង្គ្រោះមនុស្សទាំងអស់នោះឡើយ ប៉ុន្តែមនុស្សខ្លះប៉ុណ្ណោះ។ ចៀមរបស់ព្រះអម្ចាស់មានកំណត់។ ទៅកាន់ពួកយូដាដែលមិនបានទទួលទីបន្ទាល់របស់ព្រះយេស៊ូវ ទ្រង់បានប្រកាសថាពួកគេមិនបានមកឯព្រះយេស៊ូវ ដោយសារព្រះវរបិតាមិនបានជ្រើសរើសពួកគេ ហើយពួកគេមិនមែនជាចៀមរបស់ព្រះអម្ចាស់ទេ។ ហើយបើទោះជាមានមនុស្សមួយចំនួនមិនបានមកឯទ្រង់ក៏ដោយ ចុងក្រោយចៀមផ្សេងទៀតដែលមិនបានរាប់បញ្ចូលនៅក្នុងរបងនឹងមកកាន់ទ្រង់។ ដូច្នេះប៉ូលបានប្រកាសដំណឹងល្អដោយសេចក្តីព្យាយាម គាត់បានសារភាពថាមានតែអ្នកដែលព្រះបានដៅចំណាំទុកសំរាប់នឹងផ្តល់ជីវិតអស់កល្បជានិច្ចប៉ុណ្ណោះ ដែលបានសារភាពអំពើបាបរបស់ពួកគេហើយជឿលើដំណឹងល្អ។

2) ទ្រង់ដៅទុក។ ការដៅចំណាំនិងចំណេះដឹងជាមុនគឺនៅខាងមុខការរើសតាំង។ ពីព្រោះសេចក្តីសង្គ្រោះនៃការដៅចំណាំនិងចំណេះដឹងដែលមានស្រាប់ ដែលគ្រីស្ទានដែលនៅក្នុងព្រះគ្រីស្ទតែងតែអរគុណដល់ព្រះ។

ដោយសារព្រះបានដាក់ខ្ញុំ ដែលជាមនុស្សមានបាបនៅក្នុងព្រះគ្រីស្ទដោយគ្មានលក្ខខណ្ឌហេតុផលអ្វីសោះ។ បើទោះជាមាននិកាយមួយចំនួនត្រូវបានបែងចែកដោយសារតែការមួយណាជាមុន មិនថាការដៅចំណាំឬចំណេះដឹងដែលមានស្រាប់ នៅពេលដែលយើងយល់ពីទស្សនៈរបស់ព្រះជាមុន នោះយើងនឹងអាចដោះស្រាយបញ្ហានោះបាន។ យ៉ាងណាក៏ដោយវាជាការជាក់ស្តែងដែលការប្រោសលោះត្រូវបានចាប់ផ្តើមដោយចំណេះដឹងមានស្រាប់និងការដៅចំណាំ ឬ ការដៅចំណាំ និង ចំណេះដឹងដែលមានស្រាប់។

B. ការសំរេចបំពេញរបស់ព្រះរាជបុត្រា (7-12) - អង្គទីពីរនៃព្រះត្រៃឯកត្រូវបានសំរេចបំពេញនូវគម្រោងការនៃសេចក្តីប្រោសលោះរបស់ព្រះវរបិតានៅក្នុងហឫទ័យរបស់ទ្រង់។ មានព្រឹត្តិការណ៍និងការទស្សទាយជាច្រើននៅក្នុងព្រះគម្ពីរសញ្ញាចាស់ទៅកាន់ព្រះគ្រីស្ទត្រូវបានសំរេចបំពេញនាកំណើត ព័ន្ធកិច្ចសាធារណៈ ការសុគតនិងការរស់ឡើងវិញរបស់ទ្រង់។ ការដែលទ្រង់មានបន្ទូលចុងក្រោយ "ការនេះត្រូវបានបញ្ចប់ហើយ" មានន័យថាគ្រប់ការទាំងអស់ត្រូវបានសំរេចបំពេញហើយ។ យោងតាមព្រះបន្ទូលដោយសំបុត្រហេព្រើរ នៅពេលដែលទ្រង់ថ្វាយខ្លួនរបស់ទ្រង់ទៅកាន់ព្រះម្តងជាសំរេច។ ទ្រង់បានថ្វាយដង្វាយដ៏អស់កល្បទៅព្រះជាម្ចាស់ (ហេព្រើរ 10:12-13)។ សាវ័កប៉ូលបានណែនាំផ្លូវពិសេសបីនៅក្នុងអាថ៌កំបាំងនៃសេចក្តីប្រោសលោះដែលព្រះរាជបុត្រាបានសំរេចបំពេញ។

1) ដែលបានប្រោសលោះ - សេចក្តីប្រោសលោះរបស់ព្រះរាជបុត្រា មានន័យថាទ្រង់បានសងថ្លៃឈ្នួលនៃអំពើបាបរបស់រាស្ត្រទ្រង់ ហើយបានទិញដាច់ជាមរតករបស់ទ្រង់។ តម្លៃនោះជាលោហិតដ៏មានតម្លៃរបស់ព្រះរាជបុត្រា។ គ្រប់អំពើបាបទាំងអស់ត្រូវបានអត់ទោសដោយសេចក្តីមេត្តានៃការសុគតរបស់ទ្រង់ ហើយគេត្រូវបានប្តូរទៅជាទ្រព្យសម្បត្តិរបស់ទ្រង់ចេញពីទ្រព្យ

សម្បត្តិរបស់សាតាំង ព្រះពរនៃអ័ដាមទីពីរចេញពីបណ្តាសាររបស់អ័ដាមទីមួយ។ ការផ្លាស់ប្រែនៃទ្រព្យសម្បត្តិនិងមុខមាត់គឺសេចក្តីប្រោសលោះ(យ៉ូហាន5:24)។,

2) ដែលត្រូវបានរួបរួម (8-10) - សេចក្តីប្រោសលោះនេះរាប់បញ្ចូលទាំងសេចក្តីប្រោសលោះគ្រប់ការទាំងអស់ជាមួយសេចក្តីសង្គ្រោះរបស់កូនរបស់ទ្រង់ជាច្រើននាក់។ ព្រះទ្រង់បានធ្វើឲ្យការទាំងអស់ឲ្យរួមគ្នានៅក្នុងព្រះគ្រីស្ទ។ ទាល់តែគ្រប់ទាំងការរួបរួមនិងភាពចុះសម្រុងត្រូវពឹងលើការនេះ នោះគេនឹងក្លាយទៅជាចេស្តានៃបាបិល ពីព្រោះព្រះបានគ្រោងគ្រប់ការទាំងអស់នឹងត្រូវបានរួបរួមតែនៅក្នុងព្រះគ្រីស្ទ។ ហើយពិភពលោកខាងវិញ្ញាណផ្ទាល់ខ្លួនក៏ដើរតាមបន្ទាត់នេះដែរ។ ដូចដែលព្រឹត្តិការណ៍និងគំនិតជាច្រើនត្រូវបានផ្តោតទៅលើព្រះគ្រីស្ទ ជាចុងក្រោយការយល់ច្រឡំត្រូវបានរៀបចំនិងរបៀបរៀបរយត្រូវបានបង្កើត ហើយសេចក្តីសុខសាន្តនឹងមកឯយើង។ មុនពេលទទួលព្រះគ្រីស្ទយើងមិនអាចភ្លក់សេចក្តីសុខសាន្តចេញពីការបង្រួបបង្រួមពិតនោះឡើយ។

3) មរតក (11) - អ្នកដែលត្រូវបានប្រោសលោះនៅក្នុងអង្គប្រោសលោះ ជាមរតករបស់ព្រះ ហើយព្រះជាមរតករបស់ពួកគេ។ កំរិតនៃស្ថានសួគ៌ទីបី (ស្ថានសួគ៌) ដែលសាវ័កបានឃើញនោះជាមរតករបស់យើង ការដែលសំខាន់ជាងនេះទៀតនោះគឺជាភាពជាក់ស្តែងដែលព្រះផ្ទាល់ទ្រង់ជាមរតករបស់យើង។ ទំនាយត្រូវបានសំរេចបំពេញនៅទីនេះ (ហូសេ 14:3, 8)។ មនុស្សដែលមានព្រះជាមរតករបស់គេ ទឹកដោះនិងទឹកឃ្មុំនៃទឹកដីកាណាននិងភាពបរិបូរនៃព្រះអម្ចាស់។ ក្នុងពាក្យមួយទៀតការបកប្រែអាចធ្វើទៅបានថាជាមរតករបស់ព្រះ។ វាជាការបញ្ជាក់អះអាងដ៏អស្ចារ្យមួយដែលធ្វើឲ្យយើងជាមរតករបស់ទ្រង់ ដើម្បីនឹងបើកសំដែងនូវការរំពឹងទុករបស់ព្រះសំរាប់យើង។ ដូច្នេះប៉ូលបាននិយាយថាគ្រីស្ទានជាវាលស្រែរបស់ព្រះ ជាអ្នកធ្វើការជាមួយរបស់ព្រះហើយដំណាក់របស់ព្រះ (១ កូរិនថូស 3:9)។

C. ការអនុវត្តរបស់ព្រះវិញ្ញាណបរិសុទ្ធ (13-14) គាត់មានការកោតសរសើរនៅពេលដែលគាត់បានឃើញថាព្រះវរបិតាបានគ្រោងសេចក្តីប្រោសលោះ ព្រះរាជបុត្រាបានសំរេចបំពេញសេចក្តីប្រោសលោះ ហើយព្រះវិញ្ញាណបរិសុទ្ធបានអនុវត្តសេចក្តីប្រោសលោះទៅកាន់រាស្ត្ររបស់ទ្រង់ផ្ទាល់ដូចជាវិញ្ញាណទីបី។ តើទ្រង់បានអនុវត្តសេចក្តីប្រោសលោះដល់ពួកគេដោយរបៀបណា? សាវ័កបានសង្កេតឃើញការពីរយ៉ាង។

1) ដែលត្រូវបានបោះត្រា។ ព្រះវិញ្ញាណបរិសុទ្ធមកកាន់អ្នកជឿដូចជាសុវត្ថិភាពមួយ។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធមកកាន់យើង យើងត្រូវបានកើតជាថ្មីម្តងទៀតហើយទទួលបាននូវការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ ហើយមិនត្រូវចាកចេញពីទ្រង់អស់កល្បនោះឡើយ ហើយត្រូវសំរេចបំពេញនូវសេចក្តីប្រោសលោះ។ ព្រះវិញ្ញាណបរិសុទ្ធនឹងចាប់ផ្តើមការល្អនិងសំរេចបំពេញសេចក្តីប្រោសលោះរហូតដល់ពេល ដើម្បីនឹងធ្វើឲ្យកូនក្រមុំរបស់ព្រះគ្រីស្ទ ដែលជាអ្នកដែលមានរូបឆ្លុះរបស់ព្រះ។ ដូច្នេះប៉ូលបានជម្រុញឲ្យយើងមិនត្រូវលេបភ្លើងនៃព្រះវិញ្ញាណបរិសុទ្ធ និងធ្វើឲ្យទ្រង់មានសេចក្តីព្រួយនោះឡើយ។ គ្រីស្ទានបានទទួលការបង់លោះរួចហើយ (សុវត្ថិភាព) នៅក្នុងទ្រង់ ដែលគេអាចទៅកាន់ស្ថានសួគ៌ដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ជាអង្គដែលធ្វើឲ្យពួកគេលន់តួបាបនិង ផ្លាស់ប្រែទៅជាមនុស្សថ្មី បើទោះជាមានការល្បួងល្បងជាច្រើនវាយប្រហារយើងក៏ដោយ។

2) ត្រូវបានបើកសំដែង។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងយើងដោយការដឹកនាំទៅកាន់សេចក្តីពិត ទ្រង់តែងតែបំភ្លឺទៅកាន់ការបើកសំដែង។ ព្រះវិញ្ញាណបរិសុទ្ធធ្វើការតាមវិធីសាស្ត្រជាច្រើនដើម្បីធ្វើឲ្យយល់នូវសេចក្តីពិតនៅក្នុងគំនិតនិងគ្រប់ព្រឹត្តិការណ៍ទាំងអស់។ ទ្រង់បានធ្វើឲ្យយើងស្គាល់ដោយការបើកបទគម្ពីរ ធ្វើឲ្យស្គាល់ភាពពិតជាក់ស្តែងអំពី របៀបការដែលពិតៗ និងរបៀបគេចចេញពីបញ្ហាទាំងនោះ។ វាជាកិច្ចការនៃការបំភ្លឺដែលព្រះវិញ្ញាណបរិសុទ្ធបើកភ្នែករបស់យើ

ង។ ដូច្នេះដោយហារគ្រីស្ទានត្រូវការវាជារៀងរាល់ថ្ងៃ នោះព្រះវិញ្ញាណបរិសុទ្ធនៅតែបន្តធ្វើការ។ ពិតណាស់ព្រះវរបិតានិងព្រះរាជបុត្រាធ្វើការជាមួយគ្នា។ ដោយសារសេចក្តីសង្គ្រោះរបស់គ្រីស្ទានត្រូវបានសំរេចដោយកិច្ចការរបស់ព្រះត្រៃឯក។ ប៉ូលមិនអាចនឹងទប់នូវការសរសើរដល់ព្រះនោះឡើយ។ឱព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ចូរសរសើរព្រះអម្ចាស់។

3. ការទូលអង្វរ (15-23)

ប៉ូលដែលជាអ្នកដែលស្គាល់នូវហេតុផលនៃការសរសើរដំកើងបានសូមការទូលអង្វរដែលរឹងមាំទៅកាន់ព្រះអម្ចាស់។ ការទូលអង្វរត្រូវបានផ្តោតលើការធ្វើឲ្យក្រុមជំនុំស្គាល់នូវសេចក្តីប្រោសលោះនិងកោតសរសើរការនោះនិងដំកើតដល់ព្រះអម្ចាស់។

(1) ការអរព្រះគុណ (15-16) - ប៉ូលបានកោតសរសើរម្តងទៀត។ ហេតុផលដែលគាត់ចាំនិងគិតលើក្រុមជំនុំអេភេសូគឺ ដើម្បីនឹងធ្វើឲ្យបានតាំងជាប់នៅក្នុងក្រុមនៃសេចក្តីប្រោសលោះយ៉ាងអស្ចារ្យ។ ក្រុមជំនុំមិនអាចទប់នូវការសរសើរដំកើងនៅគ្រប់កាលៈទេសៈបានឡើយ ពីព្រោះក្រុមជំនុំធ្វើការនៅក្នុងព្រះគ្រីស្ទដែលនៅក្នុងពេលវេលានិងកន្លែងដែលមិនអាចទៅដល់បាន។

(2) ការទូលអង្វរ (17-19) - គាត់បានសូមការទូលអង្វរបីជាមួយការសរសើរដំកើង។ ការសូមទាំងបីនេះមានគោលបំណងលើការយល់បីកំណាប់ដែលអនុញ្ញាតឲ្យអ្នកដែលជឿ។

ការទូលអង្វរទីមួយ - ធ្វើឲ្យពួកគេស្គាល់ព្រះ។ សាវ័កបានសូមថាពួកគេគួរតែស្គាល់ព្រះដោយព្រះវិញ្ញាណបរិសុទ្ធនៃការបើកសំដែង ពីព្រោះគាត់ដឹងថាគោលបំណងចចុងក្រោយបង្អស់នៃសេចក្តីជំនឿរបស់យើងគឺដើម្បីស្គាល់ព្រះជាចំណុចកណ្តាលនៃសេចក្តីប្រោសលោះ។ ជីវិតអស់កល្បមានន័យថាការស្គាល់ព្រះ (យ៉ូហាន

17:3)។ ជីវិតគ្រីស្ទានគឺការស្គាល់ព្រះ។ ដូច្នេះជីវិតរបស់គាត់មាននូវពេលដ៏អស្ចារ្យពីព្រោះគោលបំណងនៃការបន្ទុតគឺជាការស្គាល់ព្រះយ៉ាងជ្រាលជ្រៅសំរាប់ការប្រកបគ្នា។

ការទូលអង្វរទីពីរ- ធ្វើឲ្យយើងសង្ឃឹមលើការត្រាស់ហៅ។ វាជាការសំខាន់ណាស់ក្នុងការស្គាល់នូវសង្ឃឹមនៃការត្រាស់ហៅបន្ទាប់ពីស្គាល់ព្រះដោយផ្ទាល់ខ្លួន។ សេចក្ដីប្រោសលោះផ្ទាល់ខ្លួនរាប់បញ្ចូលនូវបេសកម្ម។ ពីព្រោះវាទាមទាមនូវគោលបំណង វាមាននូវសង្ឃឹមដ៏រស់។ ដូច្នេះព្រះវិញ្ញាណបរិសុទ្ធបានស្ដីបន្ទោសទៅកាន់សង្ឃឹមនៃការត្រាស់ហៅ ហើយបានកែតម្រូវ និង លើកទឹកចិត្តសត្រូវពេញមួយជីវិត ដូចជាម៉ូសេនិងពេត្រុសបានធ្វើដូច្នេះដែរ (អេសាយ6 លូកា5 និក្ខមនំ3)។

ការទូលអង្វរទីបី- ធ្វើឲ្យពួកគេស្គាល់នូវមរតកដែលពេញដោយសិរីរុងរឿង។ សាវ័កចង់ធ្វើឲ្យពួកគេស្គាល់ព្រះគុណដំបូងជាមួយនឹងមរតកដែលបរិបូរ។ ប្រសិនបើយើងមិនស្គាល់អ្វីដែលយើងបានទទួលរួចហើយទេ នោះយើងមិនអាចនឹងស្គាល់តម្លៃនៃមរតកនាពេលអនាគតនោះឡើយ។ ពីព្រោះអ្នកបរិសុទ្ធនាពេលបច្ចុប្បន្នអាចក្លាយជាអ្នកបរិសុទ្ធនាពេលអនាគត។ ព្រះបានធ្វើឲ្យពួកគេក្លាយជាសមាជិកក្រុមជំនុំ ហើយលើសពីនោះទៀតបានសន្យាឲ្យបានរីករាយនឹងមរតកដ៏បរិបូរ។ គឺដូចជាកូនទីពីរដែលបានត្រឡប់ទៅកាន់ឪពុក គាត់បានទទួលព្រះគុណថែមទៀតចេញពីព្រះបិតា បើទោះជាគាត់គ្រាន់តែចង់បំរើដូចជាអ្នកបំរើម្នាក់របស់ឪពុកក៏ដោយ។ នៅពេលដែលយើងជឿដល់ព្រះយេស៊ូវ ទ្រង់បានប្រទាននូវមរតកដ៏បរិបូរហូរហៀរដល់យើង។ ប្រសិនបើអ្នកណាដែលមិនអើពើនឹងការនេះនឹងរស់នៅដូចជាអ្នកសុំទានខាងវិញ្ញាណ ប៉ុន្តែអ្នកណាដែលស្គាល់នឹងក្លាយជាមនុស្សដែលពេញបរិបូរ។

ការទូលអង្វរទីបួន - ធ្វើឲ្យពួកគេស្គាល់ចេស្ដាដ៏ខ្ពស់បំផុត។ សាវ័កបានស្គាល់ច្បាស់ពីពិភពលោក កន្លែងបច្ចុប្បន្នដែលបញ្ហាជាច្រើននឹងកើតឡើង។ ប៉ូលជាអ្នកដែលយល់ថាយើងអាចយកឈ្នះគ្រប់ការទាំងអស់ អះអាងថាអ្នកជឿមានចេស្ដា

របស់ព្រះនៅក្នុងពួកគេ។ ពីព្រោះប្រសិនបើនរណាម្នាក់មិនស្គាល់ចេស្តានេះ គេនឹងធ្លាក់ចុះទៅក្នុងការមិនជឿ គាត់បានអធិស្ឋានទៅព្រះ។ គាត់បានអះអាងថាចេស្តារបស់ព្រះដែលធ្វើការនៅក្នុងចិត្តរបស់គាត់នោះចេញមកពីចេស្តានៃសេចក្តីរស់ឡើងវិញពីផ្នូររបស់ទ្រង់។ ប្រសិនបើជាពិត គ្រីស្ទានមានចេស្តានៃការផ្លាស់ប្រែ ដែលអាចប្តូរទៅជាអ្វីមួយពីរបស់ដែលគ្មានសោះ ហើយអំណាចនៃការផ្លាស់ប្រែដែលអាចប្តូរទៅជាពន្លឺចេញពីសេចក្តីងងឹត។ ដូច្នេះការអធិស្ឋាននេះធ្វើឲ្យយើងស្គាល់ថាសេចក្តីស្រឡាញ់របស់ព្រះជាសេចក្តីស្រឡាញ់ដ៏រឹងមាំស្ថិតស្ថេរ។

សរុបសេចក្តី៖

តើអ្នកដែលជាសមាជិកក្រុមជំនុំមានការសរសើរដំកើងរបស់ប៉ូលនៅក្នុងព្រលឹងដែរឬទេ? ហេតុអ្វីបានជាអ្នកអរគុណដល់ព្រះ? លើសពីការទាំងអស់តើខ្ញុំអាចសរសើរដំកើងនិងអរព្រះគុណដោយសារព្រះពរខាងវិញ្ញាណដែលឬទេ? សព្វថ្ងៃនេះមនុស្សជាច្រើនមិនបានសរសើរដល់ការមួយនេះទេ។ ពួកគេសរសើរព្រះប៉ុន្តែពួកគេមិនបានដឹងពីហេតុផលពិតប្រាកដនោះទេ។ មានតែអ្នកដែលស្គាល់ព្រះពរអស់កល្បនៅក្នុងព្រះគ្រីស្ទអាចសរសើរដំកើងការដូច្នេះ។ វាមិនមែនជាការសរសើរដំកើងដែលខ្សោយនោះទេ មិនមែននៅក្នុងការកំរើកបបូរមាត់របស់ពួកគេ ប៉ុន្តែជាការសរសើរដំកើងគួរឲ្យកោតស្ញប់ស្ញែងចេញពីព្រលឹងយ៉ាងជ្រាលជ្រៅទៅកាន់ទីដ៏ខ្ពស់។ យើងគួរតែស្តារឡើងវិញនូវបទភ្លេងស្ថានសួគ៌ដែលយើងបានបាត់បង់នៅក្នុងជីវិតដូចជាការអធិស្ឋាននិងការសរសើរដំកើងនៃចាស់ទុំទាំង២៤នាក់នៅក្នុងវិវរណៈ។

រូបភាព

មេរៀនទី 3

## **អាថ៌កំបាំងនៃក្រុមជំនុំ**

អេភេសូ 2:1-22

"ដ្បិតយើងរាល់គ្នាជាស្នាព្រះហស្ត ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវសំរាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម។" (អេភេសូ 2:10)

**មេរៀនទី3**
**អាថ៌កំបាំងនៃក្រុមជំនុំ**

**គោលគំនិត៖**

1. រូបភាពទាំងមូល- អាថ៌កំបាំងដែលក្រុមជំនុំសញ្ជឹងគិតអស់កល្បតទៅគឺជាការប្រោសលោះរបស់ព្រះជាម្ចាស់។
2. មនុស្សខ្មៅនៅផ្នែកខាងឆ្វេង- នាមកាលពីអតីតកាលដែលគ្មានព្រះ ដែលរស់នៅខាងសាច់ឈាម ដេញតាមទម្លាប់របស់លោកិយ ទៅអាមួយដែលវាគ្រប់គ្រងលើអំណាចអាកាស។
3. បុរសពីរនាក់នៅផ្នែកខាងស្តាំ – ពួកយូដានិងពួកសាសន៍ដទៃដែលបានសង្គ្រោះចេញពីអំពើបាប។
4. មកុដដែលមនុស្សពីរនាក់ពាក់ – កិត្តិនាមនៅស្ថានសួគ៌ដែលអ្នកដែលបានសង្គ្រោះទទួលបាន។
5. សញ្ញាភ្លេងដែលមនុស្សពីរនាក់កាន់គ្នាទៅវិញទៅមក - គឺជាជញ្ជាំងចន្លោះរវាងពួកយូដានិងពួកសាសន៍ដទៃត្រូវបានបំបែកហើយបានក្លាយជាមនុស្សថ្មី។
6. ឈើឆ្កាងដែលដាក់នៅចន្លោះជ្រលងភ្នំ - ការប្រោសលោះរបស់ក្រុមជំនុំត្រូវបានពឹងទៅលើការសុគតនិងការរស់ឡើងវិញនៃព្រះរាជបុត្រាគឺព្រះយេស៊ូវ។

# មេរៀនទី3
# អាថ៌កំបាំងនៃក្រុមជំនុំ

I. អត្ថបទ៖ អេភេសូ 2:1-22

2. ខគម្ពីរសំខាន់៖ អេភេសូ 2:10

3. ការណែនាំ៖

អាថ៌កំបាំងស្ថានសួគ៌ដែលក្រុមជំនុំគួរតែចងចាំនោះជាសេចក្តីប្រោសលោះរបស់ព្រះ។ អាថ៌កំបាំងនេះមិនបានបង្ហាញដល់អ្នកណាឡើយ ប៉ុន្តែទៅកាន់តែក្រុមជំនុំដែលទទួលបានការសង្គ្រោះប៉ុណ្ណោះ។ សាវ័កប៉ូលជាអ្នកដែលស្គាល់នូវអាថ៌កំបាំងនេះ សរសើរដំកើងដល់ព្រះនូវសេចក្តីស្រឡាញ់ដ៏ធំរបស់ទ្រង់ ហើយបានពន្យល់នូវការផ្លាស់ប្រែនៃកិត្តិនាមដែលអ្នកត្រូវបានប្រោសលោះមានដោយលំអិត ដើម្បីនឹងប្រាប់ពួកគេនូវសេចក្តីពិត។ គាត់បានរៀបរាប់ពីសេចក្តីប្រោសលោះដែលក្រុមជំនុំភាពសុក្រិត្យយ៉ាងជ្រាលជ្រៅនៅក្នុងជំពូកមួយ ហើយនៅក្នុងជំពូកពីរមានប្រតិកម្មទៅលើស្នូលនៃសេចក្តីប្រោសលោះ។ នៅទីនេះអេភេសូ 1:7 គាត់បាននិយាយអំពីអត្ថន័យនៃសេចក្តីប្រោសលោះតាមលំដាប់លំដោយ។ ស្នូលនៃសេចក្តីសង្គ្រោះគឺដើម្បីនឹងធ្វើឲ្យមនុស្សម្នាក់ស្លាប់ខាងសេចក្តីពុករលួយនិងអំពើបាប ឲ្យគេបានរស់ឡើងវិញ។ (2:1) អាចនិយាយបានម្យ៉ាងទៀតថា អ្នកដែលបានស្លាប់នៅក្នុងអតីតកាលដោយសារអំពើបាប ត្រូវបានរស់ឡើងវិញដោយការសុគតរបស់ព្រះគ្រីស្ទ។ យើងអាចរៀនពីនាមរបស់ក្រុមជំនុំត្រូវបានផ្លាស់ប្តូរពីមុននិងបន្ទាប់ពីការត្រាស់ហៅរបស់ព្រះនៅក្នុងជំពូកពីរ។

4. ការអធិប្បាយ៖

1. កិត្តិនាមនៃពេលអតីតកាល (1-3, 11-12)

(1) សាវ័កបានអះអាងពីនាមរបស់មនុស្សមានបាបមុនសេចក្តីសង្គ្រោះផ្ទាល់ខ្លួនដែលគេត្រូវបានចងដោយច្រវ៉ាក់៦ជាន់។

1) ជីវិតដែលដេញតាមអាមួយដែលគ្រប់គ្រងលើអាកាស - អាមួយដែលគ្រប់គ្រង់លើអាកាសមានន័យថា "សាតាំង" និង "អារក្ស"។ ហើយពាក្យ "អាកាស" ចង្អុលទៅកាន់ក្រុមនៃសកម្មភាពគ្រប់ការទាំងអស់ ដែលជាមេឃដែលមើលមិនឃើញនិងមើលឃើញ។ មនុស្សមួយចំនួននិយាយថាអាមួយដែលគ្រប់គ្រងលើអាកាសចង្អុលទៅលើ "តារាផ្កាយព្រឹក" នៅក្នុងអេសាយ 14:12, ប៉ុន្តែនៅក្នុងបរិបទ វាជាការទូទៅនៅក្នុងការបកប្រែមួយនោះថាជាបាប៊ីឡូន។ ប៉ុន្តែគោលលិទ្ធិនៃទង្វើរបស់បាប៊ីឡូនបានចង្អុលទៅកាន់សាតាំង។ ជាងនោះទៀតយើងយល់ថាយើងអាចមើលឃើញទេវតាត្រូវទទួលបណ្តាសារ ពីព្រោះគេមិនបានរក្សាដំណែងដើមរបស់ខ្លួន (យូដាស 1:6) នៅក្រោមការអនុញ្ញាតរបស់ព្រះជាបណ្តោះអាសន្ន។ ដូច្នេះសាវ័កយ៉ូហានបានជម្រុញឲ្យអ្នកមិនគួរស្រឡាញ់លោកិយនិងគ្រប់របស់ទាំងអស់ដែលនៅក្នុងនោះផង (១យ៉ូហាន2:15-16)។ ដោយសារការនេះហើយដែលសាតាំងដែលជាអ្នកនិពន្ធបានល្បួងអ័ដាមនិងអេវ៉ានៅក្នុងសួនច្បារអេដែនគ្រប់គ្រងដោយវិញ្ញាណអាក្រក់ (សាតាំង) ក្រុមជំនុំគួរតែវាយប្រហារតបទាស់នឹងពួកវា។ ពិតណាស់ ពួកយើងរស់នៅក្នុងអតីតកាលដូចជាទង្វើទាំងនេះ ដែលយើងបានក្លាយជាអ្នកបំរើរបស់វាដែលបានទាស់ប្រឆាំងនឹងព្រះអម្ចាស់រហូត ពីព្រោះយើងខ្លាចសេចក្តីស្លាប់ដែលជាឧបករណ៍សំខាន់របស់វា។

2) មនុស្សដែលត្រូវស្លាប់ដោយកំហុសនិងអំពើបាប – "កំហុស និង អំពើបាប" ដែលជាឧបករណ៍ចម្បងរបស់សាតាំង បានដាក់យើងទៅក្នុងសេចក្តីស្លាប់។ នៅទីនេះសេចក្តីស្លាប់មានន័យថាមិនមែនជាទីបញ្ចប់នៃរបស់មានជីវិតនោះឡើយ ប៉ុន្តែជាសភាពដែលមិនបានតភ្ជាប់ជាមួយនឹងការប្រកបជាមួយនឹងព្រះអម្ចាស់ ដែលជាការ

ដាច់ចេញពីព្រះ នោះជាសេចក្ដីស្លាប់។ វាត្រូវបានហៅថាការស្លាប់ខាងវិញ្ញាណ។ ការស្លាប់ខាងវិញ្ញាណមានការទាក់ទងនឹងការស្លាប់ខាងរូបកាយនិងការស្លាប់ដ៏អស់កល្ប។

3) មនុស្សដែលដើរតាមទម្លាប់របស់លោកិយ- ខគម្ពីរនេះបានបញ្ជាក់ថាសេចក្ដីស្លាប់មិនមែនជាសេចក្ដីវិនាសទាំងស្រុងនៃរូបសាច់នោះឡើយ។ សភាពនៃការស្លាប់ខាងវិញ្ញាណជាសភាពស្មោះត្រង់ទៅកាន់ជីវិតធម្មជាតិ មិនបានដើរតាមព្រះ និងសេចក្ដីសុចរិតរបស់ទ្រង់។ ពួកគេមាននាមដែលបំរើវាដូចជាអ្នកបំរើ ពីព្រោះសេចក្ដីភ័យខ្លាចនូវសេចក្ដីស្លាប់។ គំរូ គោលបំណង និង សេចក្ដីអំណរនៃគ្រប់របស់ទាំងអស់ចេញមកពីលោកិយ។ ពួកគេត្រូវបានធ្លាក់ចុះទៅក្នុងភាពល្ងង់ខ្លៅខាងវិញ្ញាណ ដែលរស់នៅដោយមិនស្គាល់បច្ចុប្បន្នកាល អតីកាល និងអនាគតកាល ដោយអនុវត្តការយល់ឃើញបែបរបស់លោកិយ។

4) មនុស្សដែលមិនស្ដាប់បង្គាប់ - រូបភាពមួយផ្សេងទៀតគឺជាមនុស្សដែលដើរតាមអំណាចរបសៀលោកិយ។ វាមានន័យថាគេបានចាកចេញពីព្រះហើយបានតាំងខ្លួនទៅព្រះដទៃទៀត ហើយដើរតាមវាដូចជាព្រះដោយព្យាយាម។ គេដើរតាមនៅក្នុងរូបភាពដូចគ្នានៃជីវិតដែលមិនស្ដាប់បង្គាប់របស់អ័ដាមដោយលំអិត។

5) មនុស្សដែលដើរតាមបំណងប្រាថ្នាខាងសាច់ឈាម - បំណងប្រាថ្នាដែលនាំមកនូវការប្រព្រឹត្តដោយមិនស្ដាប់បង្គាប់បានបដិសេធនូវការខាងវិញ្ញាណ ហើយបានក្លាយជាមនុស្សដែលរស់នៅខាងសាច់ឈាម។ នៅទីនេះ "សាច់ឈាម" មានន័យថា "សេចក្ដីត្រូវការខាងរូបសាច់" "មនុស្សចាស់" ជាដើម។ ដែលត្រូវបានតាំងនៅក្នុងមនុស្ស រោងចក្រដែលផលិតអំពើបាប នោះជាការបញ្ចូលលក្ខណៈនៃអំពើបាប។ ជាទូទៅប្រសិនបើមនុស្សបោះបង់នូវសេចក្ដីចង់បាន នោះមនុស្សមិនអាចរស់នៅបានឡើយ។ គ្រីស្ទានមិនរស់នៅក្នុងសភាពដែលដាច់ចេញសេចក្ដីប្រាថ្នានិង លក្ខណៈនោះឡើយ។ មានតែវត្ថុបំណងដែលតាមប៉ុណ្ណោះដែលខុសគ្នា។ វាជាជីវិតនៃ

មនុស្សមានបាបដែលមិនបានដើរតាមភាពបរិសុទ្ធ ប៉ុន្តែដើរតាមបំណងប្រាថ្នាយ៉ាងឆេះឆួលនៃអំពើបាប។ ពីសេចក្តីប្រាថ្នារបស់ព្រះអម្ចាស់នោះឡើយ។

6) ធម្មជាតិរបស់កូននៃសេចក្តីក្រោធ- គេត្រូវបានវាយតម្លៃថាជាមនុស្សមានបាបដោយព្រះនាគ្រាចុងក្រោយ។ ពីព្រោះភាពមិនបរិសុទ្ធរបស់ពួកគេ បើទោះជាគេស្គាល់ព្រះអម្ចាស់ ប៉ុន្តែមិនបានថ្វាយសិរីរុងរឿងនិងការអរគុណដល់ទ្រង់ ពួកគេរស់នៅក្រោមការកាត់ទោសដោយសេចក្តីសុចរិតរបស់ព្រះ ដូចជាត្រូវកាត់ទោសនិងត្រូវបណ្តាសារ។ នេះជានាមដែលនៅក្នុងអតីតកាល ហើយសភាពដូចគ្នានោះរបស់គ្រីស្ទានគ្រប់គ្នា។

សង្ខេបមក គេរស់នៅដោយបំរើសាតាំង ជាជីវិតដែលមើលងាយដល់ព្រះបន្ទូលរបស់ព្រះ ជាជីវិតដែលកាត់ផ្តាច់នូវការទំនាក់ទំនងខាងវិញ្ញាណ ជីវិតដែលមិនស្របច្បាប់ដែលមើលងាយនូវរបៀបរបបខាងវិញ្ញាណ ជីវិតដែលទទួលស្គាល់នូវទម្លាប់លោកិយធ្វើជាគំរូទាំងស្រុងរបស់គេ ជីវិតដែលប្រឆាំងនឹងព្រះហឫទ័យរបស់ព្រះជាមួយនឹងបំណងរបស់គេផ្ទាល់។ គេជាម្នាក់ទោរទៅរកសេចក្តីលោភលន់របស់គេដោយសេចក្តីព្យាយាម មានភាពអាត្មានិយមជ្រុលហួស ជាអ្នកដែលអាចនឹងឆក់យកអ្វីមួយពីអ្នកជិតខាងខ្លួន ទាស់ប្រឆាំងនឹងព្រះបន្ទូលរបស់ព្រះ។ ជាម្នាក់ដែលរូបសាច់ខ្លួនគ្រប់គ្រងលើព្រលឹង ដែលជាអ្នកដែលត្រូវបានធ្លាក់ចុះនៅក្នុងភាពបណ្តោយៗ ជាអ្នកដែលអាចទាញយកនូវសំភារៈបានល្អទៅបំពេញបំណងរបស់គេជាមួយគ្រប់វិធីទាំងអស់ ហើយឧបករណ៍ ភាជនៈ និង កន្លែងស្នាក់នៅរបស់សាតាំង ដែលត្រូវបានប្រើដើម្បីឲ្យកាន់តែជំនាញខាងការបោកប្រាស់។ ឱអ្នកជាមនុស្សនៃសេចក្តីក្រោធរបស់ព្រះអើយ!

(2) ជីវិតដែលគ្មានព្រះ (11-12)

សាវ័កបានបង្ហាញនូវភាពពិតនៃសេចក្ដីពិតទូទៅរបស់មនុស្សមានបាបនិងបន្ទាប់មកបានបង្ហាញពីរូបភាពដែល ជាការពិតត្រូវបានហ៊ុំព័ទ្ធដោយគម្រប៥ជាន់។

1) នៅក្នុងរូបសាច់ ពួកសាសន៍ដទៃ និង "ការមិនកាត់ស្បែក" - នៅពេលពួកគេប្រៀបធៀបជាមួយនឹងពួកអ៊ីស្រាអែល ពួកគេគ្រាន់តែជាសាសន៍ដទៃដែលគ្មាននូវការកាត់ស្បែក។ ពួកសាសន៍ដទៃមិនមានទំនាក់ទំនងទៅនឹងព្រះគុណរបស់ព្រះឡើយដោយការប្រៀងទុកមក។ បើទោះជាអ្នកមិនមែនជាសាសន៍យូដាក៏ដោយ អ្នកដែលមិនមានស្លាក់ស្នាមនៃការកាត់ស្បែក គឺដែលត្រូវបានកាត់ចេញ ហើយសាសន៍ដទៃដែលមិនទាក់ទងគ្នានោះទៅកាន់ការតាំងសញ្ញាវិញ។

2) មនុស្សខាងក្រៅដែលនៅក្រៅព្រះគ្រីស្ទ- ព្រះគ្រីស្ទដែលបានប្រសូត្រទៅជាសាសន៍យូដាជាដំបូងបង្អោះនៅពេលយាងមកលើផែនដីគឺដើម្បីនឹងសង្គ្រោះរាស្ត្ររបស់ទ្រង់ផ្ទាល់ (យ៉ូហាន 1:11)។

3) ជាមនុស្សដែលរស់នៅកន្លែងខាងក្រៅអ៊ីស្រាអែល - គេមិនបានទាក់ទងទៅនឹងការតាំងសញ្ញារបស់អ័ប្រាហាំឬស្ដេចដាវីឌនោះទេ។

4) មនុស្សខាងក្រៅនៃការតាំងសញ្ញា- វត្ថុបំណងនៃការតាំងសញ្ញានៃព្រះគុណសំខាន់នោះផ្ដោតលើតែពួកអ៊ីស្រាអែល។ ហើយវាត្រូវបានផ្លាស់ប្ដូរទៅកាន់ពួកអ៊ីស្រាអែល ពីព្រោះពួកគេបានបដិសេធព្រះគ្រីស្ទ។ ក្រុមជំនុះអេភេសូមិនមានទាក់ទងទៅនឹងការតាំងសញ្ញាឡើយ។

5) អ្នកដែលមិនមានសង្ឃឹមនៅក្នុងលោកិយ - នៅក្នុងលោកិយនេះពួកគេមិនមានជាប់ទាក់ទងទៅនឹងព្រះគុណរបស់ព្រះឡើយ ហើយគ្មានសង្ឃឹមតែម្ដង។ ក្រុមជំនុំតូចនៅក្នុងមជ្ឈមណ្ឌលនៃក្រុមជំនុំអេភេសូមិនដែលមានព្រះនៅក្នុងជីវិតនៅអតីតកាលរបស់គេឡើយ។ ផលដែលពួកគេមិនបានមានព្រះ គំរូពេញលេញរបស់ពួកគេត្រូវបានជំនួសបល័ង្គព្រះ។ ជាលទ្ធផលជីវិតរបស់ពួកគេត្រូវបានអង្គុយនៅក្រោមស្រមោលនៃសេចក្ដីងងឹតនិងជាគោលបំណងនៃសេចក្ដីក្រោធរបស់ព្រះ។ បើទោះជាពួកគេហាក់ដូចជាមានសង្ឃឹម អំណររីករាយ និង សុភមង្គលនៅក្នុងពួក

គេក៏ដោយ ការពិតនោះមានតែការធ្លាក់ទឹកចិត្តនិងការទួញសោក ហើយនឹងអ័ភមង្គលប៉ុណ្ណោះដែលកំពុងតែរងចាំពួកគេ។ ពីព្រោះពួកគេបានបាត់បង់ព្រះអម្ចាស់ដែលជាប្រភពនៃព្រះពរខាងវិញ្ញាណ (រ៉ូម 1:18-32)។

2. កិត្តិនាមនាជីវិតសព្វថ្ងៃ (8-10, 13-22)

អ្នកមានបាបដែលមិនមានសង្ឃឹមនៅអតីតកាល ពីព្រោះគេត្រូវបានបោះបង់ចោលត្រូវបានផ្លាស់ប្រែទៅជាមនុស្សមានអត្តសញ្ញាណថ្មី។ សាវ័កបានបញ្ជាក់ថែមទៀតពីសេចក្ដីពិតពីរពេលដែលគាត់យល់នូវអត្តសញ្ញាណរបស់ពួកគេ។

1) ពួកគេបានក្លាយជាមនុស្សថ្មី (8-10) "ដ្បិតគឺដោយព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ។ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន។ ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវសំរាប់ការល្អដែលព្រះបានរៀបចំទុកជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម។" "បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅ មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ" (២ កូរិនថូស 5:17)។ វាមិនសំដៅទៅលើការប្រែជាថ្មី ប៉ុន្តែជាការផ្លាស់ប្រែទាំងស្រុងនៃអត្តសញ្ញាណ។ វាជាការបង្កបង្កើតដែលដែលពេញលេញជាជាងការបង្កបង្កើតនៅក្នុងលោកុប្បត្តិ។ បើទោះជាជីវិតនៅក្នុងលោកិយនេះក៏ដោយ តែពួកគេរស់នៅដោយពឹងលើស្ថានសួគ៌។ (8-10)

តើអ្វីទៅជាគោលបំណង? ដូចនៅក្នុងខ 7 និង 10 បាននិយាយថា អ្នកដែលកើតនៅក្នុងព្រះគ្រីស្ទគួរតែសំដែងនូវសេចក្ដីសប្បុរសជាបរិបូររបស់ព្រះនៅក្នុងលោកិយនេះ។ ដូច្នេះមនុស្សគួរតែមើលទៅកាន់រូបឆ្លុះរបស់ព្រះអម្ចាស់តាមរយៈខ្ញុំ។

(2) ពួកគេបានក្លាយជាសមាជិកនៃក្រុមជំនុំ។ (13-22) ដោយផ្ទាល់ខ្លួនម្នាក់ៗអ្នកដែលត្រូវបានបង្កើតមកមានទំនាក់ទំនងទៅនឹងព្រះគ្រីស្ទយ៉ាងជ្រៀលជ្រៅ។

ប្រសិនបើវាត្រូវបានប្រៀបធៀបទៅនឹងរូបកាយ គេត្រូវបានក្លាយជាផ្នែកមួយរបស់ព្រះគ្រីស្ទ ហើយប្រសិនបើយើងប្រៀបធៀបគេទៅនឹងក្រុមគ្រួសារ គេជាក្រុមគ្រួសាររបស់ព្រះ ហើយប្រសិនបើគេត្រូវបានប្រៀបធៀបទៅនឹងសញ្ញាតិ គេជារាស្ត្ររបស់អាណាចក្រព្រះ។ ដូច្នេះក្រុមជំនុំជាហ្វូងមនុស្សដែលត្រូវបានទាញយកចេញពីលោកិយមក ( ekklesia), ចំណែករបស់ព្រះគ្រីស្ទ ( Kerk)។ នៅទីនេះ សាវ័កបានគិតថាក្រុមជំនុំជាផ្នែកនៃក្រុមជំនុំសកល ហើយបានអះអាងថាគ្រប់មនុស្សទាំងអស់ដែលនៅក្នុងព្រះគ្រីស្ទក្លាយទៅជាភាពតែមួយ។ នៅក្នុងជំនាន់ដើមនៅក្នុងការទូលអង្វររបស់មហាសង្ឃដែលព្រះអម្ចាស់បានអធិស្ឋាន។ ការសំណូមត្រូវបានសម្គាល់ជាប្រាកដ។ បើទោះជាអត្ថបទបានបង្ហាញពីវត្ថុបំណងនៃក្រុមជំនុំអេភេសូក្រុមជំនុំបានមើលឃើញប៉ូលរាប់បញ្ចូលក្រុមជំនុំនៅវាលរហោស្ថាននៅក្នុងសញ្ញាចាស់ ក្រុមជំនុំយូដានៅក្នុងសញ្ញាថ្មី ពួកជំនុំសាសន៍ដទៃ និងក្រុមជំនុំអាមេរិក កូរ៉េខាងត្បូង និង គ្រប់ទាំងក្រុមជំនុំលើសកលលោកដែលមាននូវអ្វីដែលប្លែកគ្នាច្រើននិងរួបរួមគ្នា។

មិនមានអ្នកណាអាចបំផ្លាញជញ្ជាំងរវាងពួកយូដានិងសាសន៍ដទៃបានឡើយដោយសារវាមានភាពរឹងមាំខ្លាំង។ ទោះជាយ៉ាងណាគ្រួសាររបស់លោកកូនីលាសបានអញ្ជើញពេត្រុសមកហើយបានស្តាប់ព្រះបន្ទូលរបស់ព្រះ ព្រឹត្តិការណ៍នៃថ្ងៃបុណ្យទីហាសិបបានកើតឡើងនៅក្នុងពួកគេម្តងទៀត (កិច្ចការ 10:2-8) ហើយតាមរយៈការផ្សាយដំណឹងល្អរបស់គូរកនរបស់ប៉ូល ជញ្ជាំងដែលរឹងមាំរវាងសាសន៍យូដានិងសាសន៍ដទៃត្រូវបានបំផ្លាញ ហើយទ្វានៃដំណឹងល្អទៅកាន់សាសន៍ដទៃត្រូវបានបើក។ ពួកគេបានបញ្ជាក់ថាព្រះបានបំផ្លាញនូវរបាំងសំរាប់ទ្រង់ដោយមានចេតនា។ ការបំផ្លាញនោះគឺជាការអស្ចារ្យលើអស់ទាំងការអស្ចារ្យ។ នេះគឺជាក្រុមជំនុំ។ ដូច្នេះប៉ូលបានបង្ហាញថាក្រុមជំនុំជាមនុស្សថ្មី ឬជាព្រះវិហារ 2:15 និង2:20។

3. វិធីសាស្ត្រទីបីនៃការប្រោសលោះ (4-9, 13, 16)

ដូចកាលដើមដំបូងឡើយនៃផ្ទៃមេឃនិងផែនដី ការផ្លាស់ប្រែនៃនាមត្រូវបាន កំណត់ទៅមនុស្សដែលនៅក្នុងព្រះគ្រីស្ទជាប្រាកដ សាវ័កបានរៀបរាប់ពីកត្តាជម្រុញនៃសេចក្តីប្រោសលោះ និង គោលការណ៍នៃសេចក្តីប្រោសលោះ។

(1) កំលាំងចលករនៃការប្រោសលោះ - ពីព្រោះសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះអម្ចាស់នោះជាកំលាំងជម្រុញនៃសេចក្តីប្រោសលោះ។ ពួកគេគ្មានហេតុផលណាមួយដែលត្រូវបានសង្គ្រោះដោយព្រះគុណរបស់ព្រះនោះឡើយ។ ដូច្នេះគ្រីស្ទានមិនមានការខិតខំដោយខ្លួនឯងដើម្បីទទួលបានការសង្គ្រោះទេ។ ពួកគេបានជំពាក់តែទៅកាន់ព្រះប៉ុណ្ណោះ។ ព្រះដែលស្រឡាញ់ដល់ពួកគេដោយគ្មានហេតុផល ពួកគេត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់ពួកគេ។ដូច្នេះអ្នកជឿមានមោទនភាពលើព្រះគុណរបស់ព្រះ។
(2) គោលការណ៍នៃសេចក្តីប្រោសលោះ - សេចក្តីស្រឡាញ់ត្រូវបានបើកសំដែងតាមរយៈឈើឆ្កាង ដែលជាសញ្ញានៃការសុគតរបស់ទ្រង់ (រ៉ូម 5:5)។ ទង្វើដែលជាគ្រឹះនៃសេចក្តីសង្គ្រោះគឺជាការសុគតរបស់ព្រះអម្ចាស់។ ដោយសារតែការសុគតរបស់ទ្រង់ ការរស់ពីស្លាប់ឡើងវិញរបស់ទ្រង់ និង ការយាងឡើងមាននូវអត្ថន័យដ៏ពិត។ ការសុគតរបស់ទ្រង់គឺជាការជំនួសនិងជាការបង់ថ្លៃលោះ ដែលត្រូវបានបង់ថ្លៃដោយឈ្នួលរបស់យើង។ ការនេះត្រូវបានសំរេចដោយការរួបរួមយ៉ាងអស្ចារ្យ។ ការសុគតរបស់ទ្រង់គឺជាការស្លាប់តែមួយរបស់ក្រុមជំនុំ។ ការរស់ឡើងវិញរបស់ទ្រង់ជាការរស់ឡើងវិញតែមួយរបស់ក្រុមជំនុំ ហើយការយាងឡើងទៅរបស់ទ្រង់ជាការយាងឡើងតែមួយរបស់ក្រុមជំនុំ (5-6)។ ដូច្នេះយើងអាចទៅជិតបល្ល័ង្ករបស់ព្រះដោយមានទំនុកចិតដោយពឹងលើការសគុណរបស់ទ្រង់។ ពីព្រោះសគុណនោះខ្លាំងណាស់ យើងមាននូវសុវត្ថិភាពលើសេចក្តីសង្គ្រោះយ៉ាងពេញលេញអស់កល្បជានិច្ច។ ជីវិតនៃអ្នកដែលពឹងលើសគុណនៃសេចក្តីសុគត នឹង រស់នៅដោយចេស្តានៃស្ថានសួគ៌នៅលើផែនដីនេះ។

ចូរក្រលេកមើលទៅខ 11 , ពាក្យថា "ដូច្នេះចូរពិចារណា" ខគម្ពីរនេះបានលើកឡើងថាក្រុមជំនុំគួរតែរស់នៅចេញពីសភាពដែលនៅក្នុងអតីតកាល គេអាចស្វែងរកឥរិយាបថដែលត្រឹមត្រូវនាពេលបច្ចុប្បន្ននិងទស្សនៈនាពេលអនាគត។ ជីវិតគ្រីស្ទានមិនចងចាំនូវឈ្មោះពីអតីតកាលឡើយ ហើយចងចាំអតីតកាលនិងរក្សាព្រះគុណនាពេលបច្ចុប្បន្ន។ ការសញ្ជឹងគិតនេះផ្តល់មកនូវការកោតសរសើរដល់យើង ហើយធ្វើឲ្យយើងរស់នៅក្នុងការបន្ទាបខ្លួននិងភាពស្មោះត្រង់។

សរុបសេចក្តី៖ តើខ្ញុំស្គាល់ពីអាថ៌កំបាំងនៃក្រុមជំនុំឬទេ? ជារៀងរាល់ថ្ងៃតើខ្ញុំសញ្ជឹងគិតពីសេចក្តីពិតនេះឬទេ? តើយើងមានការផ្លាស់ប្រែដោយលំអិតនៅក្នុងយើងដែរទេ? តើយើងអាចនិយាយថាយើងបានក្លាយជាមនុស្សថ្មីបានទេ? ជីវិតនៃអ្នកដែលត្រូវបានបង្កើតឡើងវិញរស់នៅលើផែនដីដោយពឹងលើស្ថានសួគ៌។ ដូច្នេះប្រសិនបើយើងត្រូវបានកាត់ចេញពីបន្ទាត់នៃព្រះគុណនេះ យើងមិនអាចគេចពីការរស់នៅដោយខ្លួនឯងនោះទេ។ យើងគួរតែសរសើរដំកើងដល់ព្រះអម្ចាស់យ៉ាងខ្លាំង ដោយការយល់ពីអាថ៌កំបាំងនៃសេចក្តីប្រោសលោះ។ អ្នកដែលនៅក្នុងអតីតកាល រស់នៅក្នុងការបាក់ទឹកចិត្ត និងការខកចិត្ត ប៉ុន្តែប្រសិនបើឋានៈនាពេលបច្ចុប្បន្ន គាត់សញ្ជឹងគិតពីពេលអតីតកាល ហើយយល់ពីទង្វើពេញដោយព្រះគុណរបស់ព្រះដែលមានដោយស្ម័គ្រចិត្តដែលលះបង់នឹងព្យាយាមតភ្ជាប់ទៅនឹងព្រះ។ តើជញ្ជាំងរបស់យើងត្រូវបំផ្លាញហើយឬនៅ? ដូចជាជញ្ជាំងដែលបាំងចន្លោះរវាងពួកយូដានិងពួកសាសន៍ដទៃត្រូវបានបំផ្លាញ គ្រប់ជញ្ជាំងទាំងអស់ត្រូវតែបានបំផ្លាញនៅក្នុងព្រះគ្រីស្ទ។

រូបភាព

មេរៀនទី 4

# អ្នកធ្វើការរបស់ក្រុមជំនុំ

អេភេសូ 3:1-21

"ហើយក្នុងទ្រង់ យើងរាល់គ្នាក៏មានសេចក្តីក្លាហាន និងច្បាប់ចូលដោយទុកចិត្ត ដោយសារសេចក្តីជំនឿជឿដល់ទ្រង់ដែរ" (អេភេសូ 3:12)

## មេរៀនទី 4
## អ្នកធ្វើការរបស់ក្រុមជំនុំ

### គោលគំនិត៖

1. ច្រវ៉ាក់សំរាប់ចងកជើងបុរសដែលលុតជង្គង់ - សាវ័កប៉ូលជម្រុញក្រុមជំនុំអេភេសូនៅក្នុងសេចក្ដីលំបាកវេទនា។
2. បុរសដែលលុតជង្គង់ចុះ– ការទូលអង្វរជាលើកទីពីររបស់សាវ័កប៉ូលទៅកាន់ព្រះអម្ចាស់។
3. ដីដ៏ធំនៅផ្នែកខាងស្ដាំ - ប៉ូលសំណូមពរដល់មនុស្សដែលនៅក្នុងក្រុមជំនុំអេភេសូឲ្យមានកំលាំងខ្លាំងឡើង។
4. រូបភាពនៃដៃពីរដែលកាន់នូវសញ្ញា - ប៉ូលអធិស្ឋានសំរាប់ផលផ្លែនៃសេចក្ដីជំនឿ។
5. រូបភាពនៃការចាប់ដៃគ្នា - ប៉ូលអធិស្ឋានសំរាប់ផលផ្លែនៃសេចក្ដីស្រឡាញ់។
6. រូបភាពទាំងមូល – អ្នកធ្វើការនៅក្នុងក្រុមជំនុំគឺជាម្នាក់ដែលមានពេញដោយសំណល់នៃសេចក្ដីវេទនានៅរូបកាយរបស់គេ។.

រូបភាព

# មេរៀនទី 4
# អ្នកធ្វើការរបស់ក្រុមជំនុំ

I. អត្ថបទ៖ អេភេសូ 3:1-21

II. ខគម្ពីរសំខាន់៖ អេភេសូ 3:12

III. សេចក្តីណែនាំ៖

នៅក្នុងផ្នែកនេះ ប៉ូលមានមោទនៈភាពចំពោះសេចក្តីពិតដែលបានក្លាយជាអ្នកធ្វើការរបស់ក្រុមជំនុំ និងបានជម្រុញផងដែរកុំឲ្យពួកគេមានសេចក្តីខ្មាស់ដោយសារសភាពដែលគាត់ជាប់គុកនោះឡើយ។ (1) អ្នកធ្វើការបំរើក្រុមជំនុំជាអ្នកធ្វើការបំរើដល់ដំណឹងល្អ។ ដំណឹងល្អនៅទីនេះត្រូវបានបង្ហាញថា "អត្ថន័យនៃព្រះគុណ" "អាថ៌កំបាំងរបស់ព្រះគ្រីស្ទ" (3). ប៉ូលបានសារភាពជាលើកដំបូងពីសេចក្តីពិតដែលថាអាថ៌កំបាំងនេះត្រូវបានបើកសំដែងដោយការបើកសំដែងនៃព្រះវិញ្ញាណបរិសុទ្ធ និងគោលបំណងដែលត្រូវបានបើកបង្ហាញ ដូចនេះដែលថ្វាយសិរីល្អដល់ព្រះដោយការប្រាប់នូវគោលបំណងនៃការបើកសំដែង សកម្មភាពនៃសេចក្តីប្រោសលោះទៅកាន់លោកិយ។ ហើយគាត់ត្រូវរងសេចក្តីវេទនានៅក្នុងការប្រកាសដំណឹងល្អសំរាប់ក្រុមជំនុំ ហើយត្រូវបានបើកសំដែងមកថាគាត់ជាអ្នកបំរើដែលស្មោះត្រង់នៃដំណឹងល្អដោយពេញដោយសំណាល់នៃសេចក្តីឈឺចាប់របស់ព្រះគ្រីស្ទ។ ក្រុមជំនុំនៃអាស៊ីមីណាដែលជាផ្នែកមួយនៃក្រុមជំនុំដោយការប្រកាសដែលត្រូវការជីវិតដែលស្គាល់ពីអាថ៌កំបាំងនៃក្រុមជំនុំ។ ដូច្នេះប៉ូលបានសូមដោយស្មោះត្រង់ដល់ពួកគេ។ នេះគឺជាសេចក្តីអធិស្ឋានលើកទីពីរដែលត្រូវបានបើកសំដែងដល់ក្រុមជំនុំអេភេសូ។ ការអធិស្ឋាននេះបង្ហាញពីជីវិតនៃការបើកសំដែងជាសេចក្តីរងទុក្ខវេទនានៃជីវិតដែលបើកសំដែង។

IV. សេចក្តីអធិប្បាយ៖

## 1. ប៉ូលអ្នកបំរើនៃដំណឹងល្អ (1-13)

ប៉ូលនៅក្នុងសេចក្តីលំបាកវេទនា (1,13)- សេចក្តីរងទុក្ខវេទនាធ្វើឲ្យគ្រីស្ទានធ្វើការ និង បង្កើតផលផ្លែ។ ដូចនេះអ្នកសរសេរទំនុកដំកើងបានសរសើរថា "កាលមុនដែលទូលបង្គំកើតទុក្ខព្រួយ នោះទូលបង្គំបានវង្វេងទៅ តែឥឡូវនេះ ទូលបង្គំកាន់តាមព្រះបន្ទូលទ្រង់វិញ" "ការដែលទូលបង្គំកើតមានទុក្ខព្រួយ នោះគឺជាប្រយោជន៍ដល់ទូលបង្គំហើយ ដើម្បីឲ្យទូលបង្គំបានរៀនយកបញ្ញាត្តរបស់ទ្រង់" (ទំនុកដំកើង 119: 67, 71)។ សាស្តាដែលជាកណ្ឌគម្ពីរស្តេចសាឡូម៉ូនបានសរសេរនៅគ្រាចុងក្រោយនៃជីវិតរបស់គាត់បានយល់ព្រមដល់ប្រាជ្ញាដ៏អាថ៌កំបាំងរបស់ព្រះ ដែលបានអនុញ្ញាត្តយើងឲ្យមានទាំងគ្រាបញ្ហា និង គ្រាដែលបានចំរុងចំរើន។ (សាស្តា 7:14 យ៉ាកុប 5:13)។ ហើយយ៉ាកុបបានបើកសំដែងពីហេតុផលដែលយើងគួរតែពេញចិត្តនូវពេលដែលយើងជួបគ្រាមានបញ្ហា (យ៉ាកុប 1:2-3) ដោយសារបញ្ហាបង្វឹកនូវការស៊ូទ្រាំ ហើយស៊ូទ្រាំបង្កើតនូវសេចក្តីសង្ឃឹម (រ៉ូម 5:3-4)។

តើអ្វីទៅជាដំណឹងល្អ ដែលជាអាថ៌កំបាំងនៃក្រុមជំនុំ?

(1) ប៉ូលជាអ្នកដែលបានរងទុក្ខវេទនាដោយសារដំណឹងល្អរបស់ព្រះគ្រីស្ទបានកំសាន្តចិត្តដល់ក្រុមជំនុំអេភេសូ ដោយសារសេចក្តីទុក្ខលំបាករបស់គាត់។ "ហេតុនោះបានជាខ្ញុំអង្វរអ្នករាល់គ្នា កុំឲ្យរសាយចិត្តដោយការដែលខ្ញុំរងទុក្ខលំបាកជាការដែលមានប្រយោជន៍ដល់អ្នករាល់គ្នានោះឡើយ ដ្បិតការនោះជាសិរីល្អដល់អ្នករាល់គ្នាទេ" (13)។ ហេតុដែលគាត់កំសាន្តចិត្តដល់អ្នកដទៃ នោះគឺដើម្បីនឹងទទួលបាននូវសេចក្តីអំណរយ៉ាងខ្លាំងដោយស្គាល់នូវដំណឹងល្អ។ គាត់អាចទទួលនូវសេចក្តីទុក្ខលំបាករបស់គាត់ជាក់ស្តែងសំរាប់ព្រះគ្រីស្ទ ពីព្រោះគាត់យល់ពីព្រះគុណរបស់ព្រះដែលមិនអាចវាស់បាននាពេលបច្ចុប្បន្នដោយសេចក្តីអរគុណ។(7)

(2) តើអ្វីទៅជាដំណឹងល្អដែលធ្វើឲ្យប៉ូលក្លាយជាអ្នកបំរើនៃដំណឹងល្អ? ដូចដែលគាត់បានបង្ហាញនៅក្នុងជំពូក 1-2, សាវ័កប៉ូលនិយាយម្តងហើយម្តងទៀត។ នៅទីនេះ វាបានបង្ហាញថា "ការគ្រប់គ្រងនៃសេចក្តីអាថិកំបាំង" (9) ឬ "អាថិកំបាំងរបស់ព្រះគ្រីស្ទ" (4)។ ការគ្រប់គ្រងនៃអាថិកំបាំងមានន័យថា ទង្វើពេញដោយព្រះគុណរបស់ព្រះ ជាអង្គដែលបានផ្តល់មកដោយមិនមានលក្ខខណ្ឌដែលជា បំណងរបស់ព្រះដែលព្រះត្រៃឯកបានគ្រោងទុកកាលពីដើមដំបូងមកម្ល៉េះដោយរាប់បញ្ចូលទាំងពួកសាសន៍ដទៃផងដែរ។ ហើយអាថិកំបាំងនៃព្រះគ្រីស្ទជាសេចក្តីពិតដែលលាក់ទុករហូតដល់ព្រះគ្រីស្ទនឹងត្រូវបានបើកសំដែងដែលបានរៀបទុក។ ដូច្នេះដំណឹងល្អមិនបានបើកសំដែងនូវការសិក្សារបស់មនុស្ស ប៉ុន្តែបានយល់ដោយសារព្រះវិញ្ញាណរបស់ព្រះ ដែលជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ (5)

ហេតុអ្វីបានជាព្រះទ្រង់ធ្វើឲ្យពួកគេស្គាល់ដំណឹងល្អ? ពីព្រោះព្រះទ្រង់ចង់ឲ្យព្រះគុណដ៏ហូរហៀររបស់ទ្រង់បានប្រាប់ទៅដល់មនុស្សលោកទាំងអស់(8)។ នៅក្នុងអត្ថន័យដូច្នេះក្រុមជំនុំគឺជាភ្នាក់ងារបង្ហូរព្រះគុណសំរាប់នឹងប្រាប់ពីព្រះគុណទ្រង់ដល់គេ(5-6)។ ដូចសាវ័កជាកោសិកានៃការបើកសំដែងដំបូង អ្នកដែលត្រូវបានសង្គ្រោះគួរតែប្រកាសពីព្រះគុណដូចជាឧបករណ៍មួយទៅកាន់ពិភពលោក។ (9-10)

## 2. សេចក្តីអធិស្ឋានរបស់ប៉ូល (14-21)

ការទូលអង្វរដំបូងនៅក្នុងអេភេសូជំពូក១ សាវ័កដែលស្វែងរកដំណោះដឹងនៃការបើកសំដែង បានសូមរបស់ដែលចាំបាច់ខាងព្រលឹងវិញ្ញាណរបស់គេ ដើម្បីនឹងរក្សាព្រះគុណជាបន្តទៀតនៅក្នុងលោកិយ។ នៅក្នុងជំពូក3។

(1) ឥរិយាបថនៃការអធិស្ឋាន- គាត់បានលត់ជង្គង់ចុះនៅមុខព្រះវរបិតា ដែលទ្រង់បានប្រទាននាមទៅដល់គ្រប់ជាតិសាសន៍ ហើយបានថ្វាយការទូលអង្វរដោយភាពស្មោះត្រង់(14)។ បន្ទាប់ពីការសុគតនិងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ ទ្រង់មានគ្រប់ទាំងអំណាចទាំងអស់របស់ស្ថានសួគ៌ ផែនដី ហើយគ្រប់ទាំងនាមទាំងអស់ត្រូវលត់ជង្គង់ចុះនៅចំពោះព្រះ ហើយថ្វាយនូវក្លិនឈ្ងុយនៃសេចក្តីអធិស្ឋាន។ (ម៉ាថាយ 2៖8:18)

(2) អត្ថន័យនៃសេចក្តីអធិស្ឋាន - អត្ថន័យនៃសេចក្តីសំណូមគឺជាសប្តិរបស់មនុស្សនៃការអធិស្ឋាន ឥរិយាបថនៃជីវិត និង កាបញ្ចោក់គម្រោងរបស់គេផ្ទាល់ដែលផ្តោតលើគម្រោងការដ៏អស្ចារ្យរបស់ព្រះ។ នៅក្នុងការទូលអង្វររបស់គាត់សំរាប់ក្រុមជំនុំអេភេសូ ស្នាមជើងរបស់ក្រុមជំនុំដែលស្គាល់ដំណឹងល្អ ដែលគាត់បាននាំចិត្តរបស់គាត់សំរាប់នឹងបង្ហាញនូវរូបឆ្លុះរបស់ព្រះ ដែលជាជីវិតរបស់ពួកសិស្ស។ ការអធិស្ឋានជាសេចក្តីសង្ខេបជាមួយការទូលអង្វរបួនយ៉ាង។

1) ការទូលអង្វរទីមួយ - ធ្វើឲ្យមនុស្សខាងក្នុងបានចម្រើនកំលាំងឡើង(16)។ – នៅទីនេះ មនុស្សខាងក្នុងចង្អុលទៅកាន់ព្រលឹងដែលកើតជាថ្មី ដែលជាម្នាក់ដែលគ្រប់គ្រងលើដោយព្រះវិញ្ញាណបរិសុទ្ធ (១ កូរិនថូស 3:1)។ នៅពេលដែលមនុស្សខាងក្នុងត្រូវបានចម្រើនកំលាំងឡើងដូចជាដើមឈើដែលវាឡើង ជំនឿ សេចក្តីស្រឡាញ់ និង សេចក្តីសង្ឃឹមត្រូវបានចុះសម្រុងគ្នា។ ដូច្នេះសាវ័កស្វែងរកដំបូងនូវការចំរើនកំលាំងនៃមនុស្សខាងក្នុង។ វាជាជីវិតដែលវិញ្ញាណគ្រប់គ្រងលើសាច់ឈាម ជាជីវិតដែលមនុស្សខាងក្នុងគ្រប់គ្រងលើមនុស្សខាងក្រៅ ជាជីវិតដែលពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ (អេភេសូ 5:18)

2) ការទូលអង្វរទីពីរ៖ ចម្រើននូវសេចក្តីជំនឿរបស់ពួកគេ (17) – "ដែលព្រះនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើង ព្រះវរបិតានៃសិរីល្អ នឹងប្រទានដល់អ្នកនូវវិញ្ញាណនៃប្រាជ្ញា និង ការបើកសំដែងនៅក្នុងចំណេះដឹងរបស់ទ្រង់" ដែលនៅក្នុង

ពួកគេជាស្រាប់។ ហេតុអ្វីបានជាគាត់សូមឲ្យព្រះ គ្រីស្ទគង់នៅជាមួយគេ? វាជាការឆ្លងនូវទំហំដែលត្រឹមត្រូវ ប៉ុន្តែដើម្បីនឹងចង្អុលទៅកាន់ទំហំដែលបានពិសោធរួចមក។ វាមានន័យថាព្រះគ្រីស្ទមិនមែនត្រឹមតែជាព្រះសង្រ្គោះប៉ុណ្ណោះ តែទ្រង់ជាព្រះអម្ចាស់នៅគ្រប់ការទាំងអស់ ហើយពួកគេចង់រស់នៅជាអ្នកបំរើរបស់ព្រះគ្រីស្ទ។ កាលពីដើម ជីវិតរបស់មនុស្សនៅក្នុងការតាំងសញ្ញាត្រូវបានបង្ហាញដោយរាស្រ្តអ៊ីស្រាអែលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលត្រូវបានដឹងថាជាគោលការណ៍ដែលសំខាន់នៅក្នុងដំណឹងល្អ។ "ព្រះយេហូវ៉ាជាព្រះរបស់អ៊ីស្រាអែល ហើយអ៊ីស្រាអែលជារាស្ត្ររបស់ព្រះ"។ សេចក្តីជំនឿមានទាក់ទងទៅនឹងទំនាក់ទំនងនៃការរួបរួម ដែលមិនអាចបំបែកចេញពីព្រះគ្រីស្ទបាន។ សេចក្តីជំនឿដែលបានចម្រើនឡើងជាទំនាក់ទំនងដែលរួបរួម ដែលត្រូវបានរួបរួមជាមួយនឹងព្រះគ្រីស្ទ។ ដូច្នេះអ្នកជឿជារាស្ត្រអ៊ីស្រាអែលថ្មី ហើយជាមនុស្សថ្មីនឹងត្រូវការជីវិតនៃមនុស្សថ្មី។

3) សេចក្តីទូលអង្វរទីបី៖ សូមឲ្យខ្ញុំរស់នៅដោយពេញបរិបូរ (17) - "ដែលព្រះនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើង ព្រះវរបិតានៃសិរីល្អ នឹងផ្តល់មកអ្នកនូវវិញ្ញាណនៃប្រាជ្ញា និង ការបើកសំដែងនៅក្នុងចំណេះដឹងរបស់ទ្រង់" (17)។ សេចក្តីស្រឡាញ់ពិតគឺជាផ្កា និង ជាផ្លែដែលចេញពីឫសនៃជំនឿពិត (១ កូរិនថូស 13:13)។ ដូច្នេះសេចក្តីសង្ឃឹម និង សេចក្តីស្រឡាញ់ចេញមកពីសេចក្តីជំនឿ។ ចេតនារបស់ប៉ូលបានគិតថាសេចក្តីស្រឡាញ់ជាទីមួយនៅក្នុងការទាំងបី បានសង្កត់ធ្ងន់ថាគ្រឹះនៃគ្រប់ទាំងព្រះគុណនិងអំណោយទានគឺជាសេចក្តីស្រឡាញ់។ ប្រសិនបើយើងមិនមានផលផ្លែនៃសេចក្តីស្រឡាញ់ នោះវាបានស្លាប់ហើយក៏ខុសឆ្គងដែរ។ ចុងក្រោយឥរិយាបថរបស់យ៉ាកុបគឺជាសេចក្តីស្រឡាញ់របស់ប៉ូលនោះឯង។ ការមួយនេះគួរតែបានរីករាយនៅក្នុងជីវិតរបស់គ្រីស្ទាន សាវ័កបានអះអាងថាឫសនិងគ្រឹះរបស់នៃសេចក្តីជំនឿនឹងត្រូវបានចំរើនកំលាំងឡើង។ ដូច្នេះគាត់បានប្រើការប្រៀបធៀបពីដើមឈើនិងផ្ទះ (១ កូរិនថូស 2:7)។ អ្វីដែលបានគ្របបាំងនូវការចាកចេញនៃសេចក្តី

ជំនឿនិងដំណើរការនៃការលូតលាស់ គឺជាសេចក្តីស្រឡាញ់របស់ព្រះ។ ការកាត់ទំនាក់ទំនងនៃសេចក្តីស្រឡាញ់របស់ព្រះពីគ្រប់ការទាំងអស់នោះវាមិនអាចទៅរួចឡើយ។ ដូច្នេះប៉ូលស្វែងរកទំនាក់ទំនងនៃសេចក្តីស្រឡាញ់របស់ព្រះនោះដែលទ្រទ្រង់ និង បានហូរហៀរ ហើយគ្រប់ទាំងព្រះគុណនឹងបានហូរយ៉ាងបរិបូរណ៍។

4) ការទូលអង្វរទីបួន៖ បំពេញពួកគេដោយសេចក្តីពោរពេញនៃព្រះព្ទ (19) - "សេចក្តីអស្ចារ្យរបស់ព្រះដែលមិនអាចវាល់បាននៃចេស្តារបស់ទ្រង់មកកាន់យើងអ្នកដែលជឿយ៉ាងណាហ្ន៎ តាមការធ្វើការនៃចេស្តាដ៏អស្ចារ្យរបស់ទ្រង់" សំរាប់នឹងបំពេញក្រុមជំនុំជាមួយនឹងសេចក្តីពោរពេញរបស់ព្រះ ដែលជាគោលបំណងចុងក្រោយ ដែលក្រុមជំនុំគួរតែឆ្ពោះទៅកាន់(MacArthur)។ វាមានន័យថាសំណួរដំបូងនៃ the Westminster Confession Shorter Chatechism, "តើអ្វីទៅជាគោលបំណងចម្បងរបស់មនុស្ស?" ចម្លើយនោះគឺដើម្បីនឹងថ្វាយសិរីរុងរឿងដល់ព្រះហើយមានអំណរនឹងទ្រង់អស់កល្បជានិច្ច។ ពាក្យមួយទៀតថា វាជាជីវិតដែលបង្ហាញពីរូបឆ្លុះរបស់ព្រះគ្រីស្ទដោយការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ អត្ថន័យពិតនៃពួកបរិសុទ្ធគឺជាលទ្ធផលដែលចេញមកពីសេចក្តីពោរពេញរបស់ព្រះ។ សាវ័កបានប្រាប់ថាយើងត្រូវការការពីរយ៉ាងដើម្បីទទួលបានការនោះ។ ទីមួយ ស្គាល់ពីទំហំ កំពស់ និង ប្រវែង ហើយទីពីរ យល់ពីសេចក្តីស្រឡាញ់នេះជាមួយគ្នានឹងពួកបរិសុទ្ធ។ ដើម្បីនឹងចម្រើនដល់មនុស្សខាងក្នុង មានន័យថាការបង្កើតនូវសហគមន៍ដែលរួបរួមដែលបង្កើតឡើងដោយអំណាចនៃសេចក្តីស្រឡាញ់ តាមរយៈការទទួលយកសេចក្តីស្រឡាញ់របស់ព្រះចេញពីឬសនៃដើមនៃសេចក្តីជំនឿ។ ព្រះសព្វព្រះហឫទ័យនៅពេលដែលលោកិយទទួលស្គាល់ថាក្រុមជំនុំជាកូនរបស់ព្រះ។ រូបភាពនៃការប្រោសលោះយ៉ាងពេញលេញគឺជាព្រះវិញ្ញាណបរិសុទ្ធដែលព្រះបានចាក់បំពេញលើក្រុមជំនុំ។

(3) ការប្រសិទ្ធិពរ - សាវ័កបានបញ្ចប់ទីបញ្ចប់នៃការអធិស្ឋានជាមួយនឹងការសរសើរដំកើងនៃសេចក្តីជំនឿ(20-21)។ ទីមួយ គាត់បានសារភាពថាព្រះអាចធ្វើឲ្យ

ការទូលអង្វររបស់គេ និង គំនិតរបស់គេឲ្យពេញដោយរបស់ពេញបរិបូរណ៍ ហើយអាចបង្កើតនូវគោលបំណងរបស់គេ។ នៅក្នុងការអធិស្ឋានទីមួយរបស់គាត់ គាត់ដែលជាអ្នកមានការកោតសរសើរ ដោយបានឃើញនូវគម្រោងការនៃសេចក្តីប្រោសលោះ និង ការអនុវត្តការប្រោសលោះ នឹងសរសើរព្រះ ថ្វាយសិរីល្អព្រះ ដោយឃើញនូវក្រុមជំនុំដ៏មានសិរីរុងរឿង ដែលពេញដោយគ្រប់ការទាំងអស់របស់ព្រះតាមរយៈការថ្វាយនូវការទូលអង្វរនិងការសរសើរដំកើង។ នៅទីនេះយើងឃើញសិរីរុងរឿងរបស់ក្រុមជំនុំគឺដូចគ្នានឹងសិរីរុងរឿងរបស់ព្រះគ្រីស្ទ ពីព្រោះគាត់បានឃើញសេចក្តីសំរេចយ៉ាងពេញលេញនៃការតាំងសញ្ញា។ ដែលមានព្រះគ្រីស្ទជាព្រះអម្ចាស់នៅក្នុងក្រុមជំនុំ ហើយក្រុមជំនុំជាអ្នកបំរើរបស់ព្រះគ្រីស្ទ។

សរុបសេចក្តី៖

ក្រុមជំនុំជាអ្នកធ្វើការនៃដំណឹងល្អ។ ដូច្នេះខ្ញុំដែលជាសមាជិកម្នាក់របស់ក្រុមជំនុំមានកាតព្វកិច្ចក្នុងការប្រកាសដំណឹងល្អ។ វិធីសាស្រ្តប្រកាសដំណឹងល្អគឺបើកសំដែងពីរូបឆ្លុះរបស់ព្រះនៅក្នុងជីវិតរបស់យើង។ តើសេចក្តីទុក្ខលំបាកអ្វីខ្លះដែលខ្ញុំត្រូវរងសំរាប់ដំណឹងល្អ? ដូច្នេះក្រុមជំនុំគួរតែស្តាប់បង្គាប់តាមកាតព្វកិច្ចនេះរហូតដល់ព្រះគ្រីស្ទយាងមកម្តងទៀតនៅលើផែនដីនេះ។ រហូតដល់ព្រះអម្ចាស់មកលើលោកិយនេះ ក្រុមជំនុំគួរតែបំពេញនូវរូបកាយរបស់គេដោយសំណល់នៃសេចក្តីទុក្ខលំបាក។យើងគួរតែរៀបរបៀបនៃមនុស្សខាងក្នុងលើសជាងការទាំងអស់។ យើងគួរតែក្លាយជាមនុស្សដែលខ្លាំងនៅក្នុងចិត្ត។ យើងគួរតែពេញដោយចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ មិនត្រូវធ្លាក់ចុះដោយការវាយប្រហាររបស់សាតាំងនិង កុំឲ្យទទួលនូវព្យុះនៃអំពើបាប ប៉ុន្តែក្លាយជាមនុស្សដែលមានចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។ ចេស្តានេះនឹងត្រូវបានផ្តល់មកអ្នកដែលស្មោះត្រង់ ដែលជាអ្នកដឹកនាំ។ ក្រុមជំនុំនាពេលបច្ចុប្បន្នត្រូវការមនុស្សខាងវិញ្ញាណដូចនេះ។ តាមរយៈមនុស្សដូច្នេះក្រុមជំនុំនឹងលូតលាស់ជារឿយៗ។ ចុងក្រោយក្រុមជំនុំដែលឈររឹងមាំលើគ្រឹះនៃសេចក្តីជំនឿនិងសេចក្តីស្រឡាញ់ នឹងក្លាយជាកូនក្រមុំរបស់ព្រះគ្រីស្ទ ដែលទ្រង់បានបើក

សំដែងពីរូបឆ្លុះរបស់ព្រះគ្រីស្ទ សេចក្តីសប្បុរស សេចក្តីសុចរិត និង ភាពស្មោះត្រង់ដោយភាពពេញដោយកិច្ចការរបស់ព្រះ។

លំហាត់

# មេរៀនទី 5
# ការរួបរួមរបស់ក្រុមជំនុំ

អេភេសូ 4:1-32

"ទាល់តែយើងរាល់គ្នាបានរួបរួម ខាងឯសេចក្តីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ ដូចគ្នាទាំងអស់ គឺដល់បានពេញជាមនុស្ស ហើយដល់ខ្នាតកំពស់នៃសេចក្តីពោរពេញផងព្រះគ្រីស្ទ" (អេភេសូ 4:13)

## មេរៀនទី 5 ការរួបរួមរបស់ក្រុមជំនុំ

គោលគំនិតៈ

1. រូបភាពទាំងមូល- រស់នៅឲ្យសាកសមនឹងកិច្ចការដែលអ្នកបានត្រាស់ហៅមក។
2. សៀវភៅដែលដាក់នៅកណ្តាលនៃរូបភាព - វាជាជីវិតដែលរួមជាមួយនឹងព្រះ។ នៅចំនុចកណ្តាលរបស់គាត់។
3. មនុស្សដែលឈរនៅផ្នែកខាងលើ – អំណោយដែលព្រះផ្តល់ឲ្យក្រុមជំនុំ។
(1) មនុស្សដែលចាកចេញចុងក្រោយបង្អស់ – ពួកសាវ័កដែលជាគ្រឹះនៃក្រុមជំនុំ និងជាអាវៈយវៈនៃការបើកសំដែង។
(2) មនុស្សដែលកាន់ដំបង – ហោរា
(3) បុរសដែលកាន់គម្ពីរ - អ្នកផ្សាយដំណឹងល្អ
(4) បុរសដែលពាក់អាវធំ - គ្រូគង្វាលនិងគ្រូបង្រៀន
3. មនុស្សពីរប្រភេទដែលឈរនៅក្នុងសៀវភៅ – ទង្វើដែលរឹងមាំដើម្បីរួបរួមជាមួយក្រុមជំនុំ គឺការបោះចោលនូវមនុស្សចាស់ ប៉ុន្តែបំពាក់នូវមនុស្សថ្មីវិញ។
4. បន្ទាត់ពុះចែក - ការរួបរួមនៃក្រុមជំនុំត្រូវបានសំរេចបំពេញដោយការរួបរួម ដើម្បីស្គាល់ព្រះគ្រីស្ទ ហើយជឿដល់ទ្រង់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ។

រូបភាព

មេរៀនទី 5

# ការរួបរួមរបស់ក្រុមជំនុំ

I. អត្ថបទ៖ អេភេសូ 4:1-32

2. ខគម្ពីរសំខាន់៖ អេភេសូ 4:13

3. សេចក្តីណែនាំ៖

យើងបានរំលឹកមេរៀនមួយចំនួនរួចមក អេភេសូជំពូក 1-3 បង្ហាញពីគោលលិទ្ធិនៃសមាជិកនៃក្រុមជំនុំជាអ្វី និយាយដោយខ្លី សេចក្តីប្រោសលោះ។ ប៉ូលព្យាយាមផ្តល់កំលាំងដល់ក្រុមជំនុំអេភេសូដោយពន្យល់ប្រាប់ពីអាថ៌កំបាំងនៃសេចក្តីប្រោសលោះ ពីព្រោះពេលដែលក្រុមជំនុំយល់ឲ្យបានជ្រៅពីគំរូនៃសេចក្តីប្រោសលោះ គេអាចនឹងដើរតួបានយ៉ាងល្អក្រៃលែងនៅក្នុងផែនដី។ ចាប់ពីពេលនេះទៅយើងនឹងសិក្សាពីក្រុមជំនុំត្រូវបញ្ចេញនូវផលផ្លែនៃកិច្ចការខាងសេចក្តីប្រោសលោះ ។ ពិតណាស់ការបង្រៀននិងជីវិត ការសង្គ្រោះនិងការអនុវត្ត ការស្គាល់និងការធ្វើមិនមានអ្វីដែលដាច់ចេញពីគ្នានោះទេ។ ដូច្នេះក្រុមជំនុំដែលត្រូវបានបង្កើតឡើងនៅលើសេចក្តីពិតនៃការប្រោសលោះ គួរតែដើរតាមជីវិតនៃចរិយាមាយាទនិងសីលធម៌ដែលសមរម្យទៅនឹងសេចក្តីប្រោសលោះ។ និយាយបានម្យ៉ាងទៀតថា មុនពេលដែលយើងស្តាប់នូវអ្វីដែលយើងធ្វើ យើងគួរតែមានហេតុផលរស់នៅឲ្យបានដូចការនោះដែរ។ បន្ទាប់មកចរិយាមាយាទនិងសីលធម៌នរបស់គ្រីស្ទានក្លាយទៅជាផ្កានិងផ្លែដែលចាក់ឬសនៅក្នុងសេចក្តីប្រោសលោះ។ គោលការណ៍នេះជាលំហូរដែលស្ថិតស្ថេរដែលបើកសំដែងនៅក្នុងសំបុត្ររបស់ប៉ូល។ លើសពីនោះទៀតគោលលិទ្ធិនេះត្រូវបានបង្ហាញដោយព្រះវិញ្ញាណបរិសុទ្ធ។ ការរួបរួមត្រូវបានសំរេចនៅក្នុងការ

លើកឡើងរបស់ព្រះគ្រីស្ទ ជាពិសេស ហើយដោយការប្រទាននូវវត្តមានរបស់ទ្រង់ទៅកាន់ក្រុមជំនុំ ការនោះនឹងបានសម្រេចបំពេញក្នុងព្រះវិញ្ញាណបរិសុទ្ធ។

4. សេចក្តីអធិប្បាយះ

នៅក្នុងជំពូកបួន ប៉ូលបាននិយាយពីសារៈសំខាន់នៃក្រុមជំនុំសកលលោក។ ប៉ូលបានបង្រៀនពីសេចក្តីប្រោសលោះនៅក្នុងជំពូក 1-3 សង្ខេបដោយនិយាយថា "ធ្វើការដែលសាកសមនឹងការត្រាស់ហៅ" នៅផ្នែកដំបូង។ តើអ្វីទៅជាជីវិតនៃការត្រាស់ហៅ? គាត់បានបកប្រែមកថា "សេចក្តីត្រេកត្រាអាលដើម្បីនឹងពង្រឹងនូវសេចក្តីរួបរួមនៃព្រះវិញ្ញាណនៅក្នុងចំណងនៃសេចក្តីសុខសាន្ត"(3)។ ចូរយើងគិតពីជីវិតនៃការរួបរួមនិងឥរិយាបថគោលនៃការរួបរួម។

1. ការរួបរួមនៃព្រះវិញ្ញាណ (1-13)

(1) សេចក្តីពិតដែលប៉ូលមានប្រតិកម្មលើការរួបរួមនៃក្រុមជមនុំជាសំខាន់ នោះចេញមកពីការរួបរួមជាដំណែងយ៉ាងសំខាន់នៅក្នុងការបង្កើតនូវសេចក្តីប្រោសលោះ។ ក្រុមជំនុំដែលមានជីវិតនៅក្នុងព្រះវិញ្ញាណបរិសុទ្ធតែមួយមាននូវសង្ឃឹមនៃការត្រាស់ហៅ និងបំរើព្រះអម្ចាស់ ជាព្រះតែមួយដោយទទួលបានជំនឿមួយនិងការជ្រមុជតែមួយ។ វាមិនមែនជាការរួបរួមអស់កល្បទេ ប៉ុន្តែជាការរួបរួមខាងក្នុងអស់កល្បវិញ(1;10)។ ការរួបរួមនៃក្រុមជំនុំដែលបានសង្គ្រោះគួរតែជាការរួបរួមនៅក្នុងចំណុចកណ្តាលនៃបំណងរបស់ព្រះនៅក្នុងព្រះគ្រីស្ទ។

(3) ព្រះដែលទ្រង់ជាអ្នកបង្កើតក្រុមជំនុំ ដែលជារូបកាយរបស់ព្រះគ្រីស្ទដោយផ្តល់នូវព្រះគុណយ៉ាងសាកសម(7-16)។ ព្រះអម្ចាស់ដែលទ្រង់បានលើកឡើងមិនឈប់ឡើយ ប៉ុន្តែបង្កើតការរួបរួមនៃក្រុមជំនុំដោយផ្តល់នូវព្រះគុណវិញ។ សំរាប់ជាប្រយោជន៍ដល់ក្រុមជំនុំ ព្រះគ្រីស្ទបានបង្កើតពួកសាវ័ក ហោរា និង អ្នកផ្សាយដំណឹងល្អ។ ពួកគេធ្វើការបណ្តោះអាសន្នដើម្បីនឹងបង្កើតបទគម្ពីរដែលក្រុមជំនុំ

សកលលោកគួរតែឈរឲ្យបានរឹងមាំលើ ហើយបន្ទាប់ពីព្រះគម្ពីរត្រូវបានបញ្ចប់ តួនាទីត្រូវបានរលាយបាត់ ប៉ុន្តែឥឡូវព្រះគ្រីស្ទធ្វើព័ន្ធកិច្ចរបស់ទ្រង់យ៉ាងជាប់លាប់តាមរយៈគ្រូបង្រៀន និង គ្រូគង្វាល។ ដូច្នេះលោកកាល់វីនបានប្រាប់យើង ថាវាជាការដែលអាចិកំបាំងណាស់ ដែលព្រះធ្វើឲ្យគ្រូគង្វាលដឹងព្រះបន្ទូលរបស់ព្រះ តាមរយៈមាត់ដ៏អាក្រក់របស់ពួកគេ។ ដូច្នេះសមាជិកក្រុមជំនុំគួរតែចូលរួមជាមួយគ្នាបង្កើតនូវការរួបរួមនៅក្នុងក្រុមជំនុំ។

(3) ការរួបរួមនឹងត្រូវបានបង្កើតឡើងដោយក្លាយទៅជាភាពតែមួយ ដោយជឿលើព្រះរាជបុត្រារបស់ព្រះនិងស្គាល់ដល់ទ្រង់(13)។ ការរួបរួមនេះគួរតែក្លាយជាតែមួយដែលគួរតែឈរលើគ្រឹះនៃចំណេះដឹងនៃសេចក្តីពិតនិងការបង្រៀនត្រឹមត្រូវ (អេភេសូ 2:20)។ នៅពេលដែលក្រុមជំនុំស្គាល់ព្រះបន្ទូល ដែលបានបើកសំដែងនៅក្នុងបំណងរបស់ព្រះហើយធ្វើតាម គេនឹងបានជាមនុស្សពេញលេញ ដែលជាព្រះវិហារពេញលេញ។ បន្ទាប់មកក្រុមជំនុំអាចបង្ហាញពីរូបឆ្លុះរបស់ព្រះ។ នៅពេលដែលក្រុមជំនុំបើកសំដែងពីរូបឆ្លុះ សេចក្តីសុចរិត សេចក្តីមេត្តា និងភាពបរិសុទ្ធ វានឹងបានស្រស់ស្អាត។ សេចក្តីពិតដែលដានីយ៉ែលនិងមិត្តទាំងបីរបស់គាត់ត្រូវបានប្រើដោយព្រះទៅចំពោះស្តេចសាសន៍ដទៃដ៏ធំ និង អ្នកបំរើរបស់គេ នោះចេញមកពីជីវិតដែលស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ សេចក្តីទៀងត្រង់និងស្មោះត្រង់។ ពួកគេជាឧទាហរណ៍សំរាប់ក្រុមជំនុំនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ជីវៈប្រវត្តិនៃការលូតលាស់នៃក្រុមជំនុំសញ្ញាចាស់បង្ហាញថាមនុស្សដែលរស់នៅដោយបង្ហាញពីរូបឆ្លុះរបស់ព្រះបំរើព្រះដោយស្មោះត្រង់ដូចជាប៉ូលបានធ្វើ។ គោលការណ៍នេះជាសេចក្តីពិត ដែលមិនផ្លាស់ប្រែនៅក្នុងប្រវត្តិសាស្រ្ត។ ដូច្នេះក្រុមជំនុំគួរតែផ្តោតលើការស្គាល់ព្រះហើយជឿដល់ទ្រង់ មុននឹងធ្វើកិច្ចការអ្វីផ្សេងទៀត។ នេះគ្រាន់តែជាការធ្វើការរបស់ព្រះគម្ពីរ។ នៅពេលដែលយើងអានព្រះគម្ពីរហើយសញ្ជឹងគិត និងធ្វើតាមព្រមទាំងប្រកាសដល់អ្នកជិតខាង ការលូតលាស់ពិតប្រាកដនឹងកើតឡើង។ ជីវៈប្រវត្តិនៃការលូតលាស់ទាំងអស់មាននូវការប្រកបជាមួយនឹងព្រះគម្ពីរ។ ការលូតលាស់ដែល

ជៀសពីព្រះគម្ពីរមិនមែនជាការលូតលាស់ពិតប្រាកដនោះទេ ប៉ុន្តែវាជាទីដែលសាតាំងធ្វើការប៉ុណ្ណោះ។ ក្រុមជំនុំមិនគួរស្តាប់ទៅកាន់ពាក្យរបស់ឡាសាដែលស្លាប់ទេ ប៉ុន្តែគួរស្តាប់តាមម៉ូសេនិងហោរាដែលនោះជាព្រះគម្ពីរ។ បន្ទាប់មកគេអាចស្គាល់ព្រះនិងរីករាយនឹងព្រះពរដែលធ្វើឲ្យភ្នែករបស់ពួកគេបើកឡើង និងស្គាល់ហេតុផលនៃការថ្វាយបង្គំសំរាប់សិរីល្អរបស់ទ្រង់ និងធ្វើឲ្យពួកគេរស់នៅដោយវិជ្ជមាន។

2. វិធីសាស្ត្រនៃការរួបរួម (17-32)

គ្រឿងដែលជាឧបសគ្គនៃការលូតលាស់របស់ក្រុមជំនុំនោះគឺជាការមានទ្រឹស្តីជាច្រើនខុសៗគ្នានិងការរួបរួមខាងក្រៅ ប៉ុន្តែបញ្ហាខ្លួនវាផ្ទាល់នោះគឺមនុស្សចាស់ដែលកំពុងតែធ្វើការនៅក្នុងសមាជិកក្រុមជំនុំ។ ដូច្នេះប៉ូលបានជម្រុញថា "ថាខាងឯកិរិយាការប្រព្រឹត្តកាលពីដើម នោះត្រូវឲ្យអ្នករាល់គ្នាបានដោះមនុស្សចាស់ ដែលតែងតែខូចទៅ តាមសេចក្តីប៉ងប្រាថ្នារបស់សេចក្តីឆបោកចោលចេញ។ ហើយឲ្យគំនិតក្នុងចិត្តបានកែប្រែជាថ្មីឡើង។ ព្រមទាំងប្រដាប់ខ្លួន ដោយមនុស្សថ្មីវិញ ដែលកើតមកក្នុងសេចក្តីសុចរិត ហើយក្នុងសេចក្តីបរិសុទ្ធរបស់ផងសេចក្តីពិតតាមភាពព្រះ" (22-24) សំរាប់សេចក្តីរួបរួមរបស់ក្រុមជំនុំ។ យោងតាមការបញ្ជាក់របស់ព្រះអម្ចាស់ នោះវាជាការបដិសេធខ្លួនឯង ជាចុងក្រោយគេនឹងក្លាយជាសហគមន៍ដែលមានការរួបរួមនឹងព្រះ ដែលព្រះអម្ចាស់ចង់បាន។ (ឯកសារយោង ម៉ាថាយ 16:)

លោកកាល់វីនដែលបានយល់ពីសេចក្តីពិតនេះបានសង្ខេបជីវិតនៃគ្រីស្ទានធម្មតាដូចជាការ៦យ៉ាង។ ការទាំងនោះជា ការបន្ទាបខ្លួន ជីវិតស្តាប់បង្គាប់ ការបដិសេធខ្លួនឯង ជីវិតដែលលីឈើឆ្កាងនៅក្នុងសេចក្តីអត់ធ្មត់ សេចក្តីសង្ឃឹមនៅពេលអនាគត ទិសដៅដែលត្រឹមត្រូវនៃជីវិតបច្ចុប្បន្ននៅក្នុងការអនុវត្តរបស់គេ។ អាល់ហ្វានិង អូមេហ្គានៅក្នុងជីវិតនេះគឺជាការបដិសេធខ្លួនឯងដូចជាពួកសាវ័កបានបង្ហាញ។

(1) រូបភាពនៃមនុស្សចាស់

បើទោះជាពួកសាវ័កបានប្រៀបធៀបពីអត្តសញ្ញាណនៅក្នុងអេភេសូជំពូក២ ទីនេះគាត់បានរៀបចំនូវរូបភាពបីនៃមនុស្សចាស់។ មនុស្សចាស់ចង្អុលទៅកាន់ឥរិយាបថដែលគ្រប់គ្រងនៅលើជីវិតចាស់ពីមុនសេចក្តីសង្គ្រោះ។ បើទោះជាមនុស្សកើតម្តងទៀតដោយព្រះវិញ្ញាណបរិសុទ្ធ តែឥរិយាបថដែលពុករលួយនៅតែសេសសល់នៅក្នុងគ្រីស្ទាន ដូចជាពួកអ៊ីស្រាអែលត្រូវបានសន្សល់ទុកពួកកាណានដោយព្រះអម្ចាស់ ហើយធ្វើឲ្យពួកគេត្រូវបណ្តេញចេញបន្តិចម្តងៗ ដើម្បីនឹងរក្សាទឹកដីឲ្យបាន នឹងដើម្បីបង្វឹកដល់ពួកគេ។ មនុស្សចាស់នេះដែលប្រែថាជាសាច់ឈាម រូបកាយ និង សេចក្តីត្រូវការខាងសាច់ឈាម គឺជាសត្រូវដ៏អាក្រក់ ដែលបំផ្លាញការរួបរួមនៃសហាគមន៍របស់ក្រុមជំនុំ។ សត្រូវនេះត្រូវបានបង្ហាញជាមួយប្រភេទបីយ៉ាង។

ទីមួយ ពីព្រោះសេចក្តីឆ្លាតវៃដែលងងឹតងងុល ធ្វើឲ្យយើងក្លាយជាមនុស្សល្ងីល្ងើ។ វាធ្វើឲ្យពួកគេធ្លាក់ចុះនៅក្នុងសេចក្តីល្ងង់ខ្លៅខាងវិញ្ញាណ។ ហេតុផលដែលតែងតែប្រឆាំងនឹងកិច្ចការនៃព្រះវិញ្ញាណរបស់ព្រះជាការមិនស្គាល់ព្រះ។

ទីពីរ ចិត្តដែលបោះបង់នូវជីវិតរបស់ព្រះបានក្លាយជាខ្លាំងដូចជាថ្ម ពីព្រោះគេរស់នៅដូចមនុស្សដែលចាកចេញពីព្រះគ្រីស្ទ។ ពេលដែលក្រុមជំនុំត្រូវពុករលួយពីព្រោះគេត្រូវបានផ្លាស់ប្តូរទៅជាចិត្តដែលវាយឫកចេញពីចិត្តដែលខ្មៅខ្មាំ និងចិត្តដែលខ្សោយក្នុងវិញ្ញាណ គេបានក្លាយជាក្រុមជំនុំនៃរូបឆ្លុះរបស់បីសាយជារូងរបស់ចោរ។

ទីបី គេមិនបានទទួលការបើកសំដែងនិងមានជីវិតដែលវង្វេង ហើយធ្វើនូវអំពើដែលស្មោគគ្រោកនៅក្នុងភាពលោភលន់ដូចជាសត្វតិរច្ឆាន។ រូបខាងក្រៅរបស់គេ

បានលេចឡើងជាអ្នកដែលគោរពកោតខ្លាចដល់ព្រះ ប៉ុន្តែខាងក្នុងវិញពេញដោយសេចក្តីកំពុត។ ដូចនេះព្រះអម្ចាស់បានបង្គាប់ ទីមួយឲ្យបដិសេធខ្លួនឯង ហើយលីឈើឆ្កាងរបស់ខ្លួននិងដើរតាមព្រះអម្ចាស់។

បើទោះជាយើងបំពាក់នូវមនុស្សថ្មីក៏ដោយ ប្រសិនបើយើងមិនអើពើនឹងជីវិតដែលបានបំពាក់មនុស្សថ្មី យើងបង្ហាញពីរូបនៃមនុស្សចាស់។ គេបាត់បង់នូវចំណេះដឹងនៃសេចក្តីពិតដែលស្គាល់ព្រះនៅក្នុងវិញ្ញាណដែលល្ងង់ខ្លៅ ហើយគេមិនស្គាល់បាប នឹងប្រគល់ចិត្តដែលមានតម្លៃរបស់ខ្លួនទៅគ្រប់ការទាំងអស់ហើយរស់នៅក្នុងភាពច្របូកច្របល់។ ប៉ូលបានប្រគល់ទិសដៅ៨ដែលក្រុមជំនុំគួរតែធ្វើនៅក្នុងជីវិតរបស់ពួកគេ។ (25-32)

1) បោះចោលអ្វីដែលខុស និងនិយាយការដែលទៀងត្រង់។
2) មិនត្រូវប្រព្រឹត្តអំពើបាបនៅក្នុងសេចក្តីកំហឹង។
3) មិនត្រូវទុកចន្លោះសំរាប់អារក្សចូលឡើយ។
4) មិនត្រូវលួចនិងថ្វាយដោយដៃខ្លួន ចែករំលែកទ្រព្យសម្បត្តិជាមួយអ្នកដទៃ។
5) មិនត្រូវនិយាយពាក្យស្មោគគ្រោកចេញពីបបូរមាត់ ប៉ុន្តែនិយាយពាក្យដែលនាំមកនូវគុណតម្លៃវិញ។
6) មិនត្រូវធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះព្រួយព្រះទ័យនោះឡើយ។
7) បោះបង់ចោលនូវភាពល្វីង សេចក្តីកំហឹង សេចក្តីក្រោធ ការឡូឡា និង ពាក្យចោទប្រកាន់ជាមួយនឹងការព្យាបាទចេញ។
8) ចូរអត់ទោសដោយសេចក្តីស្រឡាញ់និងសេចក្តីមេត្តា។

អត្ថន័យខាងលើបានពន្យល់ពីទំនាក់ទំនងរវាងមនុស្ស និងមនុស្សនៅផ្នែកបន្ទាប់នៃបញ្ញត្តិដប់ប្រការ។ ដូច្នេះប៉ូលបានសម្គាល់យ៉ាងជាក់ថា សេចក្តីស្រឡាញ់នៃសេចក្តីមេត្តារបស់ព្រះអាចយកឈ្នះបាន តាមរយៈទំនាក់ទំនងរវាងមនុស្សនិង

មនុស្ស។ ក្រុមជំនុំមានទំនួលខុសត្រូវព្យាបាលបងប្អូនដែលខ្សោយភាពបរាជ័យរបស់គេដោយសេចក្ដីមេត្តារបស់ព្រះ។

(2) រូបភាពនៃមនុស្សថ្មី

សាវ័កប៉ូលមិនបានយកខ្លឹមសារជាការជម្រុញបែបអវិជ្ជមាន ដែលបង្ហាញនូវគំរូសាមញ្ញ ប៉ុន្តែបានបង្ហាញពីទិសដៅនៃទំនោរដែលវិជ្ជមាននៃមនុស្សថ្មីដូចខបន្តទៅនេះ។ "ហើយឲ្យក្នុងគំនិតក្នុងចិត្តបានកែប្រែជាថ្មីឡើង។ ព្រមទាំងប្រដាប់ខ្លួន ដោយមនុស្សថ្មីវិញ ដែលកើតមកក្នុងសេចក្ដីសុចរិត ហើយក្នុងសេចក្ដីបរិសុទ្ធរបស់ផងសេចក្ដីពិត តាមភាពព្រះ"។ (23-24)

នៅទីនេះយើងជួបនូវរូបភាពបីនៃក្រុមជំនុំ ដែលគួរតែពេញដោយសេចក្ដីពោរពេញរបស់ព្រះ។ និយាយម្យ៉ាងទៀតថា យើងឃើញលក្ខណៈបីដែលទាក់ទងទៅនឹងដំណែងបីជាន់ (ហោរា ស្ដេច និងសង្ឃ) ដំណែងបីជាន់នៃក្រុមជំនុំ (គ្រូគង្វាលចាស់ទុំ និង អ្នកបំរើក្រុមជំនុំ)។ បើទោះជាវាហាក់ដូចជាការពន្យល់ដែលហួសហេតុតែវាជាការបកស្រាយដែលសាកសមដើម្បីនឹងបង្ហាញពីរូបភាពនៃសិរីរុងរឿងនៃក្រុមជំនុំដែលបានប្រោសលោះ។

ទីមួយ វាជារូបឆ្លុះនៃសេចក្ដីសុចរិត។ សេចក្ដីសុចរិតគឺជាកំរិតស្ដង់ដានិងជាឆ្អឹងខ្នង។ ពេលដែលគ្រឹះនៃអាណាចក្ររបស់ព្រះត្រូវបានបង្កើត សេចក្ដីសុខសាន្តនឹងគ្រប់គ្រងលើពួកគេ។ ដោយសារការសុគតរបស់ព្រះគ្រីស្ទត្រូវបានទទួលស្គាល់ថាជាសេចក្ដីសុចរិតដោយសារព្រះ។ នោះក្រុមជំនុំត្រូវបានសង្គ្រោះដោយសារសេចក្ដីសុចរិតរបស់ក្រុមជំនុំ ដែលត្រូវបានជឿលើសគុណរបស់ព្រះគ្រីស្ទ។វាជាការជួបរវាងសេចក្ដីសុចរិតនឹងសេចក្ដីសុចរិត។ ក្រុមជំនុំជាការជួបជុំរវាងមនុស្សសុចរិត។ វា

ជាបល័ង្គរបស់ព្រះដែលសុចរិតដែលអង្គុយលើនោះ។ សេចក្តីសុចរិតនេះបត្រូវបាន បញ្ជាក់ដោយសេចក្តីសុចរិតនិងព្រះបន្ទូលជាសេចក្តីសុចរិតផ្ទាល់។ ដូច្នេះក្រុមជំនុំ បង្ហាញពីរូបឆ្លុះសេចក្តីសុចរិតនៅពេលដែលគេជឿព្រះគម្ពីរនឹងធ្វើតាម។ ពេលសព្វ ថ្ងៃនេះមនុស្សមួយចំនួនវាយតម្លៃថា "ក្រុមជំនុំកូរ៉េបានបាត់បង់សេចក្តីសុចរិតដូចជា ក្រុមជំនុំនាសម័យកណ្តាលបានធ្វើ ហើយចុងក្រោយពួកគេនឹងត្រូវធ្លាក់ចុះក្នុង កិរិយាមាយាទដែលទាបថោកនៅក្នុងការច្របូកច្របល់"។ វាមានន័យថាពួកគេបាន បាត់បង់សេចក្តីសុចរិត គ្រឹះនៃកិរិយាមាយាទ។ បើទោះជាពួកគេសង្កត់ធ្ងន់លើសេច ក្តីសុចរិតនៃសេចក្តីសង្គ្រោះក៏ដោយ ប៉ុន្តែពួកគេបានបាត់បង់សេចក្តីសុចរិតនៃជីវិត ហើយបន្ទាប់មកពួកគេមានទំនោរទៅរកការដែលទាល់នឹងភាពធម្មតា antinomian។

ដូច្នេះ ដោយសារក្រុមជំនុំបានបាត់បង់នូវអំណាចនៃសេចក្តីសុចរិត គេមិនអាច ដើរតួជាស្តេចឡើយ។ ពួកចាស់ទុំត្រូវគ្រប់គ្រងក្រុមជំនុំដោយសេចក្តីសុចរិត ប៉ុន្តែ គាត់បែរជាមើលងាយនូវសេចក្តីសុចរិតទៅវិញ។ ក្រុមជំនុំត្រូវធ្លាក់ចុះទៅក្នុងថ្នាក់ សង្គមហើយត្រូវស្នាក់នៅក្នុងនោះ។

ទីពីរ វាជារូបឆ្លុះនៃសេចក្តីពិត។ សេចក្តីពិតមានទំនាក់ទំនងទៅនឹងសេចក្តីទៀត ត្រង់ ភាពស្មោះត្រង់ និង សេចក្តីសុចរិត។ ភាពស្មោះត្រង់ជាស្នូលនៃកិច្ចការរបស់ ហោរា។ សេចក្តីពិតជាព្រះផ្ទាល់ និងព្រះបន្ទូលរបស់ទ្រង់។ ហើយមានតែព្រះទេ ដែលជាសេចក្តីសុចរិតនិងសេចក្តីពិត។ ព័ន្ធកិច្ចរបស់គ្រូគង្វាលគឺព័ន្ធកិច្ចដែល បន្លាយរបស់ហោរាដើម្បីនឹងប្រកាសសេចក្តីពិត និង ធ្វើឲ្យសេចក្តីពិតគួរឲ្យសំដែង ចេញ។ ក្រុមជំនុំគួរតែស្អប់ការខុសឆ្គង និង ស្តាប់ទៅកាន់សំឡេងនៃការយល់ដឹង ល្អ។ ការដែលប្រឆាំងនឹងការមើលទៅកាន់ព្រះគម្ពីរត្រូវបានផ្តល់លទ្ធផលឲ្យ បដិសេធសេចក្តីពិតដ៏ត្រឹមត្រូវ ហើយលើកឡើងនូវប៉មដែលមានកំហុស។យើងគួរ តែក្លាយជាសហគមន៍ដែលបំពាក់ដោយការប្រោកជនូវសេចក្តីពិតក្នុងព្រះគម្ពីរ។

ទីបី រូបឆ្លុះនៃសេចក្ដីបរិសុទ្ធ។ មួយទៀតដែលយើងគួរតែប្រាកដថា ក្រុមជំនុំជាសហគមន៍ដែលបរិសុទ្ធ។ ជីវិតរបស់សង្ឃជាជីវិតបរិសុទ្ធ។ យើងដែលជាអ្នកដើរតាមគោលការណ៍ ដែលថាគ្រប់គ្រីស្ទានទាំងអស់ជាសង្ឃ គួរតែដើរតាមរបៀបរស់នៅនៃការថ្វាយដង្វាយ ដែលថ្វាយខ្លួនរបស់យើងទៅព្រះអម្ចាស់ (រ៉ូម 12:1-2) ដែលដេញតាមរូបឆ្លុះនៃសេចក្ដីបរិសុទ្ធ។ ចិត្តរបស់សង្ឃគួរតែពេញដោយរូបឆ្លុះដែលបរិសុទ្ធ។

នៅក្នុងចំណោមធាតុផ្សំទាំងបីរបស់ព្រះគ្រីស្ទ និង រូបឆ្លុះនៃក្រុមជំនុំ។ ប៉ូលដែលបានងើបឡើងនៅក្នុងទំហំទីបីនៃស្ថានសួគ៌អាចនឹងបានឃើញរូបឆ្លុះនៃសិរីល្អរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលត្រូវបានចុះសម្រុងដោយសេចក្ដីសុចរិត សេចក្ដីពិត និងសេចក្ដីបរិសុទ្ធ ដូចជារូបឆ្លុះពិតរបស់ក្រុមជំនុំ។ ព្រះវិញ្ញាណបរិសុទ្ធបានយាងមកកាន់យើង ដើម្បីសំរេចនូវគោលបំណងនេះ ហើយទ្រង់កំពុងធ្វើការនៅក្នុងយើងដោយឥតឈប់សោះ ដូចជាការប៉ូមរបស់បេះដូងតាំងពីបុណ្យទីហាសិបបានចាប់ផ្ដើមរហូតមកគ្រប់ពេលវេលានិងគ្រប់ទីកន្លែង។ ចុងក្រោយគេនឹងបំពេញនូវក្រុមជំនុំពេញដោយសិរីល្អរបស់ព្រះ ហើយបន្ទាប់មកគេនឹងផ្លាស់ប្ដូរទៅជារូបឆ្លុះនៃការរួបរួមដែលពេញដោយភាពបរិបូររបស់ព្រះនៅក្នុងស្ថានសួគ៌អស់កល្ប។

សរុបសេចក្ដី៖

ដោយសារក្រុមជំនុំដែលពេញដោយការកើតជាថ្មី ដោយយកទំនាក់ទំនងជាមួយព្រះជានិច្ច រស់នៅក្នុងរូបឆ្លុះរបស់ព្រះ សេចក្ដីសុចរិតរបស់ព្រះបើកសំដែងនៅក្នុងជីវិតរបស់គេ។ រូបរបស់ព្រះ ភាពស្មោះត្រង់នឹងត្រូវបានបង្កើតនៅក្នុងជីវិតរបស់ក្រុមជំនុំ។ សេចក្ដីពិតដែលលោក ចន កាល់វីន ជាអ្នកកំណែទម្រង់បានចង្អុលថា ក្រុមជំនុំជាមាតាខាងវិញ្ញាណ ដែលសង្កត់ធ្ងន់ ដែលក្រុមជំនុំចាកចេញនូវការប្រកបរបស់ក្រុមជំនុំ គេមិនអាចនឹងមានការលូតលាស់នៃសេចក្ដីជំនឿពេញលេញនោះឡើយ។

បន្ទាប់មកបើទោះដោយសារស្ថានភាពជាក់ស្តែងបង្ហាញពីការប្រកបដែលពិបាក នោះវានឹងបំបាក់ទឹកចិត្តដល់អ្នកបរិសុទ្ធ ព្រះនឹងបំពេញការទាំងនេះវិញ។ បើទោះជាគំនិតខុសគ្នាមិនវិធីខុសគ្នាត្រូវបានប្រមូលផ្តុំ នៅពេលដែលគេប្រមូលផ្តុំដោយក្រោកឈររឹងមាំនៅលើគ្រឹះរបស់ព្រះគ្រីស្ទ បន្ទាប់មកការរួបរួមនៃក្រុមជំនុំនឹងត្រូវបានបង្កើតឡើងនៅក្នុងព្រះគ្រីស្ទ។ អត្ថន័យនៃការរួបរួមនេះជាគោលបំណងរបស់ក្រុមជំនុំដែលគួរខិតទៅរក។ អ្នកដែលមើលងាយការរួបរួមនេះហើយបោះបង់ចោល គេនឹងក្លាយជាម្នាក់ដែលទាស់ប្រឆាំងនឹងអាណាចក្ររបស់ព្រះ ហើយបះបោរនឹងបំណងរបស់ព្រះគ្រីស្ទ។ យើងសំរាប់ការរួបរួមនេះយើងនឹងព្យាយាមសម្លាប់ខ្លួនយើងនៅក្នុងព្រះគ្រីស្ទ។ថ

លំហាត់

មេរៀនទី 6

## គំរូរបស់ក្រុមជំនុំ

អេភេសូ 5:1-6:9

"ដ្បិតកាលពីដើមអ្នករាល់គ្នាក៏ងងឹតដែរ តែឥឡូវនេះវិញបានភ្លឺក្នុងព្រះអម្ចាស់ ដូច្នេះចូរដើរដូចជាមនុស្សភ្លឺចុះ។ ដ្បិតផលផ្លែនៃពន្លឺនោះមាននៅក្នុងគ្រប់ទាំងកិរិយាល្អ សេចក្ដីសុចរិត និង សេចក្ដីពិត។" (អេភេសូ 5:8-9)

## មេរៀនទី 6 **គំរូរបស់ក្រុមជំនុំ**

គោលគំនិតៈ

1. រស្មីឆ្ពោះទៅកាន់មកុដ- ក្រុមជំនុំដែលជាពាស្រ្តដែលយកគំរូតាមព្រះ។

2. មកុដ-ជីវិតរបស់កូនរបស់ព្រះ។

(1) ពេជ្រទីមួយ-ភាពស្មោះត្រង់

(2) ពេជ្រទីពីរ- សេចក្តីសុចរិត

(3) ពេជ្រទីបី- សេចក្តីសប្បុរស

3. ទំនាក់ទំនងអ្នកជិតខាងរបស់ក្រុមជំនុំ

(1) រូបទីមួយ- ការស្តាប់បង្គាប់និងសេចក្តីស្រឡាញ់នៅក្នុងទំនាក់ទំនងនៃប្តីប្រពន្ធ និងលើការរួបរួមរបស់ក្រុមជំនុំ។

(2) រូបទីពីរ- ការស្តាប់បង្គាប់ និង សារធាតុចិញ្ចឹមនៅក្នុងទំនាក់ទំនងរបស់ឪពុកនិងកូន មានគោលបំណងលើការលូតលាស់របស់ក្រុមជំនុំ។

(3) រូបទីបី- ជីវិតនៃការស្តាប់បង្គាប់នៅក្នុងទំនាក់ទំនងរវាងចៅហ្វាយនិងអ្នកបំរើគួរតែយកគំរូតាមព្រះគ្រីស្ទ។

រូបភាព

# មេរៀនទី 6
## គំរូរបស់ក្រុមជំនុំ

I. អត្ថបទ៖ អេភេសូ 5:1-6:9

II. ខគម្ពីរសំខាន់៖ អេភេសូ 5:8-9

III. សេចក្ដីណែនាំ៖

ប៉ូលបានពន្យល់ពីរបៀបដែលក្រុមជំនុំនៃសេចក្ដីប្រោសលោះរស់នៅក្នុងលោកិយ។ នៅមេរៀនខាងលើ យើងបានគិតថាអ្វីដែលក្រុមជំនុំស្វែងរកជាទីមួយនោះជាការរួបរួមនៅកណ្ដាលនៃនគររបស់ព្រះ និងសេចក្ដីសុចរិត ហើយបានបើកសំដែងគំរូនៃឥរិយាបថដែលព្យាយាមសំលាប់មនុស្សចាស់ចោល។ ដូចជាព្រះយ៉ាងពេញលេញ ភាពពេញលេញរបស់យើងជាគំរូនៃក្រុមជំនុំ។ (ម៉ាថាយ 5:8)។ ដូច្នេះប៉ូលបានបង្រៀនថាគំរូនៃក្រុមជំនុំមានតែព្រះប៉ុណ្ណោះ នៅក្នុងផ្នែកដំបូងរបស់អេភេសូជំពូកប្រាំ។ ដូចព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះក្រុមជំនុំមានការចាប់កំណើតជាគំរូនៃសេចក្ដីស្រឡាញ់។ ហើយដូចព្រះទ្រង់ជាពន្លឺនៃលោកិយ គេគួរតែជាពន្លឺរបស់លោកិយដែរ។ ហើយក្រុមជំនុំដែលរស់នៅក្នុងថ្ងៃនៃព្រះគុណគួរតែរស់នៅក្នុងប្រាជ្ញាពីស្ថានសួគ៌ ប៉ូលបានជម្រុញ ជាមួយនឹងទំនុកចិត្តនិងព្រះគុណជាបរិបូរណ៍នៅពេលព្រះយេស៊ូវយាងមកជាលើកទីពីរ។ ទ្រង់ចង់ឲ្យទំនាក់ទំនងប្ដីប្រពន្ធនៅក្នុងក្រុមគ្រួសារ ទំនាក់ទំនងរវាងឪពុកម្ដាយនឹងកូនៗ និង ទំនាក់ទំនងរវាងចៅហ្វាយនិងអ្នកបំរើគួរតែបង្ហាញនូវ សេចក្ដីសប្បុរស ភាពស្មោះត្រង់ និង សេចក្ដីសុចរិត។ មេរៀននៃជីវិតសង្គមមិនបានកំណត់ពីមេរៀនដែលច្បាស់លាស់នៃគ្រួសារទេ ប៉ុន្តែព្យាយាមសំរេចនូវក្រុមជំនុំសកលយ៉ាងពេញលេញ (ក្រុមជំនុំរូបិយ)។

IV. ការអធិប្បាយៈ

## 1. ចូរដើរតាមគម្រូរបស់ព្រះ

ការបើកសំដែងរបស់ពួកសាវ័កបង្ហាញពីឧទាហរណ៍នៃក្រុមជំនុំ ដែលជាព្រះត្រៃឯងទ្រង់ផ្ទាល់។ សេចក្តីស្រឡាញ់ ភាពស្មោះត្រង់ និង ភាពបរិសុទ្ធ។ ដូច្នេះនៅក្នុងសំបុត្ររបស់គ្រូគង្វាល សំបុត្ររបស់ធីម៉ូថេ ប៉ូលបានផ្តល់នូវការទិសដៅរបស់គ្រូគង្វាល ទៅកាន់គ្រូគង្វាលធីម៉ូថេ ដែលនឹងក្លាយជាគំរូនៃការថ្វាយបង្គំនៅក្នុងជីវិតរបស់គាត់ផ្ទាល់។ ជាទូទៅបុគ្គលនិងក្រុមជំនុំមាននូវបញ្ហាជាច្រើន ពីព្រោះវាជាពេលដែលមនុស្សអាក្រក់មកដល់ហើយក៏ខ្វាត់ខ្វាយនូវខ្វែនៅក្នុងលោកិយ។ កិច្ចការដំបូងនៃភាពដឹកនាំរបស់ក្រុមជំនុំគួរតែជាគំរូបែបព្រះ។ ប្រសិនបើគំរូនៅមាននោះការប្រព្រឹត្តនឹងមកតាមក្រោយ។ តើយើងត្រូវធ្វើនូវគំរូបែបយ៉ាងដូចម្តេច?

ទីមួយ ធ្វើដោយសេចក្តីស្រឡាញ់។ **(1-3)** - ទីមួយ វាបង្ហាញថាយើងគួរតែដើរតាមគំរូនៃសេចក្តីស្រឡាញ់។ ដូចដែលព្រះបានប្រទានព្រះរាជបុត្រាទ្រង់ដោយគ្មានលក្ខខណ្ឌ ហើយព្រះគ្រីស្ទបានស្រឡាញ់ខ្មាំងសត្រូវរបស់ទ្រង់រហូតដល់ពីបំផុត។ ក្រុមជំនុំគួរតែបង្ហាញនូវសកម្មភាពនៃសេចក្តីស្រឡាញ់។ ពីព្រោះគំរូនៃសេចក្តីស្រឡាញ់នោះខ្ពស់ជាងខ្លាំងណាស់ ទាល់តែស្គាល់នូវសេចក្តីស្រឡាញ់ ហើយភ្លក់វានៅក្នុងបទពិសោធន៍របស់គេ នោះគេមិនអាចនឹងរស់នៅក្នុងសេចក្តីស្រឡាញ់ដោយគំនិតវិជ្ជមាននោះឡើយ។

ទីពីរ ដូចជាកូននៃពន្លឺ (4-14) - ពាក្យថា "ព្រះទ្រង់ជាពន្លឺ" បង្ហាញពីលក្ខណៈជាព្រះនៅក្នុងសេចក្តីប្រៀបធៀប។ ប៉ូលបានសម្គាល់អ្វីដែលជាផលផ្លែនៃពន្លឺដោយលំអិត។ ទាំងមាន 1) គ្រប់ទាំងសេចក្តីសប្បុរស 2) សេចក្តីសុចរិត និង3) ភាពស្មោះត្រង់។ នេះជាការបង្ហាញនូវរូបឆ្លុះរបស់ព្រះដោយសង្ខេប។ វាមានន័យថាជារូបឆ្លុះ

ដែលមនុស្សបានបាត់បង់ដោយសារបាបរបស់គេដែលត្រូវបានស្តារឡើងវិញនៅក្នុងព្រះគ្រីស្ទ។ ក្រុមជំនុំបង្ហាញពីរូបឆ្លុះជាសញ្ញានៃសេចក្តីសង្គ្រោះនៅគ្រប់កន្លែងទាំងអស់។ ដូច្នេះពួកគេមិនគួរចូលរួមនៅក្នុងកិច្ចការខាងសេចក្តីងងឹតឡើយ ផ្ទុយទៅវិញពួកគេគួរតែស្តីបន្ទោសដល់ការនេះវិញ។ បន្ទាប់មកអ្វីដែលគេត្រូវទទួលបាននូវការស្តីបន្ទោសនឹងបាននៅក្នុងពន្លឺវិញ។

ទីបី ធ្វើជាជីវិតនៃប្រាជ្ញា (15-22) - ប្រាជ្ញាតាមព្រះគម្ពីរមិនមែនជារបៀបនៃជីវិតនិងឧបករណ៍របស់វាឡើយ។ វាមានន័យថាការអនុវត្តនៃចំណេះដឹងដែលចេញពីការកោតខ្លាចនៃសេចក្តីគោរពដល់ព្រះ។ វាជាប្រាជ្ញានៃជីវិតដែលចេញមកពីសេចក្តីគោរពកោតខ្លាចដល់ព្រះ។ ប្រាជ្ញានៃសេចក្តីប្រោសលោះមិនចេញមកពីខ្លួនគេនោះឡើយ តែចេញមកពីព្រះនិងការបង្រៀនរបស់ទ្រង់។

តើយើងគួរតែធ្វើដូចម្តេច? សាវ័កបានបង្រៀនការពីរយ៉ាង (1) ការដឹងនូវពេលវេលាការបង្គាប់ "ចូរសន្សំសំចៃពេលវេលា" មានន័យថាគេត្រូវប្រើពេលវេលានិងឱកាសបានអនុញ្ញាត្តដល់គេសំរាប់សេចក្តីសប្បុរស។ គេគួរតែជៀសចេញពីគំនិតដូចកូនក្មេង ដែលមិនមាននូវការដឹងពេលវេលា ហើយគេគួរតែរស់នៅអត្ថន័យដ៏ពោរពេញជាមួយនឹងការដឹងនូវការពង្រីកនូវភាពដឹងខ្លួន បើទោះជាក្រុមជំនុំមានអ្វីកើតឡើងនៅកន្លែងណាមួយ គេគួរតែទទួលស្គាល់ថាព្រះជាព្រះអម្ចាស់របស់គេហើយថ្វាយដាច់ខ្លួនរបស់គេសំរាប់នឹងសំរេចនូវបំណងរបស់ព្រះ។ ហើយក្រុមជំនុំទទួលថាគេចង់រស់នៅជាមនុស្សដែលព្រះប្រើដោយមានគោលបំណង ពីព្រោះគ្រប់ការទាំងអស់នឹងត្រូវបានសំរេចសេចក្តីសប្បុរសជាមួយគ្នា។ (2) ជាការស្វែងរកបំណងព្រះហឫទ័យរបស់ព្រះ។ ព្រះហឫទ័យដែលត្រូវបានសំរេចបំពេញនៅស្ថានសួគ៌ នោះនឹងត្រូវសំរេចបំពេញនៅផែនដីជាប្រាកដ។ យើងគួរតែប្រាកដថាគ្រប់ការទាំងអស់ដែលប្រឆាំងនិងទាស់បំណងព្រះហឫទ័យរបស់ព្រះនឹងត្រូវបានបំផ្លាញ ហើយនឹងមានសេចក្តីនឿយព្រួយនៅក្នុងការស្វែងរកបំណងរបស់ព្រះនៅក្នុងគ្រប់ការទាំង

អស់និងផ្តោតទៅលើការនោះ។ បំណងព្រះហឫទ័យរបស់ព្រះនោះជាព្រះបន្ទូលរបស់ព្រះដោយពេញលេញ និង ដោយចង្អៀតនោះជាធាតុដែលលំអិត ដែលព្រះបន្ទូលរបស់ព្រះចង្អុលទៅកាន់។ ការសំគាល់ដែលបង្គាប់ "ចូរអរសប្បាយ ជូរអរព្រះគុណនៅក្នុងគ្រប់ការទាំងអស់ ហើយអធិស្ឋានឥតឈប់ឈរ" ជាបំណងរបស់ព្រះដែលជាគំរូរបស់ក្រុមជំនុំ។ នៅពេលដែលហាបាគុកទូញសង្រេងនៅចំពោះព្រះជាមួយនឹងសំណួរមួយចំនួន ដែលចេញមកពីការឲ្យហេតុផលរបស់គាត់ ព្រះអម្ចាស់បង្ហាញបំណងព្រះហឫទ័យរបស់ទ្រង់ ហើយធ្វើឲ្យគាត់យល់ពីកម្ពស់នៃបំណងរបស់ទ្រង់ នឹងធ្វើឲ្យគាត់មានអំណរដល់ព្រះផ្ទាល់ បើទោះជាគាត់ត្រូវទទួលស្គាល់ថាមានតែព្រះទេដែលមានចេស្តា។ បំណងព្រះហឫទ័យរបស់ព្រះគឺដើម្បីនឹងបង្កើតនូវគម្រោងនៃសេចក្តីប្រោសលោះឲ្យបានពេញ។ ពីព្រោះព្រះទ្រង់ចង់បង្កើតនូវបំណងព្រះហឫទ័យរបស់ព្រះនៅក្នុងអ្នកជឿ ដែលជាប្រភពបង្ហូរនូវសេចក្តីប្រោសលោះដែលព្រះបានធ្វើឲ្យពួកគេយល់ពីបំណងរបស់ទ្រង់យ៉ាងគ្រប់គ្រាន់នៅក្នុងភាពពេញបរិបូរណ៍ និងភាពរងទុក្ខវេទនានាពេលបច្ចុប្បន្ន។ ប៉ុន្តែព្រះចង់ឲ្យក្រុមជំនុំស្គាល់នូវបំណងព្រះហឫទ័យរបស់ព្រះហើយក៏ឆ្លើយតបវិញនៅក្នុងគ្រប់ការនោះ។

ទីបួន ទទួលនូវភាពពេញដោយព្រះវិញ្ញាណបរិសុទ្ធ (18) - សាវ័កមិនចង់បង្ហាញពីគំរូរបស់ក្រុមជំនុំ ដើម្បីនឹងស្តារឡើងវិញនូវរូបឆ្លុំរបស់ព្រះជាគំរូហើយបង្រៀនរបៀបដើម្បីបង្កើតវាឡើយ។ វាជាជីវិតដើម្បីនឹងបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះគាត់បានបង្គាប់ "ចូរឲ្យអ្នកបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ" ជាបំណងលើអស់ទាំងបំណងរបស់ព្រះ។ ក្រៅពីការពេញដោយព្រះវិញ្ញាណបរិសុទ្ធ គ្រប់ការទាំងអស់នឹងមិនអាចទៅរួចឡើយ។

ភាពពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធចង្អុលទៅកាន់ជីវិតដែលព្រះវិញ្ញាណគ្រប់គ្រងលើ។វាមានន័យថាយើងចូលរួមនៅក្នុងកិច្ចការអនុវត្តរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយដើរតាមការដឹកនាំរបស់ទ្រង់ដោយស្មោះត្រង់។ សំខាន់ជាងនេះទៀត

នោះការងារនោះមិនផ្តោតលើទីសំគាល់ដើម្បីនឹងសំដែងនូវការដឹកនាំរបស់ទ្រង់ទេ ប៉ុន្តែដើរតាមការដឹងនាំរបស់ទ្រង់ដោយស្មោះត្រង់ដែលដឹកនាំទៅកាន់សេចក្តីពិត។ ការដែលក្រុមជំនុំទទួលបានភាពពេញដោយព្រះវិញ្ញាណបរិសុទ្ធត្រូវបានបង្ហាញដោយបទពិសោធន៍នៃពួកសាវ័កនៅក្នុងក្រុមជំនុំដើមនៅក្នុងបុណ្យថ្ងៃទីហាសិប។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតលើពួកគេ ជីវិតរបស់ពួកសាវ័កបាននាំមកនូវបន្ទាត់មួយដែលខ័ណ្ឌដាច់នៅក្នុងជីវិតរបស់ពួកសាវ័កជាពិសេស ហើយបានបង្ហាញនូវផលផ្លែខុសៗគ្នានៅក្នុងជីវិតរបស់ពួកគេ។ បទពិសោធដូច្នេះគួរតែកើតឡើងម្តងហើយម្តងទៀតតាមដំណាក់កាល។ ពីព្រោះមានតែព្រះវិញ្ញាណបរិសុទ្ធទេដែលស្គាល់យ៉ាងច្បាស់នូវសេចក្តីប្រោសលោះនៅក្នុងព្រះគ្រីស្ទ។

យើងទទួលបានដោយរបៀបណា? យើងត្រូវការលក្ខខណ្ឌពីរយ៉ាង។ 1) ការប្រែចិត្ត និង2) សេចក្តីជំនឿ។ នៅពេលដែលក្រុមជំនុំលន់តួបាបហើយទទួលនូវសេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទ ព្រះវិញ្ញាណនឹងមកលើពួកគេ។ ក្រុមជំនុំដែលរួចរាល់នឹងទទួលពិធីជ្រមុចនៃព្រះវិញ្ញាណបរិសុទ្ធគួរតែស្វែងរកនូវពីធីជ្រមុចដោយចេស្តាសំរាប់ការធ្វើព័ន្ធកិច្ចនិងការបន្សុត ពីព្រោះកិច្ចការចម្បងរបស់យើងគឺការពេញដោយព្រះវិញ្ញាណបរិសុទ្ធជាជាងការពិភាក្សាបញ្ហានៃលក្ខណៈនៃមនុស្សទាំងអស់និងការបន្ត។ ទ្រឹស្តីអត្ថន័យរបស់ពួកបរិសុទ្ធអំពីចេស្តានៃព្រះវិញ្ញាណបរិសុទ្ធហាក់ដូចជាមានភាពទាក់ទាញជាង។

នៅពេលកំណាង់ត្រូវបានលេចមក នោះនឹងមានព្រឹត្តិការណ៍អ្វីកើតឡើង? ឥទ្ធិពលដែលនឹងរីករាយដាលទៅកាន់ក្រុមគ្រួសារ មុខរបរ និងសហាគមន៍។ ភាពជាក់ស្តែងដែលព្រះគុណរបស់ក្រុមជំនុំទៅកាន់ព្រះគុណឆ្ពោះទៅកាន់លោកិយ ជាគម្រោងផែនការរបស់ព្រះ ហើយជារបៀបដែលព្រះវិញ្ញាណបរិសុទ្ធដឹកនាំ។ សាវ័កបានបង្គាប់ 1) ចូរច្រៀងចម្រៀងខាងវិញ្ញាណដោយចេញពីចិត្ត ពីព្រោះការសរសើរដ៏ពិតចេញមកពីការពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ 2) គេគួរតែថ្វាយនូវការអរគុណនៅគ្រប់កាលៈទេសៈទាំងអស់។ 3) ពួកគេគួរតែស្រឡាញ់គ្នាទៅវិញទៅមក

ហើយគួរតែស្តាប់បង្គាប់។ ការលូតលាស់នេះអាចនឹងបញ្ជេះទីក្រុងរបស់អារក្ស ហើយធ្វើឲ្យលោកិយទាំងមូលក្លាយជាអាណាចក្ររបស់ព្រះ។

## 2. ទំនាក់ទំនងអ្នកជិតខាងរបស់ក្រុមជំនុំ (5:22-6:8)

ភាពពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធគួរតែបង្ហាញដោយចរិយាមាយាទនិងសីលធម៌នៃទំនាក់ទំនងរបស់មនុស្ស។ វាមានន័យថានៅក្នុងទំនាក់ទំនងប្តីប្រពន្ធ ឪពុកនិងកូន ហើយចៅហ្វាយនិងអ្នកបំរើ នោះបំណងព្រះហឫទ័យរបស់ព្រះគួរតែបានសំរេច។

(1) ទំនាក់ទំនងប្តីប្រពន្ធ (5:22-33) - សាវ័កបានគិតនិងបង្គាប់ថានៅក្នុងទំនាក់ទំនងរវាងប្តីនិងប្រពន្ធ ការសំរេចតាមបំណងព្រះហឫទ័យរបស់ព្រះនឹងត្រូវបានបង្ហាញដោយភាពពោរពេញនៃព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលដែលយើងបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ការផ្លាស់ប្រែដោយផ្ទាល់ខាងវិញ្ញាណនឹងត្រូវបានកើតឡើង ហើយក្រុមគ្រួសារនឹងត្រូវបានផ្លាស់ប្រែដោយចេស្តា ពីព្រោះការផ្លាស់ប្រែដោយផ្ទាល់ខ្លួននឹងមានឥទ្ធិពលទៅលើការផ្លាស់ប្រែនៅក្នុងគ្រួសារ។

(2) លើគ្រប់ការទាំងអស់គ្រួសារជាចំណុចស្នូលនៅក្នុងការបង្កើតសេចក្តីប្រោសលោះនៅក្នុងគម្រោងផែនការរបស់ព្រះសំរាប់ការប្រោសលោះនៅមុខរបស់ដែលត្រូវបានបង្កើតមក។ ដូច្នេះព្រះទ្រង់ផ្ទាល់បានបង្កើតប្រព័ន្ធគ្រួសារទៅតាមគោលការណ៍នៃការបង្កបង្កើតនិងបានបង្គាប់ឲ្យប្រពន្ធគោរពដល់ប្តីខ្លួន ហើយប្តីគួរតែស្រឡាញ់ប្រពន្ធខ្លួនដើម្បីនឹងបង្កើតនូវគំរូនៃនគររបស់ដំណឹងល្អ និងឆ្ពោះទៅកាន់ជីវិតដែលមានស្ថានសួគ៌ជាចំណុចកណ្តាលនៅក្នុងពិភពលោក។ ដូច្នេះសាវ័កមានប្រតិកម្មថាការផ្លាស់ប្រែនៅក្នុងដំណឹងល្អគួរតែសំដែងនៅក្នុងការផ្លាស់ប្រែរបស់ក្រុមគ្រួសារ។ គាត់បាននិយាយថាអ្នកដែលពេញលេញនៅក្នុងគ្រួសារមួយគួរ

តែជាលក្ខខណ្ឌដែលមានគុណតម្លៃនៃអ្នកបំរើរបស់ក្រុមជំនុំ។ ហើយគាត់បានចង្អុលថាអំពើបាបបំផ្លាញគ្រួសារ អំពើបាបនៃការផិតខាងវិញ្ញាណដែលប្រឆាំងនឹងព្រះជាខ្លាំង។ ហើយបានប្រព្រឹត្តទៅកាន់ការរៀបការរបស់អ្នកដែលគោរពព្រះក្លែងក្លាយដូចជាអំពើបាបនៃសេចក្តីស្លាប់និងអំពើបាបដែលគួរតែចេញពីពួកអ៊ីស្រាអែល បានចង្អុលទៅកាន់សារៈសាំខាន់របស់ក្រុមគ្រួសារ។ ដូច្នេះភាពជាស្រ្តីដែលមិនចេញមិពីព្រះគម្ពីរនាពេលបច្ចុប្បន្នបានអះអាងនូវគោលបំណងរបស់ពួកគេជាមួយនឹងហេតុផលមួយចំនួន ដើម្បីនឹងអង្រួននូវរបៀបរបបមូលដ្ឋាននៃក្រុមគ្រួសារ នោះមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះវិញ្ញាណបរិសុទ្ធឡើយ។
សាវ័កបានសង្កត់ធ្ងន់នៅទីនេះពីសេចក្តីស្រឡាញ់និងការស្តាប់បង្គាប់។ វាមានន័យថាគាត់ទាមទារនូវសេចក្តីស្រឡាញ់ដូចព្រះគ្រីស្ទបានស្រឡាញ់ក្រុមជំនុំនិងការស្តាប់បង្គាប់ដូចក្រុមជំនុំបានស្តាប់បង្គាប់ព្រះគ្រីស្ទ ពីព្រោះការនេះសំរេចនូវការតាំងសញ្ញានៅក្នុងព្រះគ្រីស្ទសំរាប់រាស្រ្តនៅក្នុងការតាំងសញ្ញាថ្មី។ ពាក្យមួយទៀត វាមានន័យថាគោលការណ៍ដ៏ធំអស្ចារ្យដែលព្រះទ្រង់ជាព្រះរបស់អ្នក ហើយអ្នកជារាស្រ្តរបស់ទ្រង់ គួរតែបានសិក្សានៅក្នុងអត្ថន័យនៃគ្រួសារ។ ក្រុមជំនុំជាសភាពដែលត្រូវបានពង្រីករបស់គ្រួសារ និងក្រុមគ្រួសារជាសភាពមួយដែលកាត់បន្ថយរបស់ស្ថានសួគ៌។ ហើយប្រពន្ធគួរតែបានហ្វឹកហាត់នូវការស្តាប់បង្គាប់ដោយការគោរពដល់ប្តីខ្លួន ហើយប្តីត្រូវបានហ្វឹកហាត់ស្រឡាញ់ដោយការស្រឡាញ់ប្រពន្ធខ្លួន។ ដើម្បីបង្កើតក្រុមជំនុំពេញដោយសិរីរុងរឿងនៅក្នុងលោកិយនេះ។

(2) ទំនាក់ទំនងរបស់ឪពុកម្តាយនិងកូន (6:1-4) កិច្ចការដែលជាបំណងរបស់ទ្រង់គឺសំរេចនៅក្នុងទំនាក់ទំនងរបស់ឪពុកម្តាយនិងកូន។ កូនៗគួរតែស្តាប់បង្គាប់ឪពុកម្តាយនៅក្នុងព្រះអម្ចាស់ហើយគោរព។ ហើយឪពុកម្តាយគួរតែបង្រៀនកូនជាមួយការបង្រៀននិងការបន្ទោសរបស់ព្រះអម្ចាស់។ នេះជារូបភាពនៃក្រុមជំនុំ។ ក្រុមជំនុំថ្វាយខ្លួនដើម្បីនឹងធ្វើតាមព្រះបន្ទូលរបស់ព្រះ ដើម្បីនឹងសំរេចតាមនូវការរួបរួមតាម

បំណាងព្រះហឫទ័យរបស់ព្រះ។ តាមអត្ថន័យក្រុមជំនុំគួរតែជាសាលារៀនរបស់ព្រះគ្រីស្ទនិងជាផ្ទះនៃព្រះបន្ទូល។

(3) ទំនាក់ទំនងរបស់ចៅហ្វាយនិងអ្នកបំរើ (5-9) អំណាចដែលមានប្រសិទ្ធិភាពដែលអនុវត្តទៅកាន់គ្រួសារគួរតែបង្ហាញនៅក្នុងសហគមន៍ដែលទាក់ទងទៅនឹងមនុស្ស។ វប្បធម៌ និង ការអភិវឌ្ឍគឺជាលទ្ធផលនៃសហគមន៍។ ក្រុមជំនុំមិនគួរបន្ធូរបន្ថយជាមួយនឹងលោកិយ ឬ គួរតែផ្លាស់ប្រែនូវវប្បធម៌នោះ ហើយបង្កើតនូវនគររបស់ព្រះនៅទីនោះ។ សីលធម៌និងឥរិយាបថគួរតែជាកិច្ចការដែលសំខាន់ដែលក្រុមជំនុំគួរយកជាទំនួលខុសត្រូវ។ វាមានន័យថាយើងគួរតែបំពេញនៅក្នុងសហគមន៍ទៅកាន់ព្រះបន្ទូលរបស់ព្រះ ដោយការពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ អ្នកបំរើគួរតែស្តាប់បង្គាប់ចៅហ្វាយជាមួយសេចក្តីកោតខ្លាចនិងការគោរព ដូចក្រុមជំនុំបានធ្វើទៅកាន់ព្រះគ្រីស្ទ ហើយចៅហ្វាយមិនគួរតែគ្រប់គ្រងអ្នកបំរើខ្លួនដោយអំពើហិង្សានិងការធ្វើទុកបុកម្នេញនោះឡើយ។ វាមានន័យថាដើម្បីនឹងបង្ហាញពីទំនាក់ទំនងរវាងព្រះនិងក្រុមជំនុំ។ ទំនុកចិត្តរបស់អ្នកបរិសុទ្ធដែលបានមកដល់ទ្វីបនោះគឺ "ពួកគេបានមកដើម្បីបំរើនៅក្នុងវាលរហោស្ថាន ដើម្បីនឹងបង្កើតនូវនគររបស់ព្រះអម្ចាស់" ដែលត្រូវបានពឹងលើព្រះបន្ទូលរបស់ព្រះដើម្បីនឹងបង្កើតអាណាចក្ររបស់ព្រះជាមួយនឹងឥរិយាបថនិងសីលធម៌របស់ព្រះ។ ជាចុងក្រោយ ពួកគេអាចបង្កើតនគរមួយដ៏ស្រស់ស្អាត ដែលមានលក្ខណៈត្រឹមត្រូវនៅក្នុងពិភពលោក។ ដូចជាអាណាចក្រនេះ ភាពពេញដោយព្រះវិញ្ញាណបរិសុទ្ធជាបទពិសោធន៍ពិតៗដែលទទួលបាននូវគោលបំណងចម្បងរបស់ក្រុមជំនុំ។

## សរុបសេចក្តី៖

ឧទាហរណ៍របស់ក្រុមជំនុំគឺជាព្រះអម្ចាស់ផ្ទាល់។ នៅពេលដែលយើងយកគំរូតាមលក្ខណៈរបស់ទ្រង់ ក្រុមជំនុំអាចធ្វើនូវកិច្ចការទីមួយរបស់គេ។ លើសអស់ទាំង

ការ ក្រុមជំនុំគួរតែបង្ហាញនូវលក្ខណៈរបស់ព្រះ ហើយកាន់ខ្ជាប់លក្ខណៈនៃសេចក្តីសុចរិតដែលមិនអាចបន្ធូរបន្ថយបាន។ ដូច្នេះក្រុមជំនុំគួរតែមានលក្ខណៈនៃភាពស្មោះត្រង់ ពីព្រោះលក្ខណៈនេះត្រូវបានពឹងលើសេចក្តីពិត។ យើងរកឃើញថាទោះជាគំរូជាច្រើននៅក្នុងព្រះគម្ពីរ ផលផ្លែនៃពន្លឺ។ អ្វីដែលផលផ្លែនេះអនុវត្តនៅក្នុងជីវិតជាបំណងរបស់ព្រះ។ ផ្នែកដែលភ្ជាប់ទៅនឹងក្រុមជំនុំចេញមកជាពន្លឺរបស់ព្រះទោះបីជាវាងងឹតខ្លាំងយ៉ាងណាក៏ដោយ លោកិយនឹងត្រូវបានផ្លាស់ប្តូរជាពន្លឺ។

ដូចដែលយើងដឹងហើយថាពេលបច្ចុប្បន្នដែលយើងតែងតែមាននូវបញ្ហាជាច្រើនតាមរយៈអ៊ីនធឺណិតនិងទូរទស្សន៍ដែលងងឹតខ្លាំងណាស់។ បន្ទាប់មកប្រសិនបើយើងរស់នៅដូចជាពន្លឺព្រះ សេចក្តីងងឹតនឹងត្រូវរលាយបាត់ភ្លាមទៅ។ ពេលនេះដែលមនុស្សស្វែងរកដើម្បីនឹងក្លាយជាគំរូនៃសេចក្តីសប្បុរស ជាម្នាក់ដែលបានថ្វាយបុត្រារបស់ទ្រង់ដោយគ្មានលក្ខខណ្ឌ នឹងផ្តល់មកនូវចេស្តាដល់យើងជាប្រាកដ។

លំហាត់

មេរៀនទី 7

# ការវាយប្រឆាំងរបស់ក្រុមជំនុំ

អេភេសូ 6:10-24

"ឯសេចក្ដីឯទៀត បងប្អូនអើយ ចូរឲ្យមានកម្លាំងឡើង ក្នុងព្រះអម្ចាស់ដោយឫទ្ធិបារមីរបស់ព្រះចេស្ដាទ្រង់។ ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអាចនឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអំបាលម៉ានរបស់អារក្ស។" (អេភេសូ 6:10-11)

## មេរៀនទី 7 **ការវាយប្រឆាំងរបស់ក្រុមជំនុំ**

គោលគំនិត៖

1. បរិស្ថានដែលងងឹត - សត្រូវដែលក្រុមជំនុំត្រូវតែវាយប្រឆាំងគឺជាវិញ្ញាណអាក្រក់។

2. គ្រឿងសឹកដែលទាហ៊ានពាក់ - គ្រឿងសឹកទាំងអស់ដែលព្រះបានរៀបចំសំរាប់ពួកបរិសុទ្ធ។

(1) មួកសឹក – ការធានាអះអាងនៃសេចក្តីសង្គ្រោះ។

(2) ខែល – សេចក្តីជំនឿដែលពឹងទៅលើតែព្រះអម្ចាស់តែមួយនៅក្នុងគ្រប់ការទាំងអស់។

(3) អាចក្រោះ – សេចក្តីសុចរិតរបស់ព្រះ។

(4) ខ្សែក្រវ៉ាត់ – ចិត្តដែលស្រឡាញ់សេចក្តីពិត។

(5) ស្បែកជើង – ជីវិតដែលប្រកាសដំណឹងល្អនៃសន្តិភាព។

(6) ដាវ – ព្រះបន្ទូលរបស់ព្រះ។

(7) ឥរិយាបថដែលមើលឆ្ពោះទៅមុខ - ជីវិតនៃការអធិស្ឋានដោយឥតឈប់ឈរ។

រូបភាព

# មេរៀនទី 7
# ការវាយប្រឆាំងរបស់ក្រុមជំនុំ

I. អត្ថបទ៖ អេភេសូ 6:10-24

II. ខគម្ពីរសំខាន់៖ អេភេសូ 6:10-11

III. សេចក្តីណែនាំ៖

ដោយសារអ្នកបរិសុទ្ធរស់នៅក្នុងសមរភូមិខាងវិញ្ញាណរហូតដល់ពេលដែលគេត្រូវចាកចេញពីផែនដីនេះ សាវ័កបាននាំមកនូវរូបភាពនៃក្រុមជំនុំដែលមានសិរីរុងរឿង ហើយបានកំសាន្តចិត្តដល់ក្រុមជំនុំអេភេសូ ហើយបានជម្រុញថា ពួកគេគួរតែរស់នៅក្នុងជីវិតដែលទាក់ទងនឹងសេចក្តីប្រោសលោះ ហើយគួរវាយប្រឆាំងទាស់នឹងសត្រូវខាងវិញ្ញាណជាមួយនឹងការបង្គាប់របស់ពួកសាវ័ក។ ដោយសារតែចំបាំងខាងវិញ្ញាណកើតមានឡើងរហូតដល់ចុងបំផុតនៃផែនដីនេះ ក្រុមជំនុំត្រូវបានចម្រើនកំលាំងថែមទៀត ដូចជាផ្នែកដែលចែងចាំងយ៉ាងខ្លាំងនៃត្បូងពេជ្រ។ ក្រុមជំនុំសំដែងពីពន្លឺនៃកូនៗរបស់ព្រះអាទិករ ជាអង្គដែលផ្គត់ផ្គង់ និងជាអង្គដែលប្រោសលោះ។ ដូចជាពួកអ៊ីស្រាអែលដែលបានចូលទៅក្នុងទឹកដីកាណាន ហើយរីករាយនឹងភាពបរិបូរណ៍ដោយទឹកដោះនឹងទឹកឃ្មុំ ពួកគេគួរតែវាយប្រឆាំងនឹងកុលសម្ព័ន្ធដែលនៅសេសសល់ ដើម្បីនឹងយកគំរូតាមរូបឆ្លុះរបស់ព្រះ។ នៅក្នុងអេភេសូយើងអាចមើលឃើញចំណងជើងមួយចំនួន "ការសរសើរដំកើងរបស់ក្រុមជំនុំអាថិកំបាំងរបស់ក្រុមជំនុំ អ្នកបំរើរបស់ក្រុមជំនុំ ការរួបរួមរបស់ក្រុមជំនុំ និងគំរូរបស់ក្រុមជំនុំ រៀននៅផ្នែកចុងក្រោយ អ្វីដែលជាគោលបំណងនៃចំបាំងខាងវិញ្ញាណ ពីវត្ថុបំណងនៃចំបាំង វិធីសាស្រ្តនៃចំបាំជាអ្វី"។

IV. សេចក្តីអធិប្បាយៈ

សាវ័កដែលមានបទពិសោធន៍នូវចំបាំងខាងវិញ្ញាណចេញពីការប្រែចិត្តរបស់គាត់នៅក្រុងដាម៉ាស ទៅកាន់ជីវិតរបស់គាត់នៅក្នុងគុកក្រុងរ៉ូម នៅតែបន្តបង្ហាញថាក្រុមជំនុំគួរតែរស់នៅដូចជាអ្នកចម្បាំងគ្រប់ពេល។ ក្រុមជំនុំដែលសម្លឹងទៅកាន់សិរីរុងរឿងនៃសេចក្តីប្រោសលោះ ហើយសរសើរដល់ការនោះ គួរតែមានបំណងដែលរត់ដេញចាប់អ្វីដែលនៅខាងមុខ។ វាជាសេចក្តីពិតខាងព្រះគម្ពីរនៃការសមប្រកបនៅក្នុងគ្រប់ការទាំងអស់។ អ្នកដែលនៅក្នុងព្រះគ្រីស្ទគួរតែឈរ អ្នកដែលក្រោកឈរគួរតែលះបង់ដើម្បីនឹងគ្រប់គ្រង់លើផែនដី។ ដូចជាកាលែបដែលគ្រប់គ្រងលើភ្នំនៃហេប្រុនដែលមិនអាចបំផ្លាញដែលបានត្រួសត្រាយដោយខ្លួនគាត់នៅក្នុងកាលអាយុ៨៦ឆ្នាំ សេចក្តីអង់អាច បំណងចិត្ត និងសេចក្តីដែលតស៊ូដូច្នេះដែលយើងត្រូវការ។ វាជាហេតុផលដែលព្រះអម្ចាស់នៅតែបន្តទុកនូវសភាពដែលលាយឡំនូវគ្រាប់ពូជនិងខ្មៅជាមួយគ្នា។

### 1. គោលបំណងនៃចំបាំងខាងវិញ្ញាណ (13)

ហេតុអ្វីបានជាព្រះអនុញ្ញាតនូវចំបាំងខាងវិញ្ញាណទៅកាន់ក្រុមជំនុំដែលត្រូវទទួលបាននូវសេចក្តីប្រោសលោះ? សាវ័កពន្យល់ពីគោលបំណងបីសំរាប់ចំបាំងខាងវិញ្ញាណនៅទីនេះ។

ទីមួយ ខ 10, 13 និង 14 ដែលបានលើកឡើង "ជាចុងក្រោយ ចូរមានកម្លាំងក្នុងព្រះអម្ចាស់និងនៅក្នុងចេស្តាទ្រង់ចុះ...ហេតុនោះបានជាត្រូវឲ្យយកគ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទប់ទល់ក្នុងថ្ងៃអាក្រក់បាន រួចកាលណាបានតតាំងសព្វគ្រប់ហើយ នោះឲ្យបាននៅតែឈរមាំមួនដដែល។ ដូច្នេះចូរឲ្យឈរមាំមួនចុះ ដោយក្រវាត់សេចក្តីពិតនៅចង្កេះ ហើយពាក់សេចក្តីសុចរិតទុកជាប្រដាប់

បាំងទ្រូង”។ វាមានន័យថាក្រុមជំនុំគួរតែវាយប្រឆាំងដោយវិញ្ញាណ ដើម្បីក្លាយជាអ្នកដែលពេញវ័យនៅក្នុងព្រះអម្ចាស់ ហើយជាអ្នកដែលពេញដោយគ្រប់ការទាំងអស់របស់ព្រះ។ ក្រុមជំនុំដែលត្រូវទទួលបានសេចក្តីប្រោសលោះដែលនៅជាប់នឹងព្រះគ្រីស្ទ ហើយត្រូវបានពេញដោយព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ ដោយត្រូវបានផ្លាស់ប្រែទៅជាមនុស្សថ្មីចេញពីមនុស្សចាស់មក គួរតែដើរតាមផ្លូវចង្អៀងនៅក្នុងលោកិយរហូតដល់ពេលព្រះគ្រីស្ទយាងមកម្តងទៀត។ ដូច្នេះក្រុមជំនុំមាននូវរឿងជាច្រើនដែលត្រូវទួញសោករហូតដល់ថ្ងៃនៃសេចក្តីប្រោសលោះបានពេញលេញ។ ហើយគ្រប់ការទាំងអស់ក៏រង់ចាំថាកូនរបស់ព្រះនឹងត្រូវបានសំដែងហើយក៏ទួញសោក។ ហើយឧបករណ៍របស់សាតាំង សេចក្តីល្បួងនៃលោកិយ និងសេចក្តីពុករលួយនៃសាច់ឈាមវាយប្រហារក្រុមជំនុំតាមវិធីសាស្រ្តជាច្រើន ដើម្បីធ្វើឲ្យពួកគេត្រូវបានកាត់ចេញពីទំនាក់ទំនងជាមួយនឹងព្រះគ្រីស្ទ។ ហើយវាក៏មាននូវគោលបំណងមួយយ៉ាងមុតមាំ ដើម្បីនឹងធ្វើឲ្យយើងមិននៅជាប់ជាមួយនឹងព្រះគ្រីស្ទដោយធ្វើឲ្យមានការច្រឡំលើដំណឹងល្អ។ ហើយដើម្បីនឹងកាត់នូវការប្រកបជាមួយព្រះជាបណ្តោះអាសន្ន ដោយការទំលាក់មកនូវសេចក្តីសង្ស័យនៅក្នុងគំនិតរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមជំនុំមាននូវគ្រឹះដោយជ័យជំនះរបស់ព្រះគ្រីស្ទ សេចក្តីសំរាកដ៏អស់កល្បនៅក្នុងព្រះគ្រីស្ទ ដោយការដើរតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ និងដោយប្រើវិធីសាស្រ្តដែលខ្ពស់ប្រសើរជាងវិធីសាស្រ្តរបស់សាតាំងថែមទៀត។ ដូច្នេះជាសេចក្តីគួរឲ្យអស្ចារ្យណាស់ដែលក្រុមជំនុំមិនផ្តោតទៅលើកិច្ចការដែលមើលឃើញ ប៉ុន្តែទៅលើបល្ល័ង្កដែលគួរឲ្យសរសើរវិញ។ ក្រុមជំនុំបានបរិសុទ្ធជាងមុន ខ្លាំងជាមុន និងមានជម្រៅជ្រៅជាងមុនតាមរយៈការប្រកបជាមួយព្រះគ្រីស្ទដោយចំបាំនេះ។ ប្រសិនបើក្រុមជំនុំមិនមានចំបាំងទេ គេនឹងត្រូវធ្លាក់ទៅក្នុងការបរាជ័យខាងវិញ្ញាណ ហើយនឹងខិតជិតនូវសេចក្តីវិនាសយ៉ាងធ្ងន់ធ្ងរ។

គោលបំណងទីពីរមិនត្រូវបានជំពប់នៅក្នុងព្រះអម្ចាស់នោះឡើយ។ ជាពិសេសប៉ូលបានជម្រុញថាពួកគេគួរតែមានចំបាំងនៅក្នុងជីវិតមិនមែនដើម្បីធ្លាក់ចុះនៅក្នុង

សេចក្តីពុករលួយនោះឡើយ។ ប្រវត្តិសាស្រ្តបានបង្ហាញយ៉ាងច្បាស់។ ប្រវត្តិសាស្រ្តយ៉ាងវែងអន្លាយរបស់អ៊ីស្រាអែលនៅក្នុងសញ្ញាចាស់ បានបង្ហាញថាបើទោះជាពួកគេមានអភ័យឯកសិទ្ធិពិសេសក៏ដោយ ដោយសារសេចក្តីកំជិលខាងវិញ្ញាណរបស់ពួកគេនិងទង្វើរឹងរូស ពួកគេត្រូវបានធ្លាក់ចុះទៅក្នុងការថ្វាយបង្គំរូបព្រះក្លែងក្លាយនិងសេចក្តីលោភលន់ដ៏អាក្រក់បំផុត។ ហើយនៅពេលដែលក្រុមជំនុំនៅសម័យកណ្តាលត្រូវបានធ្លាក់ចុះនៅក្នុងទំនោរពីខាងក្រៅ ហើយបានមើលងាយដល់ចំបាំងខាងវិញ្ញាណរបស់ពួកគេទៅកាន់សេចក្តីពុករលួយនៅខាងក្នុង ចុងក្រោយពួកគេបានធ្វើមាននូវជំនាន់ដែលងងឹត។ នៅក្នុងពេលបច្ចុប្បន្នមានដំណរដែលកាន់តែងងឹតថែមទៀត។ លើសពីនោះទៀតនៅក្រោមនាមនៃសេចក្តីគោរពកោតខ្លាចដល់ព្រះ ពេលវេលាបានក្លាយជាថ្ងៃដែលសីលធម៌ត្រូវរលាយបាត់ទៅ ពីព្រោះក្រុមជំនុំសំរាកនូវចំបាំងខាងវិញ្ញាណ។ ដូច្នេះក្រុមជំនុំមិនគួរសំរាកនូវចំបាំងខាងវិញ្ញាណឡើយ ដោយលះបង់ដើម្បីនឹងបដិសេធខ្លួនឯង។ វាជាវិធីដើម្បីនឹងរក្សានូវលក្ខណៈដែលបរិសុទ្ធ។

ជាចុងក្រោយយើងគួរតែវាយប្រឆាំងសំរាប់គោលបំណង ដើម្បីនឹងនឹងសំរេចបំពេញនូវបេសកកម្មរបស់ក្រុមជំនុំ។ ក្រុមជំនុំរបស់ព្រះអម្ចាស់ដែលត្រូវបានសម្គាល់នៅខាងលើ គួរតែត្រូវបានថ្វាយដាច់ទៅកាន់ការបង្គាប់ដ៏ធំរបស់ព្រះអម្ចាស់ទៅកាន់ក្រុមគ្រួសារ សហាគមន៍ និងអ្នកជិតខាង។ ការបង្គាប់ដ៏ធំរបស់ព្រះអម្ចាស់មិនមែនជាកិច្ចការនៅក្នុងស្រុកនោះទេ ប៉ុន្តែបង្ហាញនូវសិរីរុងរឿងរបស់ក្រុមជំនុំទៅកាន់គ្រប់កុលសម្ព័ន្ធទាំងអស់រហូតដល់ព្រះគ្រីស្ទយាងមក។ ព្រះគ្រីស្ទនៅក្នុង ម៉ាថាយ 28:19-20 ជាមេទ័ពដែលមានគ្រប់ទាំងអំណាចនៅស្ថានសួគ៌និងនៅផែនដី។ បេសកកម្មនោះគឺការហៅវាស្រ្តដែលបានរើសតាំងនិងបង្កើតសិស្ស។ វាមានន័យថាពួកគេត្រូវសំដែងនូវរូបឆ្លុះរបស់ព្រះគ្រីស្ទនៅក្នុងផែនដីតាមរយៈការផ្សាយដំណឹងល្អការថ្វាយបង្គំ និងការអប់រំ។ សំរាប់គោលបំណងព្រះអម្ចាស់បានរក្សាដូចជាអេម៉ាញូ

អែល ដែលថានៅជាមួយព្រះរហូត។ ពាក្យមួយទៀតថា បេសកកម្មដែលសំខាន់ជាការបើកសំដែងនូវរូបឆ្លុះរបស់ព្រះ សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់គ្រប់កន្លែងទាំងអស់ ទាំងនោះមាន គ្រប់ពូជសាសន៍ទាំងអស់ គ្រប់គ្រួសារទាំងអស់ គ្រប់មនុស្សទាំងអស់ គ្រប់វប្បធម៌ និងគ្រប់តំបន់ទាំងអស់។ ដូច្នេះក្រុមជំនុំគួរតែថ្វាយខ្លួនគេធ្វើនូវគោលបំណងនេះដើម្បីនឹងទាស់នូវចំបាំង Amargedon។

2. វត្ថុបំណងនៃចំបាំងខាងវិញ្ញាណ (11,12)

គោលបំណងនៃចំបាំងខាងវិញ្ញាណដាក់នូវគោលបំណងរបស់វា។ នៅពេលដែលយើងដឹងថាហេតុអ្វីដែលយើងជាធម្មតាវាប្រឆាំង យើងអាចដឹងពីវត្ថុបំណងនៃចំបាំង។ តើក្រុមជំនុំវាយប្រឆាំងនឹងអ្នកណានៅលើផែនដីនេះ?

(1) វិញ្ញាណអារក្ស- អ្នកគ្រប់គ្រង អំណាច អំណាចខាងអាកាសនៅកលើរបស់ខាងស្ថានសួគ៌ដែលជារបស់អារក្សសាតាំង ជាម្នាក់ដែលគ្រប់គ្រងលើអាកាស។ វិញ្ញាណអារក្សនេះវាយប្រហារដោយការរួបរួមទៅនឹងនយោបាយ និងវប្បធម៌របស់លោកិយ ហើយធ្វើឲ្យកែងជើងរបស់ពួកគេមានរបួស។ សាវ័កបានហៅវិញ្ញាណអារក្សថាជាប្រពន្ធរបស់សាតាំង។ (11) ហើយនៅ ២កូរិនថូស 10:4-5 បានលើកថាវាជាទ្រឹស្តីនិងគំនិតគ្រប់ទាំងអស់ ដែលត្រូវបានលើកឡើងទាស់នឹងការស្គាល់ព្រះ។ សាតាំងដែលបានធ្វើឲ្យអ័ដាម និងអេវ៉ាបរាជ័យដោយប្រាជ្ញារបស់ព្រះ។ ដូច្នេះវាបានវាយប្រហារក្រុមជំនុំដែលជាកូនក្រមុំរបស់ព្រះ ក្រុមជំនុំជាមួយនឹងវិធីសាស្ត្រមួយចំនួន។ ជាពិសេសដោយធ្វើឲ្យពួកគេទទួលថា វាធ្វើឲ្យក្រុមជំនុំមានអំណរលើជីវិតអស់កល្បដោយការស្គាល់ព្រះបណ្តោះអាសន្ន។

(2) លោកិយ- វិញ្ញាណអាក្រក់មួយនេះក្រឡឹងជុំវិញផែនដី ដែលជាតំបន់និងជាគោលបំណងនៃសកម្មភាពរបស់គេ។ ពេលខ្លះវាព្យាយាមលេបត្របាក់យើងដូចជាសត្វសិង្ហ ពេលខ្លះវាល្បួងដោយមានការទាក់ទាញដូចជាទេវតានៃសិរីល្អ ហើយព្យាយាមកាត់ការប្រកបជាមួយព្រះចេញ។ លោកិយមិនមែនជារបស់រូបិយទេ ប៉ុន្តែជាការដែលអរូបិយវិញ សេចក្តីត្រេកត្រអាលខាងសាច់ឈាម សេចក្តីត្រេកត្រអាលរបស់ភ្នែក និងអំណួតនៃលោកិយនេះ។ ពីព្រោះក្រុមជំនុំមានទំនួលខុសត្រូវសំខាន់ក្នុងការផ្លាស់ប្តូរលោកិយ ក្រុមជំនុំត្រូវបានល្បួងដោយចេញពីលោកិយ។ ដូច្នេះក្រុមជំនុំនៅក្នុងព្រះគ្រីស្ទគួរតែដឹងខ្លួនមុននូវវិធីសាស្រ្តរបស់សាតាំង ពីព្រោះក្រុមជំនុំរស់នៅក្នុងលោកិយ។

(3) ខ្លួនឯង - សាតាំងនិងលោកិយជាវត្ថុបំណងនៃចំបាំងខាងវិញ្ញាណនៅក្នុងក្រុមជំនុំ ប៉ុន្តែវត្ថុបំណងដែលគ្រោះថ្នាក់និងមានបញ្ហាជាងនេះទៀតនោះគឺសាច់ឈាម (Sarks) ដែលមានទីតាំងនៅក្នុងខ្លួនយើង។ ខ្លួនយើងដែលត្រូវបានបញ្ឆោតដោយសាច់ឈាម សេចក្តីលោភ សេចក្តីត្រេកត្រអាលខាងសាច់ឈាម។ល។ ដែលមានទំនាក់ទំនងទៅនឹងលោកិយ ត្រូវបានប្រើឲ្យដើរតួជាទាសករ។ វាបានធ្វើឲ្យពេត្រុសដើរតាមសេចក្តីល្បួងរបស់សាតាំងមួយរំពេច ដោយបដិសេធផ្លូវនៃឈើឆ្កាង បើទោះជាគាត់បានសារភាពនូវសេចក្តីជំនឿដ៏ធំក៏ដោយ។ ហើយក៏បានធ្វើឲ្យអាកានដេញតាមនូវសេចក្តីលោភលន់នៅក្នុងបរិស្ថានដែលវាងវៃ ដោយបានដាក់នូវសេចក្តីប៉ងប្រាថ្នាចង់មានសំលៀកបំពាក់និងមានមួយចំនួនដែលធ្វើដោយ Sinal។ ដូច្នេះលូធីហេតុផលរបស់មនុស្សដូចជាស្ត្រីពេស្យាចារ។ អ្នកដែលធ្លាប់វាយទាស់នឹងសាច់ឈាមដែលតែងតែផ្លាស់ប្តូរ គាត់អាចដើរតាមព្រះអម្ចាស់យ៉ាងល្អ។ វត្ថុបំណងនៃការវាយប្រយុទ្ធយ៉ាងយូរនៅក្នុងអ្នកជឿជាចំបាំងទាស់នឹងសាច់ឈាមនៅក្នុងគេនោះឯង។

3. វិធីសាស្ត្រនៃសង្គ្រាមខាងវិញ្ញាណ

បន្ទាប់ពីសាវ័កប្រាកដពីវត្ថុបំណងច្បាស់លាស់នៃចំបាំង សាវ័កបានផ្តល់នូវវិធីសាស្ត្រយ៉ាងលំអិតនៃចំបាំងរបស់គាត់។ តើយើងវាយដោយរបៀបណា? នេះជាធាតុអវិជ្ជមាននិងធាតុដែលវិជ្ជមាន។

(1) នៅក្នុងវិធីអវិជ្ជមាន ដំបូងយើងគួរតែសំគាល់ថា វាជាចំបាំងខាងវិញ្ញាណ មិនមែនជាចំបាំងខាងសាច់និងឈាមនោះឡើយ។ វិធីសាស្ត្រនៃឈាមមានន័យថាខ្លួនរបស់គេផ្ទាល់។ មានន័យថា វិធីសាស្ត្រដែលយកខ្លួនឯងជាចំណុចកណ្តាល ដែលលោកិយតែងតែប្រើយ៉ាងប្រសព្វដែលមិនអាចយកឈ្នះវាបានឡើយ។ ដូច្នេះមនុស្សមិនអាចនឹងយកឈ្នះលើចម្បាំងនេះបានឡើយ។ ឧទាហរណ៍ សេចក្តីត្រេកត្រអាលរបស់ពេត្រុសដែលជាអ្នកចង់ដើរតាមព្រះយេស៊ូវរហូតពេលដែលគាត់នឹងស្លាប់ ត្រូវបានប្តូរទៅជាមនុស្សម្នាក់ដែលបដិសេធព្រះយេស៊ូវដោយសារការវាយប្រហាររបស់សាតាំងមួយរំពិច។ ហើយវិធីសាស្ត្រដែលវាព្យាយាមសម្លាប់ម៉ាហ្គោដោយដាវរបស់វាដែលការនោះមកពីវិធីសាស្ត្រខាងសាច់ឈាម។ វិធីសាស្ត្រដូច្នេះត្រូវបានបរាជ័យ។ បើទោះជាទឹកដ៏អស្ចារ្យដែលហូរចេញមកពីថ្ម ពួកគេនៅតែមិនអាចចូលទៅក្នុងទឹកដីកាណាន។ នគរដែលត្រូវបានសំរេចដោយវិធីសាស្ត្រខាងសាច់ឈាម នោះវានឹងមិនអាចក្លាយជាអាណាចក្ររបស់ព្រះគ្រីស្ទឡើយ។ ព្រះអម្ចាស់ចង់បានគោលបំណងនិងវិធីសាស្ត្រដែលមកពីព្រះអម្ចាស់ទ្រង់ផ្ទាល់។

(2) នៅក្នុងវិធីសាស្ត្រវិជ្ជមាន សាវ័កបង្ហាញពីវិធីសាស្ត្រដោយពាក់នូវគ្រឿងសឹកទាំងអស់របស់ព្រះ។ វាជាវិធីសាស្ត្ររបស់ព្រះ។ តួនាទីរបស់យើងគឺត្រូវពាក់នូវអ្វីដែលព្រះបានរៀបចំឲ្យ។ សាវ័កបានផ្តល់នូវគ្រឿងប្រដាប់ខ្លួនយ៉ាងពេញលេញដែលមាននូវអាវុធ៧យ៉ាង។

1) ខ្សែក្រវាត់នៃសេចក្តីពិត - លក្ខណៈដែលអាចទុកចិត្តបាន (សេចក្តីកំពុត)

2) អាវក្រោះ - ការរាប់ជាសុចរិត។

3) ស្បែកជើងដែលប្រកាសដំណឹងល្អនៃសេចក្តីសុខសាន្ត - ឥរិយាបថដែលប្រកាសដំណឹងល្អដោយខិតខំប្រឹងប្រែង។

4) ខែលនៃសេចក្តីជំនឿ - បំផ្លាញនូវធ្នូរភ្លើងដែលចេញមកពីមនុស្សអាក្រក់ - សេចក្តីអាចទុកចិត្តបាន

5) មួកនៃសេចក្តីសង្គ្រោះ – សុវត្ថិភាពយ៉ាងពេញលេញនៅក្នុងសេចក្តីសង្គ្រោះ (យ៉ូហាន 20:28-29)

6) ដាវនៃព្រះវិញ្ញាណបរិសុទ្ធ – ព្រះបន្ទូលរបស់ព្រះ។

7) ការអធិស្ឋាន – ការទូលអង្វរនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ ការអធិស្ឋានឥតឈប់ឈរ។

ប្រសិនបើយើងសង្ខេបការទាំងពីរនេះ វាមានន័យថាយើងអាចយកឈ្នះដោយព្រះបន្ទូលនិងការអធិស្ឋាន។ ពីព្រោះសេចក្តីពិត សេចក្តីសុចរិត ការផ្សាយដំណឹងល្អ សេចក្តីជំនឿ និងព្រះបន្ទូលជាផលផ្លែដែលត្រូវបានរៀបចំនៅក្នុងដំណឹងល្អ។ ពាក្យមួយទៀតថា អ្នកជឿដែលស្មោះត្រង់ទៅនឹងព្រះគម្ពីរ ការនោះផ្ទាល់ជាអាវុធនិងគ្រឿងសឹកយ៉ាងគ្រប់គ្រាន់។ ការអធិស្ឋានដែលយើងទូលសូមនៅក្នុងព្រះវិញ្ញាណផ្តល់នូវកម្លាំងដ៏ចម្លែកធ្វើឲ្យគ្រប់ការទាំងអស់ពិតជាក់ស្តែង។ សាវ័កអាចយកឈ្នះគ្រប់វិធីបោកប្រាស់ទាំងអស់ដែលចេញមកពីលក្ខណៈដែលពុករលួយរបស់លោកិយ សាតាំង សាច់ឈាម។ នៅពេលដែលគាត់មានសុខភាពខ្សោយ គាត់បានសូមបីដងទៅកាន់ព្រះឲ្យបន្លានោះត្រូវដកចេញ ព្រះបានមានបន្ទូលថា "ព្រះគុណរបស់អញល្មមដល់ឯងហើយ" "ហើលនៅពេលដែលឯងខ្សោយ នោះឯងនឹងខ្លាំងឡើង" បន្លាពុំរ៉ៃដែលធ្វើឲ្យគាត់ពាក់នូវគ្រឿងសឹកទាំងអស់របស់ព្រះ ហើយយក

តម្រាប់តាមរូបឆ្លុះរបស់ព្រះដូចជាមនុស្សរបស់ព្រះដែលលោកិយមិនអាចយកឈ្នះបាន។ ដូច្នេះគាត់អាចចំអែកអាស៊ីមីណារាប់បញ្ចូលទាំងក្រុមជំនុំអេភេសូ រ៉ូម និងផែនដីទាំងមូល។ នៅពេលដែលក្រុមជំនុំពាក់នូវគ្រឿងសឹកទាំងអស់របស់ព្រះ ក្រុមជំនុំបានប្រែទៅជាក្រុមជំនុំពេញដោយសិរីល្អតាមរយៈចម្បាំងខាងវិញ្ញាណ។

4. ការប្រសិទ្ធិពរជ័យ (23-24) - ប៉ូលបានបញ្ចប់អេភេសូដោយការប្រសិទ្ធិពរជ័យ "សូមឲ្យបងប្អូនបានប្រកបដោយនូវសេចក្តីសុខសាន្តនិងសេចក្តីស្រឡាញ់ ព្រមទាំងសេចក្តីជំនឿ អំពីព្រះដ៏ជាព្រះវរបិតារបស់ព្រះយេស៊ូវគ្រីស្ទ"។ សូមឲ្យព្រះពរនៅជាប់នឹងអស់អ្នកដែលស្រឡាញ់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទដោយសេចក្តីស្រឡាញ់ដែលមិនសាបសូន្យ។ វាជាបំណងរបស់ព្រះដែលក្រុមជំនុំទទួលនូវព្រះពរខាងវិញ្ញាណ ដោយចាប់ផ្តើមជាមួយនឹងការសរសើរដំកើងព្រះ និងបញ្ចប់ដោយការវាយប្រយុទ្ធដើម្បីនឹងបង្ហាញពីរូបឆ្លុះនៃក្រុមជំនុំដែលត្រូវទទួលនូវសេចក្តីប្រោសលោះ ដែលនឹងត្រូវបានពោរពេញដោយគ្រប់ការខាងព្រះ ដូចជាមកុដដែលក្រុមជំនុំនឹងទទួលសំរាប់ជ័យជំនះនៅក្នុងចម្បាំងខាងវិញ្ញាណ ហើយជម្រុញឲ្យពួកគេមិនត្រូវឲ្យបាត់បង់នូវរង្វាន់នេះ និងបញ្ចប់ជាមួយការប្រសិទ្ធិពរជ័យរបស់សាវ័ក។

## សរុបសេចក្តី៖

ពេលដែលសាវ័កប្រតិកម្មលើចំណាងជើងទាំងប្រាំពីរដែលជាការណែនាំរបស់កណ្ឌគម្ពីរអេភេសូ ការសរសើរដំកើងរបស់ក្រុមជំនុំ អាថ៌កំបាំងរបស់ក្រុមជំនុំ អ្នកបំរើរបស់ក្រុមជំនុំ ការរួបរួមរបស់ក្រុមជំនុំ គំរូរបស់ក្រុមជំនុំ និងចម្បាំងរបស់ក្រុមជំនុំ យើងបានឃើញសិរីរុងរឿងរបស់ក្រុមជំនុំនៅក្នុងព្រះគ្រីស្ទ។ ឥឡូវសិរីល្អនេះត្រូវបានបង្ហាញនៅពេលដែលក្រុមជំនុំព្យាយាមជឿនិងស្គាល់ព្រះគ្រីស្ទ ហើយព្យាយាមវាយប្រយុទ្ធជាមួយនឹងសាច់ឈាមនៅទីនោះ ហើយអាចបង្ហាញសិរីល្អរបស់ទ្រង់នៅលើផែនដី។ ចក្ខុវិស័យរបស់ព្រះសំរាប់ក្រុមជំនុំនឹងត្រូវបានសំរេចបំពេញនៅ

ពេលកំណត់របស់ព្រះជាប្រាកដដោយសារបំណងរបស់ព្រះអម្ចាស់។ យើងដែលជាអ្នកដែលត្រូវបានត្រាស់ហៅមកសំរាប់កិច្ចការនេះ គួរតែបង្ហាញនូវសិរីល្អរបស់ព្រះដោយការបំរើដោយស្មោះត្រង់ទៅកាន់ការត្រាស់ហៅរបស់គាត់ ហើយត្រូវបានប្រើដោយទ្រង់ដើម្បីសំរេចគោលបំណងរបស់ទ្រង់នៅលើផែនដី។

**[ទីបញ្ចប់នៃពិភពលោករបស់អេភេសូ]** Soli Dei Glorii.